# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

-លេខ ៖ ១៥៧ "ក្រ៨ ញ"

-ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០

-សំណុំរឿងព្រហ្មទណ្ឌលេខ ៤៩៣០ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩

-សំណុំរឿងស៊ើបសួរលេខ ៣៣៤៧ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩

-សំណុំរឿងជំនុំជម្រះលេខ ៤៦៧៧ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង ២ និង ៣០នាទី រសៀល និងថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង ៨ និង ៤៥នាទី ព្រឹក នៅសាលសវនាការទី១ ដោយមានសមាសភាព ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោក [redacted] ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញជាប្រធានក្រុមប្រឹក្សា

-លោក [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញជាចៅក្រមប្រឹក្សា

-លោក [redacted] ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៤៩៣០ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ ដែលមាន ៖

១-**ជនជាប់ចោទ** ឈ្មោះ[redacted] **ប៊ុនរឿន** ភេទប្រុស អាយុ ៣៩ឆ្នាំ ជនជាតិខ្មែរ មុខរបរប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តពោធិ៍សាត់ កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូ[redacted] ខេត្តតាកែវ ទីលំនៅមុនពេលឃាត់ខ្លួនភូមិមាន់ចៃ សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ប្រពន្ធឈ្មោះ[redacted] **សុធានី** "រស់" មានកូន ០២ នាក់ ឪពុកឈ្មោះ [redacted] **គ្រុយ** "ស្លាប់" ម្តាយឈ្មោះ[redacted] **លីមសេង** "រស់" ទោសពីមុន គ្មាន ។ (ត្រូវបានឃាត់ខ្លួនកាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៩ និងត្រូវបានឃុំខ្លួនតាមដីកាបង្គាប់អោយឃុំខ្លួនលេខ ៨០១៨ "រ" ដ.ឃ.ដ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ ។)

ជាប់ចោទពីបទ **វិតិក្រម រំលោភអំណាច** និង **សម្អាតប្រាក់** ប្រព្រឹត្តនៅខេត្តពោធិ៍សាត់ កាលពីអំឡុងឆ្នាំ ២០១៦ រហូតដល់ថ្ងៃទី២៦-២៧ ខែកក្កដា ឆ្នាំ២០១៩ តាមបញ្ញត្តិមាត្រា ៥៩២ មាត្រា ៥៩៣ នៃក្រមព្រហ្មទណ្ឌ មាត្រា ៣៥ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និងតាមបញ្ញត្តិមាត្រា ៣ថ្មី មាត្រា ២៩ថ្មី១ នៃច្បាប់ស្តីពីវិសោធនកម្ម មាត្រា ៣ មាត្រា ២៩ និងមាត្រា ៣០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

២-**ជនជាប់ចោទ** ឈ្មោះ[redacted] **វុទ្ធី** ភេទប្រុស អាយុ ៤៧ឆ្នាំ ជនជាតិខ្មែរ មុខរបរអនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តពោធិ៍សាត់ កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិសំរោង ឃុំល្វា ស្រុកព្រះស្តេច ខេត្តព្រៃវែង ទីលំនៅមុនពេលឃាត់ខ្លួននៅផ្ទះលេខ ៥៧៩ ផ្លូវបេតុង ក្រុម៨ ភូមិព្រៃទ្រា សង្កាត់ចោមចៅ៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ[redacted] ចិន្តា មានកូន ០៤នាក់ ឪពុកឈ្មោះ [redacted] គីមស៊ន "ស្លាប់" ម្តាយ ឈ្មោះ [redacted] កាន "រស់" ទោសពីមុន គ្មាន ។ (ត្រូវបានឃាត់ខ្លួនថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៩ និងត្រូវបានឃុំខ្លួនតាមដីកាបង្គាប់អោយឃុំខ្លួនលេខ ៨០១៩ "រ" ដ.ឃ.ដ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ ។)



Scanned with CamScanner

៣-ជនជាប់ចោទ ឈ្មោះ [redacted] ប៊ុនថេង ភេទប្រុស អាយុ ៣២ឆ្នាំ ជនជាតិខ្មែរ មុខរបរមន្ត្រីការិយាល័យសំណង់នៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តពោធិ៍សាត់ កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តពោធិ៍សាត់ ទីលំនៅមុនពេលឃាត់ខ្លួននៅផ្ទះលេខ៨ ផ្លូវលេខ៥១៤ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] ប៊ុណ្ណាង "រស់" ម្តាយឈ្មោះ [redacted] វួចលាង "រស់" ទោសពីមុនគ្មាន ។ (ត្រូវបានឃាត់ខ្លួនថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៩ និងត្រូវបានឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៨០២០ "រ" ដ.ឃ.ដ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ ។)

ជាប់ចោទពីបទ *វិតិក្រម និង រំលោភអំណាច* ប្រព្រឹត្តនៅខេត្តពោធិ៍សាត់ កាលពីថ្ងៃទី២៦-២៧ ខែកក្កដា ឆ្នាំ២០១៩ តាមបញ្ញត្តិមាត្រា ៥៩២ មាត្រា ៥៩៣ នៃក្រមព្រហ្មទណ្ឌ និង មាត្រា ៣៥ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ។

**-ដើមបណ្តឹងរដ្ឋប្បវេណី** ឈ្មោះ [redacted] ទី ភេទប្រុស អាយុ ៤៤ឆ្នាំ ទីលំនៅភូមិត្រពាំងជង ឃុំត្រពាំងជង ស្រុកបាកាន ខេត្តពោធិ៍សាត់ ។

**-ដើមបណ្តឹងរដ្ឋប្បវេណី** ឈ្មោះ [redacted] ហេងឡុង ភេទប្រុស អាយុ ៣៣ឆ្នាំ ទីលំនៅភូមិដើមច្រេះ ឃុំបឹងខ្នា ស្រុកបាកាន ខេត្តពោធិ៍សាត់ ។

**-មេធាវីការពារសិទ្ធិ** លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ប៊ុនវឿន ។

**-មេធាវីការពារសិទ្ធិ** លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វុទ្ធី ។

**-មេធាវីការពារសិទ្ធិ** លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ប៊ុនវឿន ឈ្មោះ [redacted] វុទ្ធី និងឈ្មោះ [redacted] ប៊ុនថេង ។

**-មេធាវីការពារសិទ្ធិ** លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វុទ្ធី ។

**-មេធាវីការពារសិទ្ធិ** លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ប៊ុនថេង ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីអំឡុងខែមេសា ឬខែឧសភា ឆ្នាំ២០១៩ តំណាងក្រុមហ៊ុនបានមកទំនាក់ទំនងឈ្មោះ [redacted] ប៊ុនថេង (មន្ត្រីការិយាល័យសំណង់នៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តពោធិ៍សាត់) ដើម្បីសួរនាំពីការសុំច្បាប់ធ្វើស្ទូឡា ពេលនោះឈ្មោះ [redacted] ប៊ុនថេង បានរាយការណ៍ទៅឈ្មោះ [redacted] ប៊ុនវឿន (ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តពោធិ៍សាត់) និងបានជួបគ្នាជាមួយតំណាងក្រុមហ៊ុន ហើយតំណាងក្រុមហ៊ុនបានប្រគល់ឯកសារប្តង់ទៅឱ្យឈ្មោះ [redacted] ប៊ុនថេង ។ នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង ១១ ព្រឹក ឈ្មោះ [redacted] ប៊ុនថេង បាននាំតំណាងក្រុមហ៊ុនទៅជួបឈ្មោះ [redacted] ប៊ុនវឿន នៅក្នុងបន្ទប់ការិយាល័យធ្វើការរបស់ឈ្មោះ [redacted] ប៊ុនវឿន ដើម្បីនិយាយរឿងសេវាស្នើសុំសាងសង់ស្ទូឡា ហើយឈ្មោះ [redacted] ប៊ុនវឿន និងឈ្មោះ [redacted] ប៊ុនថេង បានធ្វើការគុណគូរថ្លៃសេវាអស់ ៧៥.០០០ (ចិតសិបប្រាំពាន់) ដុល្លារអាមេរិក ជាថ្លៃរត់ប្លង់ដី និងអស់ចំនួន ២៥.០០០ (ម្ភៃប្រាំពាន់) ដុល្លារអាមេរិក ជាថ្លៃសុំច្បាប់សាងសង់សរុបចំនួន ១០០.០០០ (មួយរយពាន់) ដុល្លារអាមេរិក ។ ពេលនោះ ខាងក្រុមហ៊ុនបានប្រាប់ថា មានប្រាក់ជាប់ខ្លួនតែ ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក ទេ ហើយខាងក្រុមហ៊ុនក៏បានប្រគល់ប្រាក់ឱ្យឈ្មោះ [redacted] ប៊ុនវឿន ចំនួន ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក នេះសិន ។ ភ្លាមនោះឈ្មោះ [redacted] ប៊ុនវឿន បានឱ្យឈ្មោះ [redacted] ប៊ុនថេង ជាអ្នករាប់លុយ ។ នៅព្រឹកថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង ០៨ព្រឹក ឈ្មោះ [redacted] ប៊ុនវឿន បានឱ្យឈ្មោះ [redacted] ប៊ុនថេង និងឈ្មោះ [redacted] វុទ្ធី ទៅជួបតំណាងក្រុមហ៊ុននៅភោជនីយដ្ឋានមហាលាភបន្ទប់លេខ VIP៨



Scanned with CamScanner

ពេលនោះឈ្មោះ [redacted] ប៊ុនវឿន បានមកដល់ដែរ ហើយខាងតំណាងក្រុមហ៊ុនក៏បានប្រគល់ប្រាក់ចំនួន ៤៥.០០០ (សែសិបប្រាំពាន់) ដុល្លារអាមេរិក ទៅឈ្មោះ [redacted] ប៊ុនវឿន ហើយឈ្មោះ [redacted] ប៊ុនវឿន បានឱ្យលុយទៅឈ្មោះ [redacted] ថេង ជាអ្នករាប់ ។ ចំណែកឈ្មោះ [redacted] វុទ្ធី បានចេញទៅក្រៅបន្ទប់ ដើម្បីយាមទ្វារខាងក្រៅ ដោយបាននិយាយប្រាប់តំណាងក្រុមហ៊ុនថា កុំបារម្ភគាត់ជាអ្នកយាមផ្លូវឱ្យ ។ លុះដល់វេលាម៉ោង ០៩ និង ០០នាទីជាង ថ្ងៃខែឆ្នាំដដែល ប្រតិបត្តិការលើបទល្មើសជាក់ស្តែងបានធ្វើឡើងដោយឃាត់ខ្លួនជនទាំងបីនាក់ ១.ឈ្មោះ [redacted] ប៊ុនវឿន ២.ឈ្មោះ [redacted] វុទ្ធី និង ៣.ឈ្មោះ [redacted] ប៊ុនថេង មកសាកសួរ នៅអង្គភាពប្រឆាំងអំពើពុករលួយ តែម្តង ។

-តាមការស្រាវជ្រាវ និងការសារភាពរបស់ឈ្មោះ [redacted] ប៊ុនវឿន ចាប់តាំងពីឆ្នាំ២០១៦មក ឈ្មោះ [redacted] ប៊ុនវឿន បានយកសេវាក្រៅច្បាប់ចំនួន ១៤០ ករណី បានប្រាក់ ៣៧២.៧៤៧ (បីរយចិតសិបពីរពាន់ និងប្រាំពីររយសែសិបប្រាំពីរ) ដុល្លារអាមេរិក និងជាង ៤៩.០០០.០០០ (សែសិបប្រាំបួនលាន) រៀល នោះ មិនទាន់រាប់ករណីឈ្មោះ [redacted] ទី ដែលឈ្មោះ [redacted] ប៊ុនវឿន បានទទួលប្រាក់ចំនួន ២០.០០០ (ម្ភៃពាន់) ដុល្លារអាមេរិក ដូចពាក្យបណ្តឹងដែលអង្គភាពប្រឆាំងអំពើពុករលួយបានទទួលនោះផង ។ ចំពោះលុយចំនួន ១៧.៥២៩ (ដប់ប្រាំពីរពាន់ និងប្រាំរយម្ភៃប្រាំបួន) ដុល្លារអាមេរិក និង ១៦.២៥០.០០០ (ដប់ប្រាំមួយលាន និងពីររយហាសិបពាន់) រៀល ក្នុងនោះមានលុយដែលដាក់ក្នុងស្រោមសំបុត្រចំនួន ០៦ ស្រោមសំបុត្រ និងឯកសារមួយចំនួនត្រូវបានរកឃើញនៅក្នុងការិយាល័យរបស់ឈ្មោះ [redacted] ប៊ុនវឿន ហើយឈ្មោះ [redacted] ប៊ុនវឿន ទទួលស្គាល់ទៀតថា ជាលុយបានដោយខុសច្បាប់មួយចំនួន ហើយគាត់រក្សាទុកនៅការិយាល័យគឺដើម្បីលាក់ប្រពន្ធ ។ ជារួម ក្រោយពីទទួលតំណែងជាប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តពោធិ៍សាត់ពីឆ្នាំ២០១៦ មកដល់ថ្ងៃឃាត់ខ្លួន ឈ្មោះ [redacted] ប៊ុនវឿន បានប្រើប្រាស់ប្រាក់ដែលជាផលនៃបទល្មើសក្នុងការជួសជុលផ្ទះនៅភូមិមាន់ចៃចំនួន ៤០.០០០ (សែសិបពាន់) ដុល្លារអាមេរិក ទិញផ្ទះនៅបុរីប៉េងហួត (ប៉ុស្តិ៍វិទ្យុស្ទឹងមានជ័យ) តម្លៃ ១៦៨.០០០ (មួយរយហុកសិបប្រាំបីពាន់) ដុល្លារអាមេរិក ទិញផ្ទះនៅភូមិអូរជ្រិតតម្លៃ ៧២.០០០ (ចិតសិបពីរពាន់) ដុល្លារអាមេរិក ទិញដីស្ថិតនៅភូមិស្ពានថ្មតម្លៃ ៤៤.០០០ (សែសិបបួនពាន់) ដុល្លារអាមេរិក និងបានសាងសង់ផ្ទះត្រចៀកកាំនៅលើដីនេះ ចំណាយប្រាក់អស់ប្រហែល ៤០.០០០ (សែសិបពាន់) ដុល្លារអាមេរិក, ដូររថយន្តម៉ាក LEXUS ៥៧០ និងទិញរថយន្តម៉ាក KIA PICANTO ដើម្បីទុកដាក់ប្រាក់ពីផលបទល្មើសរបស់ខ្លួន ។

-**បានឃើញ** របាយការណ៍សំយោគលេខ ០១៤/១៩ រ.ប.ក.អ.ប.ព ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៣៤០៣ អ.យ.ទ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ៤៣៧៨ អ.យ.ទ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩ ។

-**បានឃើញ** ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ៥៨១០ “វ” ដ.ដ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩ ។

## នាពេលសវនាការ

១-ជនជាប់ចោទឈ្មោះ [redacted] ប៊ុនថេង ឆ្លើយថា៖ ខ្លួនពិតជាបានប្រព្រឹត្តដូចអង្គហេតុដែលបានចោទប្រកាន់ពិតមែន ។ ខ្លួនមានតួនាទីជាមន្ត្រីច្រកចេញចូលតែមួយនៅសាលាខេត្ត ទទួលបន្ទុកជាមន្ត្រីជួរក្រោយផ្នែកសំណង់របស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តពោធិ៍សាត់ បានរយៈពេលតែ ៣ ទៅ ៤ខែ ព្រោះខ្លួនទើបប្រឡងជាប់ជាមន្ត្រីក្នុងឆ្នាំ២០១៧ ហើយត្រូវធ្វើកម្មសិក្សាមួយឆ្នាំទៀត មុននឹងបញ្ជូនទៅធ្វើការនៅសាលាខេត្ត ។ នៅច្រកចេញចូលតែមួយ ខ្លួនមានតួនាទីទទួលប្រជាពលរដ្ឋមកប្រើប្រាស់សេវាមន្ទីរដូចជា ករណីប្រជាពលរដ្ឋមកសុំច្បាប់សាងសង់ អ្នកទទួលបន្ទុកច្រកសួរព័ត៌មាន ឬណែនាំអំពីឯកសារនានា ហើយខ្លួនបញ្ជូនទៅខាងមន្ទីរពិនិត្យ ។ ទោះស្នើសុំបាន ឬមិនបាន ឬមានការខ្វះខាតឯកសារណាមួយ ខ្លួននឹងប្រាប់ទៅប្រជាពលរដ្ឋតាមការណែនាំរបស់មន្ទីរ ។ ពេលប្រជាពលរដ្ឋមកស្នើសុំលិខិតអនុញ្ញាតសាងសង់ ខាងច្រកចេញចូលនឹងផ្តល់ពាក្យសុំ ហើយពន្យល់អំពីឯកសារចាំបាច់នានា ។ បើសិនប្រជាពលរដ្ឋ



Scanned with CamScanner

មានបំណងចង់ធ្វើប័ណ្ណដីធ្លី ខ្លួនពុំមានជំនាញនេះទេ កន្លងមកខ្លួនធ្លាប់ប្រាប់ប្រជាពលរដ្ឋឱ្យទៅបញ្ជាក់អត្តសញ្ញាណប័ណ្ណ និងទទួលប្លង់ដីពីប្រជាពលរដ្ឋដើម្បីយកទៅដាក់នៅមន្ទីរ ។ ក្រោយពេលបានបំពេញពាក្យស្នើរួច ប្រជាពលរដ្ឋត្រូវយកពាក្យស្នើសុំនោះឱ្យមន្ត្រីច្រក ហើយមន្ត្រីបានយកឯកសារនោះមកឱ្យខ្លួន បន្ទាប់មកខ្លួនយកទៅឱ្យលោកប្រធានច្រកចុះហត្ថលេខាបញ្ជូនឯកសារទៅមន្ទីរដើម្បីពិនិត្យ និងសម្រេច ។ ចំពោះការកំណត់សេវាឱ្យប្រជាពលរដ្ឋបង់ ខ្លួនមិនច្បាស់ថា ស្របតាមប្រកាសអន្តរក្រសួង ឬអត់នោះទេ ព្រោះខ្លួនទើបចូលបំរើការងារ ។

កន្លងមក ឈ្មោះ [redacted] វុទ្ធី បានអោយខ្លួនទាក់ទងតាមទូរស័ព្ទទៅក្រុមហ៊ុនដែលស្នើសុំលិខិតអនុញ្ញាតសាងសង់សំណង់សូឡា ក្រោយមកខ្លួនក៏បានទំនាក់ទំនងជាមួយក្រុមហ៊ុនចំនួនបីលើក៖

លើកទីមួយ នៅហាងកាហ្វេអាមាហ្សូនផ្លូវមុនីវង្ស ដោយតំណាងក្រុមហ៊ុនប្រាប់ថា ៖ "ចង់សាងសង់សូឡា" បន្ទាប់មកក្រុមហ៊ុនបានឱ្យឯកសារប្លង់មួយដែលគាត់គូរជាងកជនមួយសន្លឹកឱ្យខ្លួនមើល តែពុំទាន់មានប្លង់ដីទាំងអស់នៅឡើយ។ ក្រុមហ៊ុនក៏សួរខ្លួនពីតម្លៃតែខ្លួនបានប្រាប់ថា ខ្លួនមិនចេះគណនាទេចាំសួរប្រធានខ្លួនតែម្តងទៅ ។ បន្ទាប់ពីបានជួបតំណាងក្រុមហ៊ុនរួចហើយ ខ្លួនបានរាយការណ៍អោយទៅឈ្មោះ [redacted] វុទ្ធី និងលោកប្រធានឈ្មោះ [redacted] ប៊ុនរឿន ដែរ។

លើកទីពីរ មិនចាំថ្ងៃ ខ្លួនបានណាត់ក្រុមហ៊ុន និងលោកប្រធានជួបគ្នានៅកាហ្វេម្ភុំទួលគោក ដោយខ្លួនក៏ចូលរួមដែរព្រោះពួកគាត់មិនទាន់ស្គាល់គ្នា ។ ក្រុមហ៊ុនបានយកឯកសារជូនលោកប្រធានពិនិត្យ ហើយពេលពិនិត្យរួចគាត់ក៏ប្រាប់វិញថា នៅខ្វះប័ណ្ណដីមួយចំនួនទាល់តែឱ្យខាងជំនាញគេគណនាសិន រួចក៏បែកគ្នា ដោយពេលនោះ ខ្លួនក៏បានឱ្យក្រុមហ៊ុនយកលេខទូរស័ព្ទលោកប្រធានដើម្បីសួរនាំភ្លាមៗដោយពុំចាំបាច់សួរខ្លួនទៀតទេ ។

លើកទីបី នៅព្រឹកថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩ ខ្លួនបានណាត់តំណាងក្រុមហ៊ុនជួបជាមួយលោកប្រធាន ហើយឈ្មោះ [redacted] វុទ្ធី ក៏បានដឹងដែរព្រោះព្រឹកនោះ ខ្លួនជូនឈ្មោះ [redacted] វុទ្ធី ទៅយកឡាននៅកន្លែងជួសជុល ។ នាពេលតំណាងក្រុមហ៊ុនទូរស័ព្ទមកខ្លួន ឈ្មោះ [redacted] វុទ្ធី កំពុងនៅក្នុងឡានជាមួយខ្លួនទើបគាត់ស្តាប់ឮខ្លួននិយាយគ្នា ។ ពេលខ្លួននិយាយទូរស័ព្ទចប់ ឈ្មោះ [redacted] វុទ្ធី ក៏សួរនាំ ហើយខ្លួនប្រាប់ថា ក្រុមហ៊ុនសូឡាទាក់ទងមក ពេលនោះឈ្មោះ [redacted] វុទ្ធី ក៏ប្រាប់ថា លើកក្រោយប្រាប់តំណាងក្រុមហ៊ុនឱ្យច្បាស់កុំឱ្យម្តងអ្នកនេះម្តងអ្នកនោះ និងឱ្យក្រុមហ៊ុនបញ្ជាក់ថា គាត់ពិតជាបុគ្គលិកក្រុមហ៊ុន ឬអត់ ។ បន្ទាប់មកក៏មានតំណាងក្រុមហ៊ុនថ្មីជានារីពីរនាក់មកជួប ខ្លួនក៏នាំពួកគេទៅជួបលោកប្រធានក្នុងបន្ទប់នៅមន្ទីរខេត្តពោធិ៍សាត់តែម្តង ចំណែកឈ្មោះ [redacted] វុទ្ធី ពុំបានចូលរួមទេ ដោយក្រុមហ៊ុនបានស្នើរឱ្យលោកប្រធានគិតតម្លៃ លោកប្រធានក៏ប្រាប់ឱ្យខ្លួនធ្វើការគណនា បន្ទាប់ពីគណនាឃើញថា អស់ចំនួន ៧៥.០០០ ដុល្លារអាមេរិក លោកប្រធានក៏ប្រាប់ថា អស់ចំនួន ១០០.០០០ ដុល្លារអាមេរិក រួមទាំងសេវា។ ខ្លួនពុំដឹងថា ការគណនានេះលោកប្រធានយកមូលដ្ឋានអ្វីនោះទេ ព្រោះខ្លួនគ្រាន់តែជួយចុចម៉ាស៊ីនគិតលេខឱ្យគាត់ប៉ុណ្ណោះ ។ ខ្លួនពុំដឹងថា តម្លៃខាងលើនេះលើសពីតម្លៃដែលច្បាប់កំណត់ឡើយ ហើយខ្លួនពុំចាំថា ក្រុមហ៊ុននិយាយយ៉ាងម៉េចខ្លះពាក់ព័ន្ធទៅនឹងតម្លៃនេះទេ ដោយគ្រាន់តែដឹងថា ចុងក្រោយឯកភាពគ្នាលើតម្លៃ ១០០.០០០ ដុល្លារអាមេរិក ហើយក្រុមហ៊ុនបានប្រគល់លុយចំនួន ៥.០០០ ដុល្លារអាមេរិក ជូនលោកប្រធាន ដោយខាងក្រុមហ៊ុននិយាយថា ជាប់លុយមកតែប៉ុន្នឹង ឬក៏ជាលុយកក់ ខ្លួនមិនច្បាស់ទេ បន្ទាប់មកលោកប្រធានឱ្យខ្លួនរាប់លុយនោះ ។ ពេលរាប់រួច ខ្លួនក៏ប្រគល់ប្រាក់ឱ្យលោកប្រធានវិញទាំងអស់ ។ ចំណែកឈ្មោះ [redacted] វុទ្ធី ពុំនៅក្នុងបន្ទប់ទេ តែគាត់បានដឹងថា តំណាងក្រុមហ៊ុនមកមន្ទីរជួបលោកប្រធានដែរ ។ ខ្លួនពុំដឹងថា ការគណនាប្រាក់ចំនួន ១០០.០០០ ដុល្លារអាមេរិក នេះ ឈ្មោះ [redacted] វុទ្ធី បានដឹង ឬអត់ទេ តែពេលខ្លួនចេញមកវិញ ឈ្មោះ [redacted] វុទ្ធី បានសួរខ្លួនហើយខ្លួនក៏ប្រាប់គាត់តាមហ្នឹង ។ រហូតដល់ពេលថ្ងៃត្រង់ ខ្លួនក៏ហូបបាយជជែកគ្នាលេងធម្មតាជាមួយឈ្មោះ [redacted] វុទ្ធី និងខាងក្រុមហ៊ុនតែលោកប្រធានមិនបានចូលរួមទេ ។ លុះល្ងាចឡើង ខ្លួនទៅហូបបាយ និងជជែកលេងជាមួយឈ្មោះ [redacted] វុទ្ធី និងតំណាងក្រុមហ៊ុនម្តងទៀត ដោយក្រុមហ៊ុនព្យាយាមសួរខ្លួនដដែលៗពីរឿងសូឡា តែខ្លួនឆ្លើយថា



Scanned with CamScanner

អត់មឹងទេ ។

ទាក់ទងនឹងការស្នើសុំលិខិតអនុញ្ញាតសាងសង់សូឡានេះ  ក៏ជាការងារច្រកចេញចូលតែមួយដែលខ្លួនត្រូវប្រាប់អំពីតម្លៃសេវាដែរ  តែដោយសារជាករណីពិសេសពុំមានក្នុងតារាងតម្លៃទើបខ្លួនជូនលោកប្រធានដើម្បីសម្រេច ។ ចំពោះការស្នើសុំលិខិតអនុញ្ញាតសាងសង់ផ្ទះល្វែងត្រូវបង់តាមតារាងមានស្រាប់  នៅកន្លែងគណនេយ្យដោយមានចេញជាវិក័យប័ត្រត្រឹមត្រូវ ។

នៅព្រឹកថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៩ នៅពេលដែលខ្លួនជូនឈ្មោះ [redacted] វុទ្ធី ទៅយកឡានរបស់គាត់នៅកន្លែងជាងជួសជុល លោកប្រធានឈ្មោះ [redacted] ប៊ុនរឿន ក៏ទូរស័ព្ទមកខ្លួនឱ្យណាត់តំណាងក្រុមហ៊ុនជួបនៅភោជនីយដ្ឋានមហា លាភ និងឱ្យខ្លួនទៅចាំគាត់មុន ។ បន្ទាប់មក ខ្លួនជាមួយឈ្មោះ [redacted] វុទ្ធី ក៏ទៅដល់បន្ទប់វីអ៊ី ភោជនីយដ្ឋានមហាលាភ ហើយឃើញតំណាងក្រុមហ៊ុនអង្គុយចាំស្រាប់ ។ រយៈពេលប្រហែលជា ១០ ទៅ ១៥ នាទី ក្រោយ លោកប្រធានក៏មកដល់ ហើយបន្ទាប់មកពួកគាត់និយាយអ្វីខ្លះខ្លួនពុំចាំទេ  តែអត្ថន័យពាក់ព័ន្ធនឹងការងារស្នើសុំលិខិតអនុញ្ញាតសាងសង់សំណង់សូឡា ។ បន្ទាប់មកទៀត តំណាងក្រុមហ៊ុនក៏បានប្រគល់ប្រាក់ឱ្យលោកប្រធានបន្ថែមចំនួន ៤៥.០០០ ដុល្លារអាមេរិក ទៀត ហើយលោកប្រធានក៏ឱ្យខ្លួនរាប់លុយ និងរកថង់ខ្មៅដើម្បីច្រក ។ ខ្លួនក៏រាប់លុយ និងច្រកទុកក្នុងខ្មៅ ហើយប្រគល់ឱ្យលោកប្រធានវិញស្រាប់តែអង្គភាពប្រឆាំងអំពើពុករលួយមកដល់ តែម្តង ។ នាពេលលោកប្រធានទទួលប្រាក់ពីក្រុមហ៊ុនពុំមានចេញវិក័យប័ត្រទេ ។ នាពេលខ្លួនរាប់លុយ ឈ្មោះ [redacted] វុទ្ធី បាននិយាយថា៖ “គាត់ទៅយាមទ្វារ” ហើយគាត់ក៏ចេញបាត់ទៅ ។

កន្លងមក  ខ្លួនធ្លាប់ទទួលសេវាប្រជាពលរដ្ឋពឹងឱ្យខ្លួនគូរប្លង់  ខ្លួនក៏ទទួលគូសដោយយកកម្រៃជាឯកជនពុំពាក់ព័ន្ធនឹងការងារជាមន្ត្រីច្រកនោះទេ ។ មូលហេតុដែលខ្លួននាំតំណាងក្រុមហ៊ុនទៅជួបលោកប្រធានដោយសារឈ្មោះ ជាង វុទ្ធី ផ្តាំផ្ញើរ ហើយខ្លួនគិតថា បើក្រុមហ៊ុនឯកភាពលោកប្រធានអាចនឹងឱ្យខ្លួនជួយគូសប្លង់ ។ ម្យ៉ាង ខ្លួនក៏ចង់រៀនសូត្រលើការមើលតារាង និងចង់បង្ហាញឱ្យឃើញថា ខ្លួនសកម្មក្នុងការងារនេះ ។ ខ្លួនពិតជាមន្ត្រីរាជការដែលត្រូវបានតែងតាំងដោយប្រកាសរបស់ក្រសួង ការផ្តល់សេវានៅច្រកចេញចូល ជាសេវាទូទៅទាក់ទឹងនឹងការស្នើសុំលិខិតអនុញ្ញាតសាងសង់ ហើយសេវាដែលក្រុមហ៊ុនស្នើសុំគឺស្នើសុំលិខិតអនុញ្ញាតសាងសង់សំណង់  ។  កន្លងមកបើប្រជាពលរដ្ឋស្នើសុំការអនុញ្ញាតសាងសង់ អ្នកស្នើសុំត្រូវទៅសាលាឃុំខ្លួនឯងដើម្បីអោយសាលាឃុំធ្វើលិខិតបញ្ជាក់ បន្ទាប់មកយកមកឱ្យច្រកចេញចូលវិញ រួចទើបបញ្ជូនទៅសាលាក្រុង និងទៅមន្ទីរបន្តទៀត ។ កន្លងមក ខ្លួនទទួលសេវាជាកញ្ចប់ពីប្រជាពលរដ្ឋ ហើយខ្លួនយកទៅចំណាយលើសេវាទាំងអស់បូករួមទាំងថ្លៃគូសប្លង់  ដែលតម្លៃកញ្ចប់នេះលោកប្រធានជាអ្នកកំណត់ ។ ចំពោះផ្ទះល្វែងគិតតាមទំហំប្រហែលពី ៣៥០ ដុល្លារអាមេរិក ទៅ ៤៥០ ដុល្លារអាមេរិក ។ ចំពោះសេវាកញ្ចប់នេះ ខ្លួនទទួលបានតែថ្លៃគូសប្លង់ប៉ុណ្ណោះ  ហើយថ្លៃគូសប្លង់នេះក៏ត្រូវចំណាយថ្លៃព្រីនទៀត ខ្លួននៅសល់ជាក់ស្តែង ពី ៥០ ដុល្លារអាមេរិក ទៅ ១០០ ដុល្លារអាមេរិក ប៉ុណ្ណោះ ។ ការគូសប្លង់នេះ ខ្លួនពុំបានចេញវិក័យប័ត្រឱ្យប្រជាពលរដ្ឋទេ ។ ពាក្យថា “រត់ការ” តាមខ្លួនយល់គឺខ្លួនត្រូវទៅសាលាឃុំ និងសាលាខេត្តជំនួសគេ តែខ្លួនពុំបានធ្វើបែបនេះទេ  ហើយក៏ពុំបានប្រើមន្ត្រីណាឱ្យធ្វើបែបនេះដែរ  ។  ខ្លួនយល់ឃើញថា អំពើរបស់ខ្លួនពុំមែនជាអំពើពុករលួយទេ ព្រោះការគូសប្លង់ត្រូវគិតថ្លៃសម្ភារៈ និងពលកម្ម ហើយខ្លួនគូសប្លង់នៅផ្ទះពេលយប់ ។

ចំពោះការគូសប្លង់ផ្ទះល្វែងមួយ ខ្លួនយកតម្លៃ ១០០ ដុល្លារអាមេរិក តម្លៃសេវាអាជ្ញាប័ណ្ណបង់ចូលរដ្ឋចំនួន ៤៤ ម៉ឺនរៀល ៨៨ ម៉ឺនរៀល ឬមានដល់ជាង ១លានរៀល ក៏មាន ។ ខ្លួនសូមបញ្ជាក់ថា គោលបំណងនៃការបង្កើតច្រកចេញចូលតែមួយគឺដើម្បីជួយសម្រួលដល់ប្រជាពលរដ្ឋឱ្យទៅតែមួយកន្លែង  ដោយតម្រូវឱ្យគាត់យកឯកសារមកដាក់  និងយកនៅកន្លែងតែមួយ  ។  កន្លងមកប្រជាពលរដ្ឋត្រូវទៅច្រើនកន្លែង  ទើបមានការយកសេវាកញ្ចប់ដើម្បីរត់ការទៅសាលាឃុំ



Scanned with CamScanner

ហើយពេលបង្កើតឱ្យមានច្រកចេញចូលតែមួយរួចគឺពុំមានយកសេវាទៀតទេ គឺគេយកសេវាថ្លៃពលកម្មគូសប្លង់វិញ ។ ខ្លួនទើបតែចូលធ្វើការនៅច្រកចេញចូលតែមួយ ហើយច្រកនេះទើបតែបង្កើតឡើងអត់ទាន់មានច្បាប់សម្រាប់ចាត់ចែងច្បាស់លាស់ទេ ទើបមានការអ្វីត្រូវមកសួរប្រធាន ។ សេវាដែលតំណាងក្រុមហ៊ុនបានបង់ជូនលោកប្រធាន ខ្លួនពុំដឹងថាជាសេវាខុសច្បាប់ទេ ហើយក៏ខ្លួនមិនដឹងថា សេវាទំហំប៉ុណ្ណាស្ថិតក្រោមសមត្ថកិច្ចមន្ទីរ និងសេវាប៉ុណ្ណាស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងឡើយ ។ ចំពោះតម្លៃសេវា ១០០.០០០ ដុល្លារអាមេរិក សម្រាប់សង់សូឡានេះ លោកប្រធានជាអ្នកគិតទើបខ្លួនពុំហ៊ានសួរទេ ចំពោះការយកប្រាក់នេះបើតាមខ្លួនយល់គឺអត់ខុសទេ ព្រោះខ្លួនពុំបានយកសិទ្ធិអំណាចខ្លួនទៅហាមថា បើមិនឱ្យប្រាក់ខ្លួនអត់ធ្វើឱ្យនោះទេ ឬក៏ប្រាក់ប៉ុន្នេះមកទើបធ្វើឱ្យ ឬក៏បង្ខំឱ្យគេយកអោយខ្លួនគូសប្លង់ឱ្យក៏អត់ដែរ សកម្មភាពខ្លួនដែលជួយក្រុមហ៊ុនដើម្បីទទួលបានឱកាសក្នុងការគូសប្លង់ខ្លួនយល់ថា ខ្លួនអត់បានឆ្លៀតឱកាសអីធំដុំទេ ហើយខ្លួនក៏ពុំបានសុំតំណាងក្រុមហ៊ុនគូសដែរ ។ ខ្លួនគ្រាន់តែប្រាប់តំណាងក្រុមហ៊ុនថា ខ្លួនចេះគូសប្លង់ ហើយគាត់អាចពឹងខ្លួនឱ្យគូសបាន ។ ក្នុងចំនួនទឹកប្រាក់ ១០០.០០០ ដុល្លារអាមេរិក ខ្លួនមិនទាន់បានទទួលចំណែកនៅឡើយទេ ព្រោះខ្លួនមិនទាន់បានគូសប្លង់នៅឡើយ ។ ពេលលោកប្រធានឱ្យខ្លួនជួយគូសប្លង់គាត់ គាត់ឱ្យប៉ុន្មានស្រេចតែលើលោកប្រធាន ហើយជានិច្ចកាលគាត់ឱ្យតម្លៃដូចគេឯងដែរ ។ ការណ៍ដែលលោកប្រធានបានទទួលសេវា ៥០.០០០ ដុល្លារអាមេរិក ខ្លួនពុំដឹងថា ជាអំពើខុសច្បាប់ ឬយ៉ាងណាទេ តែខ្លួនធ្លាប់ធ្វើការឯកជនវិញទឹកលុយសរុបដល់ទៅ ១០០.០០០ ដុល្លារអាមេរិក ត្រូវបង់លុយមុនខ្លះហើយ ។ បើអត់យកលុយមុនខ្លះទេគឺត្រូវចេញលុយខ្លួនឯងបង់ ហើយខាងក្រុមហ៊ុនក៏ឯកភាពដែរអត់មានខុសទេ ។ ចំណែកឯប្រជាពលរដ្ឋដាក់ឯកសារស្នើសុំការអនុញ្ញាតសាងសង់ ខ្លួនពុំដែលបង្ខំថា ទាល់តែអោយខ្លួនគូសប្លង់នោះទេ ហើយខ្លួនក៏ពុំបានទាមទារតំណាងក្រុមហ៊ុនឱ្យទុកចំណែកឱ្យខ្លួនដែរ ។

មុនពេលខ្លួនជួបតំណាងក្រុមហ៊ុនលើកទី១ ក្រុមហ៊ុនមិនទាន់បានដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់នៅឡើយ ។ ពេលជួបលើកទី២ និងរហូតដល់ថ្ងៃឃាត់ខ្លួន ក្រុមហ៊ុនក៏មិនទាន់បានដាក់ពាក្យស្នើសុំដែរព្រោះមិនទាន់មានប័ណ្ណ ដី ។ ការរាំងស្ទះក្នុងការធ្វើប្លង់ដីគិតពីពេលជួបតំណាងក្រុមហ៊ុនលើកទី១ រហូតដល់ពេលឃាត់ខ្លួនប្រហែលជា ២ ទៅ ៣ ខែ ក្រុមហ៊ុនក៏បានដឹងដែរថា មកពីក្រុមហ៊ុនមិនទាន់មានប្លង់ដី ហើយខាងក្រុមហ៊ុនក៏មិនទាន់បានដាក់ពាក្យសុំធ្វើប្លង់ដែរ គឺទៅជួបលោកប្រធានតែម្តង ។

ឈ្មោះ [redacted] វុទ្ធី ពុំដែលបានប្រាប់ខ្លួនឱ្យទាក់ទងទៅលេខទូរស័ព្ទក្រុមហ៊ុនដើម្បីបានទទួលផលប្រយោជន៍ដែរ ឬពេលបានលុយត្រូវអោយគាត់នោះទេ ដោយកន្លងមកខ្លួនធ្លាប់ឆ្លើយនៅអង្គភាពថា ខ្លួនបានប្រាប់ទៅឈ្មោះ [redacted] វុទ្ធី ថា ការសាងសង់រោងចក្រសូឡាត្រូវចំណាយអស់ ១០០.០០០ ដុល្លារអាមេរិក ហើយឈ្មោះ [redacted] វុទ្ធី បាននិយាយថាថ្លៃណាស់ ។ ឈ្មោះ [redacted] វុទ្ធី ជាមនុស្សឧស្សាហ៍និយាយច្រើន ហើយចំពោះពាក្យរបស់ឈ្មោះ [redacted] វុទ្ធី ថា ចេញទៅយាមទ្វារ ខ្លួនពុំដឹងថា គាត់និយាយមែន ឬនិយាយលេងនោះទេ ។

២-ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី ឆ្លើយថា៖ ខ្លួនជាមន្ត្រីរាជការសាធារណៈតាំងពីឆ្នាំ ២០០០ ហើយចូលមកកាន់តួនាទីជាអនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តពោធិ៍សាត់ ប្រហែលជាក្នុងឆ្នាំ ២០០៨ ។ ដំបូង ខ្លួនទទួលបន្ទុកការងាររៀបចំដែនដី លុះពេលលោក [redacted] ប៊ុនរឿន មកកាន់ជាប្រធានមន្ទីរ ខ្លួនទទួលបន្ទុកការងារសំណង់ និងការងារប្រជុំនានា ។ ក្រៅពីនេះ ខ្លួនមានតួនាទីត្រួតពិនិត្យប្លង់ស្ថាបត្យកម្ម គម្លាតអាគារទៅអ័ក្សផ្លូវ និងគម្លាតសងខាងនៃព្រំដី ។ ពាក់ព័ន្ធនឹងក្រុមហ៊ុនដែលស្នើសុំសាងសង់សូឡា ខ្លួនពុំទាន់បានទទួល ឬឆ្លងឯកសារអ្វីទាំងអស់ ហើយក៏ពុំស្គាល់ក្រុមហ៊ុនដែរ ។ កន្លងមកមានជាងថតរូបម្នាក់ទំនាក់ទំនងមកខ្លួន តែមិនមែនជាក្រុមហ៊ុនទេ ខ្លួនក៏ប្រាប់លេខទូរស័ព្ទរបស់ឈ្មោះ [redacted] ប៊ុនថេង ។ ការចុះបញ្ជីដីធ្លី គេពុំដែលទំនាក់ទំនងមកខ្លួនទេ ហើយខ្លួនក៏ពុំទទួលបន្ទុកដែរ ។ បើគេមកជួប ខ្លួនឱ្យគេទាក់ទងជាមួយលោកប្រធាន ឬអនុប្រធានទទួលបន្ទុក ដោយពួកគាត់អាចណែនាំពីឯកសារ



Scanned with CamScanner

ដែលត្រូវភ្ជាប់ និងត្រូវធ្វើបែបណាខ្លះ ។ ខ្លួនពុំដែលបានជួបខាងក្រុមហ៊ុនសោះ ចំពោះឈ្មោះ [redacted] ប៊ុនថេង បានជួបតំណាងក្រុមហ៊ុនប៉ុន្មានដងខ្លួនពុំដឹងទេ ខ្លួនទើបជួបម្តងនៅថ្ងៃដែលគេឃាត់ខ្លួន។ ខ្លួនពុំបានដឹងថា ក្រុមហ៊ុនដែលទៅជួបនឹងឈ្មោះ [redacted] ប៊ុនរឿន និងឈ្មោះ[redacted]ប៊ុនថេង ចំណាយសេវាប៉ុន្មានទេ ។ ខ្លួនគ្រាន់តែដឹងថា នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩ តំណាងក្រុមហ៊ុនបានមកជួបលោកប្រធានរឿងសុំសាងសង់សូឡា ដោយសារខ្លួនជិះឡានជាមួយឈ្មោះ[redacted]ប៊ុនថេង ទៅមន្ទីរ ហើយខាងក្រុមហ៊ុនជិះតាមក្រោយ ។ បន្ទាប់មកនៅពេលថ្ងៃត្រង់ ខ្លួន និងឈ្មោះ[redacted] ប៊ុនថេង បានទៅហូបបាយជាមួយតំណាងក្រុមហ៊ុនព្រោះខ្លួនអត់មានឡានជិះ ។ ខ្លួនបានសួរឈ្មោះ[redacted] ប៊ុនថេង ហើយគាត់ប្រាប់ថា ក្រុមហ៊ុនមកសុំច្បាប់សាងសង់សូឡា ហើយបានប្រគល់លុយចំនួន ៥.០០០ ដុល្លារអាមេរិក និងបានប្រាប់ពីទំហំនៃការចំណាយសរុប តែការចំណាយនោះបង់លើសេវាអីខ្លះខ្លួនអត់ដឹងទេ ។ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៩ ខ្លួនទៅកន្លែងកើតហេតុ ដោយសារឈ្មោះ [redacted] ប៊ុនថេង មកយកខ្លួនទៅយកឡាន ហើយចូលហូបគុយទាវ ។ ខ្លួនទៅដល់មុនប្រធានមន្ទីរ ហើយនាំគ្នាហូបគុយទាវ ។ បន្តិចក្រោយមក ខ្លួនឃើញក្រុមហ៊ុនយកលិខិតឱ្យលោកប្រធានចុះហត្ថលេខា ហើយគាត់ក៏រាប់លុយជាមួយឈ្មោះ[redacted] ប៊ុនថេង ។ ពេលនោះ ខ្លួនចង់ចេញទៅក្រៅដក់បារី ហើយចង់គិតលុយឱ្យហើយដែរ ព្រោះត្រូវប្រញាប់ទៅយកឡាន តែតំណាងក្រុមហ៊ុនឃាត់មិនឱ្យទៅណាទើបខ្លួនជ្រុលមាត់និយាយលេងថា៖ "អត់អីទេ ខ្លួនទៅក្រៅមើលផ្លូវចុះ" បន្ទាប់មកខ្លួនក៏ចេញទៅគិតលុយ និងជក់បារីនៅខាងក្រៅ ។ នៅពេលដែលខ្លួនចេញពីបន្ទប់ ក្រុមហ៊ុនពុំទាន់ដកប្រាក់ប្រគល់ជូនលោកប្រធានទេ ខ្លួនគ្រាន់តែបានឃើញគេហុច ក្រដាសដែលបញ្ជាក់ថា ក្រុមហ៊ុនបានមកទំនាក់ទំនងជាមួយមន្ទីរឱ្យលោកប្រធានចុះហត្ថលេខា ហើយខ្លួនពុំឃើញលុយច្បាស់ទេ ។ បន្ទាប់មកទៀត តំណាងក្រុមហ៊ុនបានហៅខ្លួនឱ្យចូលមកវិញថា៖ "ពួហើយៗ" ខ្លួនក៏ចូលមកយកទូរស័ព្ទរបស់ខ្លួនមួយនៅលើតុក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។ ចំនួនទឹកលុយដែលរាប់នោះ ខ្លួនពុំដឹងច្បាស់ទេ តែខ្លួន ឮឈ្មោះ [redacted] ប៊ុនថេង ថា គេបានកក់ប្រាក់ ៥.០០០ ដុល្លារអាមេរិក ហើយនៅថ្ងៃទី២៧ ត្រូវប្រគល់ថែម ៤៥.០០០ ដុល្លារអាមេរិកទៀត ។ ខ្លួនពុំដឹងថា លុយនេះជាលុយអ្វីទេ ហើយខ្លួនគិតថា ជាសេវារដ្ឋ តែខ្លួនពុំបានទទួលកម្រៃពីប្រាក់នេះទេ ។ ក្រៅពីតួនាទីជាអនុប្រធានមន្ទីរ ខ្លួនទទួលធ្វើសំណង់ដែលមានក្រុមហ៊ុនឈ្មោះ [redacted] ចិន្តា ដែលមានប្រពន្ធ របស់ខ្លួនជាប្រធានក្រុមហ៊ុន។ កន្លងមកក្នុងការដេញថ្លៃសំណង់រដ្ឋមានក្រុមហ៊ុនជាច្រើនចូលរួមពុំមែនមានតែក្រុមហ៊ុនរបស់ខ្លួននោះទេ ហើយក្រុមហ៊ុនខ្លួនក៏ធ្លាប់ទទួលបានការងារដេញថ្លៃដែរ ។ នៅក្នុងក្រុមហ៊ុនសំណង់ ខ្លួនពុំមានឋានៈអ្វីទេ ហើយតាំងពីឆ្នាំ២០១៥ ក្រុមហ៊ុនសំណង់ប្រពន្ធខ្លួនទទួលបានគំរោងដេញថ្លៃដូចជា៖ មន្ទីរសុខាភិបាល មន្ទីរអប់រំ មន្ទីរទំនាក់ទំនងសភា មន្ទីរហិរញ្ញវត្ថុ មន្ទីរព័ត៌មាន និងរតនាគារ នៅក្នុងខេត្តពោធិ៍សាត់ ។ នីតិវិធីដេញថ្លៃគឺបុគ្គលិកក្រុមហ៊ុនជាវិស្វករចូលរួមដេញថ្លៃ ខ្លួនពុំបានចូលរួមដេញថ្លៃទេ ។ ខ្លួនដឹងថាក្រុមហ៊ុនប្រពន្ធខ្លួនដេញថ្លៃបានគំរោងខាងលើ ដោយសារនៅថ្ងៃសៅរ៍ និងអាទិត្យ ខ្លួនជួយមើលការងារប្រពន្ធដោយបានចូលរួមពិនិត្យការងារជាង និងការងារគំរោងខ្លះៗ ។ ចំពោះគម្រោងនៅមន្ទីររៀបចំដែនដី តំណាងក្រុមហ៊ុនឈ្មោះ ភក្តី ជាអ្នកចូលរួមដេញថ្លៃដំបូងគេ ។ ការដេញថ្លៃនៅមន្ទីរដែនដី ខ្លួនពុំចាំថា ដេញបានក្នុងតម្លៃប៉ុន្មានទេ ហើយការប្រគល់ទទួលប្រាក់ថ្លៃសាងសង់ក៏រួចរាល់អស់ដែរ ។ ពេលប្រពន្ធខ្លួនដេញបាន ខ្លួនយកលុយឱ្យប្រធានមន្ទីរ ប៉ុន្តែចំពោះក្រុមហ៊ុនផ្សេងៗដេញបាន ខ្លួនមិនដឹងទេ ។ ខ្លួនយកលុយឱ្យប្រធានមន្ទីរដោយសារនៅតាមមន្ទីរមានការងារច្រើន ហើយខ្លួនក៏ត្រូវជួយគាត់ ។ ក្នុងពេលដេញថ្លៃបាន ក្រុមហ៊ុនរបស់ប្រពន្ធខ្លួនទទួលបានប្រាក់តែ ៥០ភាគរយ នៃប្រាក់គម្រោងប៉ុណ្ណោះ ព្រោះត្រូវចំណាយសេវា ច្រើនដូចជា៖ សេវាហិរញ្ញវត្ថុ និងសេវាក្រោមតុផ្សេងៗ ដើម្បីបានគម្រោងមកធ្វើត្រូវដក ៥ ភាគរយឱ្យប្រធានមន្ទីរលោក [redacted] ប៊ុនរឿន និងមន្ទីរចំនួន ១០ ភាគរយ ។ ខ្លួនពុំបានជួយឈ្មោះ [redacted] ប៊ុនថេង រៀបចំឯកសារ ឬលិខិតផ្សេងៗ សម្រាប់ក្រុមហ៊ុនសាងសង់សូឡាទេ គ្រាន់តែគាត់កាន់លិខិតមួយដែលខាងក្រុមហ៊ុនស្នើសុំឱ្យលោកប្រធាន



Scanned with CamScanner

បញ្ជាក់ថា ក្រុមហ៊ុនបានមកទំនាក់ទំនងការងារជាមួយឱ្យខ្លួនជួយពិនិត្យ ។ លិខិតនោះ ក្រុមហ៊ុនស្នើសុំលោកប្រធាន ហើយលោកប្រធានឱ្យឈ្មោះ [redacted] ប៊ុនថេង ធ្វើទើបឈ្មោះ [redacted] ប៊ុនថេង យកមកឱ្យខ្លួនជួយកែ ។ លិខិតនេះឈ្មោះ [redacted] ប៊ុនថេង យកទៅឱ្យតំណាងក្រុមហ៊ុននៅពេលល្ងាច ហើយដោយសារខ្លួនពុំមានរថយន្តធ្វើដំណើរ ឈ្មោះ [redacted] ប៊ុនថេង និងខ្លួនក៏ទៅពិសារអាហារពេលល្ងាចជាមួយតំណាងក្រុមហ៊ុន រហូតដល់ម៉ោងប្រហែល ៨ កន្លះយប់ ទើបបែកគ្នាទៅផ្ទះរៀងខ្លួន ។

នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៩ ត្រូវនឹងថ្ងៃសៅរ៍ ជាថ្ងៃជួបគ្នានិយាយពីសេវាស្នើសុំការអនុញ្ញាតសាងសង់សូឡា ក៏មានការប្រគល់លុយរវាងតំណាងក្រុមហ៊ុន និងលោកប្រធានមន្ទីរ ហើយខ្លួន និងឈ្មោះ [redacted] ប៊ុនថេង ក៏មានវត្តមាននៅទីនោះផងដែរ ។ ការប្រគល់លុយនៅថ្ងៃសៅរ៍ នៅក្រៅស្ថាប័នខ្លួនពុំដឹងថា ត្រូវច្បាប់ ឬខុសច្បាប់ឡើយព្រោះខ្លួនពុំចេះច្បាប់ ។ ការប្រគល់លុយពុំមានចេញវិក័យប័ត្រជូនតំណាងក្រុមហ៊ុនទេ ហើយជាធម្មតាការប្រគល់ទទួលប្រាក់ដោយពុំចេញវិក័យប័ត្រខ្លួនពុំដឹងថា ត្រូវច្បាប់ ឬអត់នោះទេ ។ ខ្លួនពុំបានទទួលផលប្រយោជន៍អ្វីពីប្រាក់ចំនួន ១០០.០០០ ដុល្លារអាមេរិកនេះទេ ។ ខ្លួនទទួលយកបទចោទប្រកាន់លើខ្លួន បទវិតិក្រម និងរំលោភអំណាច និងទទួលយកចម្លើយដែលខ្លួនបានឆ្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ ដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរទាំងអស់ ។

៣-ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនរឿន** ឆ្លើយថា ៖ ខ្លួនពិតជាបានប្រព្រឹត្តដូចអង្គហេតុនៃការចោទប្រកាន់មែន ។ ខ្លួនទទួលស្គាល់ចម្លើយដែលខ្លួនបានឆ្លើយនៅនគរបាលយុត្តិធម៌ ។ ខ្លួនធ្វើជាមន្ត្រីរាជការសាធារណៈតាំងពីឆ្នាំ១៩៩៨ ហើយបានបំពេញមុខងារជាប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តពោធិ៍សាត់ នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ ដោយមានអនុប្រធាន ៣នាក់ មានឈ្មោះ [redacted] សុផា ទទួលបន្ទុកកិច្ចការសុរិយោដី លោក [redacted] វុទ្ធី ទទួលបន្ទុកកិច្ចការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ លោក [redacted] ទិត្យ ទទួលបន្ទុកកិច្ចការលំនៅដ្ឋាន ។ ក្នុងនាមជាប្រធាន ខ្លួនបានរៀបចំរចនាសម្ព័ន្ធ បទបញ្ជាផ្ទៃក្នុង និងបែងចែងភារកិច្ចជូនអនុប្រធានមន្ទីរដាច់ៗគ្នា តែម្តង ។ ពាក់ព័ន្ធនឹងច្រកចេញចូលតែមួយ តាមប្រកាសរបស់ក្រសួងតម្រូវឱ្យបង្កើតយូរហើយ តែប្រធានមន្ទីរចាស់មិនបានរៀបចំ ។ ពេលចូលកាន់តំណែង ខ្លួនក៏រៀបចំអោយមានច្រកចេញចូលតែមួយនេះនៅក្នុងឆ្នាំ២០១៩ ។ ក្រោយពីមានអនុក្រឹត្យលេខ ១៨ ស្តីពីការប្រគល់ភារកិច្ចច្រកចេញចូលតែមួយឱ្យសាលាខេត្ត ខ្លួនក៏ប្រគល់ឱ្យសាលាខេត្តអស់ហើយ ពុំទទួលសេវានៅមន្ទីរទេ ។ ឈ្មោះ [redacted] ប៊ុនថេង ជាមន្ត្រីទើបចូលបំពេញការងារ ហើយដោយសារតែការខ្វះខាតមន្ត្រីនៅការិយាល័យសំណង់ ខ្លួនក៏បានចាត់គាត់អោយទៅទទួលបន្ទុកនៅច្រកចេញចូលតែមួយនៅសាលាខេត្តជាមន្ត្រីជួរក្រោយ ដើម្បីពិនិត្យឯកសារដែលប្រជាពលរដ្ឋដាក់ពាក្យស្នើសុំដើម្បីយកឯកសារទាំងនោះមកខាងមន្ទីរដើម្បីចរន្តការ ។ ទម្រង់ពាក្យសុំ ខាងក្រសួងបញ្ជូនមកអោយប្រើ ហើយកម្រងសេវាគឺអនុវត្តទៅតាមប្រកាសអន្តរក្រសួងដោយមានចែងច្បាស់ថា តំបន់ណាត្រូវបង់ប៉ុន្មាន ។ ខ្លួនបានប្រជុំ និងចែកជូននូវតារាងនេះដល់ឈ្មោះ [redacted] ប៊ុនថេង តែមិនដឹងថា ឈ្មោះ [redacted] ប៊ុនថេង បានពិនិត្យ ឬអត់នោះទេ ។ ខ្លួនក៏បានឱ្យព្រីនជាប៉ាណូធំបិទនៅជញ្ជាំង និងចម្លងជូនឱ្យច្រកដែរ ។ ចំពោះការចំណាយរបស់ប្រជាពលរដ្ឋក្នុងការស្នើសុំគឺមាននៅក្នុងតារាងស្រាប់ ហើយមន្ត្រីច្រកអាចប្រាប់ទៅប្រជាពលរដ្ឋបានដូចជា ផ្ទះល្វែងមួយមានទំហំប៉ុន្មាន កំពស់ប៉ុន្មានជាន់ សេវាប៉ុន្មានគឺមានក្នុងតារាងសេវាស្រាប់ ។ ពេលប្រជាពលរដ្ឋបង់សេវាជូនរដ្ឋភាគច្រើន មន្ត្រីច្រកមិនជូនដំណឹងខ្លួនទេ ព្រោះគណនេយ្យគាត់ទទួលទៅតាមតារាងដែលមានស្រាប់ ។ ពាក្យថា "រត់ការ" គឺកន្លងមកប្រជាពលរដ្ឋមួយចំនួនជាអ្នកមានលទ្ធភាព ហើយគាត់ត្រូវការប្រញាប់ ឬពុំមានពេលវេលាកាន់ឯកសារ ព្រោះសេវាត្រូវឆ្លងកាត់អង្គភាពពាក់ព័ន្ធច្រើន ។ ប៉ុន្តែក៏មានប្រជាពលរដ្ឋមួយចំនួនធំ គាត់ទៅធ្វើដោយខ្លួនឯងដែរ ។ ពេលប្រជាពលរដ្ឋមកពឹង ពេលខ្លះខ្លួនជាអ្នកសម្រេចពីតម្លៃសេវាកញ្ចប់ទាំងបង់ចូលរដ្ឋ និងកម្រៃសម្រាប់មន្ត្រីរបស់ខ្លួនជួយសម្រួលជាមួយអង្គភាពពាក់ព័ន្ធ ។ ជាទូទៅប្រជាពលរដ្ឋមិនធ្វើដោយខ្លួនឯងទេ គាត់តែងស្នើឱ្យរត់ការឱ្យគាត់ ។ ចំពោះប្រាក់នៅសល់ពីការរត់ការគឺមិនទៀងទេព្រោះតាមលទ្ធភាពប្រជាពលរដ្ឋជូនជូនតិច និងជូនច្រើន ។ ប្រាក់ទាំងអស់នេះមួយផ្នែក ខ្លួនបង់សេវា



Scanned with CamScanner

ជូនរដ្ឋដូចជា ពន្ធប្រថាប់ត្រា និងបង់ទៅផ្នែកពាក់ព័ន្ធ ហើយប្រាក់នៅសល់ខ្លួនចែកទៅមន្ត្រីដែលខ្វះលទ្ធភាព និងទុកមួយចំណែកតូចសម្រាប់ខ្លួនឯងផ្ទាល់ ។ ចំពោះលោក [redacted] ប៊ុនថេង គាត់មិនទទួលប្រាក់ពីការរត់ការទេ ដោយគាត់ទុកឱ្យខ្លួនជួយសង្គម ហើយគាត់ទទួលតែកម្រៃគូសប្លង់របស់គាត់ប៉ុណ្ណោះ ។ ចំពោះលោក [redacted] វុទ្ធី ក៏ដូចគ្នា គាត់ប្រគល់ឱ្យខ្លួនទុកជួយសង្គម ។ រាល់ការស្នើសុំនានាពាក់ព័ន្ធនឹងសំណង់ លោក [redacted] វុទ្ធី ជាអ្នកចុះហត្ថលេខាសង្ខេបរួចទើបខ្លួនចុះហត្ថលេខាជាក្រោយ ។ សមត្ថកិច្ចឃាត់ខ្លួនទាក់ទងនឹងរឿងដែលខ្លួនបានទទួលសេវាតាមការពឹងពាក់ស្នើសុំលិខិតអនុញ្ញាតសាងសង់សំណង់ស្វូឡា ។ ខ្លួនជួបដំបូងជាមួយវិស្វករក្រុមហ៊ុននៅហាងកាហ្វេមិនចាំ ដោយកាលនោះវិស្វករគ្រាន់តែកាន់ប្លង់សំណង់មកឆ្លងប៉ុណ្ណោះ ។ ខ្លួនបានប្រាប់គាត់ថា សំណង់ស្វូឡាអត់មាននៅក្នុងប្រកាសអន្តរក្រសួងទេ ហើយខ្លួនសុំពេលឆ្លងថ្នាក់ដឹកនាំសិន ។ ខ្លួនទាមទារសេវានាពេលតំណាងក្រុមហ៊ុនជានារីមកជួបខ្លួននៅក្នុងបន្ទប់ តែម្តង ។ ក្រុមហ៊ុនមានបំណងសាងសង់សំណង់ស្វូឡាលើផ្ទៃដី ១៣៤ ហិចតា តែប្លង់ដីមានតែ ៩៤ ហិចតា នៅខ្វះប្លង់ដីរហូតដល់ទៅ ៤០ ហិចតា ទើបខ្លួនគិតទៅលើតម្លៃធ្វើប្លង់កម្មសិទ្ធិដីបន្ថែម ។ ការគណនាតម្លៃនេះ ខ្លួនធ្វើជាមួយឈ្មោះ [redacted] ប៊ុនថេង ហើយឈ្មោះ [redacted] វុទ្ធី ពុំបានចូលរួមទេ ។ ក្រុមហ៊ុនបានស្នើសុំកក់ប្រាក់ចំនួន ៥.០០០ ដុល្លារអាមេរិក នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០១៩ ម៉ោងប្រហែល ១០ ព្រឹក បន្ទាប់ពីបានព្រមព្រៀងតាមតម្លៃដែលបានគណនារួច តែខ្លួនមិនបានទាមទារប្រាក់កក់នេះទេ ។ នាពេលនោះ នៅក្នុងបន្ទប់មានតំណាងក្រុមហ៊ុនពីរនាក់ ឈ្មោះ [redacted] ប៊ុនថេង និងខ្លួន ហើយប្រាក់ចំនួន ៥.០០០ ដុល្លារ អាមេរិក ខ្លួនក៏ប្រគល់ឱ្យឈ្មោះ [redacted] ប៊ុនថេង រាប់ រួចឈ្មោះ [redacted] ប៊ុនថេង ក៏ប្រគល់ឱ្យខ្លួនវិញ ។ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៩ ខ្លួនទៅជួបតំណាងក្រុមហ៊ុននៅភោជនីយដ្ឋានមហាលាភក៏តាមការស្នើសុំរបស់តំណាងក្រុមហ៊ុនដែរ ។ ខ្លួនទៅដល់ភោជនីយដ្ឋានមហាលាភនៅម៉ោងប្រហែលជា ៨ និង ១៥ នាទី ហើយឃើញឈ្មោះ [redacted] ប៊ុនថេង ឈ្មោះ [redacted] វុទ្ធី និងតំណាងក្រុមហ៊ុនពីរនាក់នៅទីនោះស្រាប់ ។ បន្ទាប់មក ខ្លួនក៏ចុះហត្ថលេខាលើលិខិតបញ្ជាក់ថា ក្រុមហ៊ុនពិតជាបានមកទំនាក់ទំនងការងារជាមួយខ្លួន ហើយតំណាងក្រុមហ៊ុនក៏ប្រគល់ប្រាក់ចំនួន ៤៥.០០០ ដុល្លារអាមេរិក ទៀត ។ ខ្លួនក៏ប្រគល់ប្រាក់នេះទៅឱ្យឈ្មោះ [redacted] ប៊ុនថេង ដើម្បីរាប់ និងរកថង់ខ្មៅដើម្បីច្រកទុក ចំណែកឈ្មោះ [redacted] វុទ្ធី គាត់ក៏ដើរចេញ ដោយខ្លួនពុំបានឱ្យគាត់ទៅឃាមផ្លូវទេ ។ ប្រាក់ចំនួន ១០០.០០០ ដុល្លារអាមេរិក ដែលជាសេវាកញ្ចប់នេះ ពេលចប់សព្វគ្រប់តាមការគិតរបស់ខ្លួន បើពុំទាន់គិតដល់អង្គភាពពាក់ព័ន្ធប្រាក់នៅសល់ជាប្រយោជន៍ខ្លួនប្រហែលជា ៣ ពាន់ ទៅ ៤ ពាន់ដុល្លារអាមេរិក ប៉ុណ្ណោះ ។ កន្លងមក ប្រាក់នៅសល់ខ្លួនតែងចែកឱ្យមន្ត្រីដែលពាក់ព័ន្ធការងារ មន្ត្រីខ្វះខាត និងមួយផ្នែកទៀត ខ្លួនទុកសម្រាប់លើកទឹកចិត្តដល់មន្ត្រីដែលខិតខំបំពេញការងារ រៀបចំឱ្យមានដំណើរទស្សនកិច្ច កាត់អាវ រៀបចំអបអរពិធីបុណ្យផ្សេងៗ ។ ដំបូងឡើយ ខ្លួនគិតថា ការទទួលប្រាក់ពីតំណាងក្រុមហ៊ុនជួយសម្រួលក្នុងនាមមនោសញ្ចេតនាប៉ុណ្ណោះមិនមែនអំពើខុសច្បាប់ទេ ។ ចំពោះសេវាគូសប្លង់វិញមិនមាននៅក្នុងប្រកាសអន្តរ ក្រសួងទេ ម្ចាស់សំណង់ត្រូវមានប្លង់ដី និងប្លង់សំណង់ដែលគូរដោយវិស្វករមានវិញ្ញាបនប័ត្រប្រកបអាជីវកម្មវិស្វករ។

ចាប់ពីឆ្នាំ២០១៦ មក ខ្លួនទទួលសេវាក្រៅច្បាប់ប្រហែលមិនដល់ ១៤០ ករណី ទេ ព្រោះករណីខ្លះទទួលហើយតែមិនជោគជ័យ ខ្លួនក៏ប្រគល់ប្រាក់ឱ្យគេវិញ ។ ខ្លួនពិតជាបានកត់ត្រានូវសេវាក្រៅច្បាប់ក្នុងសៀវភៅដែលសមត្ថកិច្ចបានដកហូតដែលមានទឹកប្រាក់សរុបប្រហែលជា ៣៧២.៧៤៧ ដុល្លារអាមេរិក និង ៤៩ លាន រៀល មែន តែខ្លួនទទួលស្គាល់តែចំនួន ២៧០.០០០ ដុល្លារអាមេរិក ប៉ុណ្ណោះ ។ ខ្លួនមិនចាំថា ក្នុងចំណោម ១៤០ ករណីនេះ ជោគជ័យប៉ុន្មានករណីទេ ។ សមត្ថកិច្ចដកហូតប្រាក់នៅក្នុងបន្ទប់ខ្លួនមានលុយដុល្លារចំនួន ១៧.៥២៩ ដុល្លារអាមេរិក និងលុយរៀលចំនួន ១៦ លាន ២៥ ម៉ឺនរៀល ដោយក្នុងនោះលុយដែលនៅក្នុងស្រោមសំបុត្រប្រហែល ៣ ទៅ ៤ ជាលុយដែលប្រជាពលរដ្ឋមកពឹងពាក់សេវា ហើយមានសរសេរឈ្មោះអ្នកពឹងពាក់នៅលើស្រោមសំបុត្រស្រាប់ ។ ចំណែកលុយក្រៅពីស្រោមសំបុត្រខាងលើជាលុយផ្ទាល់ខ្លួន ។ ចំណែកឯកសារលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីនៅក្នុងបន្ទប់របស់ខ្លួន សុទ្ធតែជាឯកសារខុសដែល

ត្រូវបោះចោលតែខ្លួនរវល់ពេកមិនទាន់បានប្រមូលបោះចោល ។

ខ្លួនមានប្រពន្ធឈ្មោះ [redacted] សុធានី រៀបការនៅឆ្នាំ ២០១១ ។ មុនពេលរៀបអាពាហ៍ពិពាហ៍ ខ្លួនមានទ្រព្យសម្បត្តិដូចជា៖ ដីនៅខេត្តឧត្តរមានជ័យ ឡានធុនត្រាមួយគ្រឿង ផ្ទះល្វែងមួយល្វែងនៅបុរីធ្វូធូនី និងមានប្រាក់នៅសល់ខ្ទង់ ៦ ទៅ ៧ ម៉ឺនដុល្លារអាមេរិក ។

ខ្លួនបានទិញដីមួយកន្លែងនៅភូមិស្ពានថ្ម ក្នុងឆ្នាំ២០១៦ ឬ២០១៧ តម្លៃ ៤៤.០០០ ដុល្លារអាមេរិក និងបានចំណាយប្រាក់ប្រហែល ៤០.០០០ ដុល្លារអាមេរិកទៀត ដើម្បីសង់ផ្ទះត្រចៀកកាំនៅលើដីនេះនៅឆ្នាំ២០១៩ ។ ប្រាក់ទិញដីនេះមួយចំណែកបានមកពីការលក់ដីរបស់ខ្លួននៅឧត្តរមានជ័យ ដោយឡែកប្រាក់សង់ផ្ទះត្រចៀកកាំក៏មានមួយចំណែកបានមកពីការលក់ដីខេត្តឧត្តរមានជ័យពីរប្លង់បានប្រាក់ចំនួន ២៩.០០០ ដុល្លារអាមេរិកដែរ ហើយប្រាក់មួយផ្នែកទៀតជាប្រាក់សន្សំរបស់ខ្លួន ។ ចំណែកផ្ទះលេខ៦១ នៅបុរីប៉េងហួត បុស្តិ៍វិទ្យុស្ទឹងមានជ័យ ខ្លួន និងប្អូនស្រីបានទិញជាមួយគ្នាក្នុងឆ្នាំ២០១៨ ដោយបានប្រាក់ពីការលក់ផ្ទះនៅបុរីធ្វូធូនីក្រោយផ្សារត្រពាំងថ្លឹងអោយបងស្រីបានប្រាក់ ៧០.០០០ ដុល្លារអាមេរិក និងប្រាក់សន្សំរបស់ខ្លួន និងប្រាក់សន្សំនៅផ្ទះសរុបប្រហែលជាង ៩០.០០០ ដុល្លារអាមេរិក ។ ខ្លួនទិញដីផ្ទះគ្មានលេខនៅភូមិដូនត្រុំ ក្នុងឆ្នាំ២០១៨ ក្នុងតម្លៃ ៧២.០០០ ដុល្លារអាមេរិក ដោយប្រាក់ទិញដីនេះមួយចំណែកបានមកពីប្រាក់សេវាពុំត្រឹមត្រូវ និងមួយចំនួនទៀតបានមកពីប្រាក់សន្សំនៅផ្ទះ ។ ចំពោះរថយន្តឡិចស៊ីសសេរីឆ្នាំ២០១០ ខ្លួនទិញក្នុងឆ្នាំ២០១៩ តម្លៃ ៨៦.០០០ ដុល្លារអាមេរិក ហើយប្រាក់ទិញឡាននេះបានមកពីប្រាក់លក់ឡានឡង់គ្រីស័រ ៤៧០ ចាស់ របស់ខ្លួនតម្លៃ ៥៥.០០០ ដុល្លារអាមេរិក (កាលទិញតម្លៃ ៧០.០០០ ដុល្លារអាមេរិក) និងថែមប្រាក់ខែសន្សំរបស់ខ្លួន និងប្រាក់របស់ប្រពន្ធខ្លួនចំនួន ១០.០០០ ដុល្លារអាមេរិកទៀតសុរបចំនួន ៣៣.០០០ ដុល្លារអាមេរិក ។ ចំណែកដីផ្ទះនៅភូមិមាន់ចៃជាផ្ទះរបស់ឪពុកម្តាយក្មេកដែលខ្លួនធ្វើការជួសជុលចំណាយថវិកាអស់ចំនួនជាង ៣ ទៅ ៤ម៉ឺនដុល្លារអាមេរិក ។ ប្រាក់នេះបងប្អូនខាងប្រពន្ធខ្លួននៅអាមេរិកជាអ្នកចេញលុយ ខ្លួនពុំមានភស្តុតាងណាបញ្ជាក់ថា លុយជួសជុលផ្ទះបងប្អូនប្រពន្ធផ្ញើរមកទេ ។ ចំពោះរថយន្តឡង់គ្រីស័រ ប្រាក់ចំណាយទិញរថយន្តបានមកពីលក់ឡានចាស់របស់ខ្លួន និងប្រាក់ខែខ្លួនសន្សំ បូកប្រាក់សន្សំនៅផ្ទះខ្លះ ។ ចំពោះរថយន្តម៉ាកគា ទិញនៅឆ្នាំ២០១៩ ក្នុងតម្លៃប្រហែលជាង ១២.៨០០ ដុល្លារអាមេរិក ហើយប្រាក់ទិញឡាននេះជាប្រាក់របស់ប្រពន្ធខ្លួនទេ ។

ប្រពន្ធខ្លួនមានមុខរបរលក់គ្រឿងសង្ហារឹម ចំណូលគាត់ប្រចាំខែខ្លួនមិនច្បាស់ទេ ប្រហែលជា ២.០០០ ទៅ ៣.០០០ ដុល្លារអាមេរិក ។ ចំណូលខ្លួនជាប្រចាំខែពីសេវាកញ្ចប់ និងប្រាក់លាភការនានាបានពី ២.០០០ ទៅ ៣.០០០ ដុល្លារអាមេរិក ដោយមិនទាន់គិតដល់ប្រាក់បៀវត្សរ៍ទេ ។ ខ្លួនប្រើប្រាស់គណនីធនាគារសម្រាប់បើកប្រាក់គំរោង និងធនាគារកាណាឌីយ៉ាសម្រាប់បើកប្រាក់ខែ ។ បៀវត្សរ៍របស់ខ្លួនពិតប្រាកដមានចំនួនតែ ២លានរៀល ប៉ុណ្ណោះ ។ ក្នុងមួយខែ ខ្លួនបានអោយលុយទៅប្រពន្ធពី ២.០០០ ទៅ ៣.០០០ ដុល្លារអាមេរិក ហើយប្រាក់នេះបានមកពីសេវាដែលខ្លួនទទួលបាន ។ ប្រាក់ដែលខ្លួនទទួលបានពីសេវាក្រៅច្បាប់ផ្ទាល់ខ្លួនមានចំនួនតែ ៧៥.០០០ ដុល្លារអាមេរិកប៉ុណ្ណោះ ព្រោះត្រូវចំណាយបង់ពន្ធជូនមន្ត្រី និងចំណាយផ្សេងៗ ។

ចំពោះឈ្មោះ [redacted] ទី ខ្លួនបានធ្វើប្លង់ដីជូនគាត់តាំងពីមុនពេលគាត់ដាក់ពាក្យបណ្តឹងទៅអង្គភាពប្រឆាំងអំពើពុករលួយទៅទៀត ។ កន្លងមក ខ្លួនក៏បានបំភ្លឺជូនអង្គភាពប្រឆាំងអំពើពុករលួយដែរថា គាត់ដាក់ពាក្យស្នើសុំគីនៅខ្វះឯកសារមួយចំនួនធំ ។ ខ្លួនមិនដឹងថា ហេតុអ្វីបានជាគាត់ប្តឹងទាមទារលុយខ្លួនចំនួន ២០.០០០ ដុល្លារអាមេរិក នោះទេ ខ្លួនពិតជាបានទទួលប្រាក់នេះមែន ។ លុយចំនួន ២០.០០០ ដុល្លារអាមេរិក នេះ ខ្លួនមិនចាំថា ចំណាយទៅលើសេវាពន្ធប្រថាប់ត្រាអស់



Scanned with CamScanner

ប៉ុន្មានទេ ហើយប្រាក់នៅសល់ក៏មិនចាំថាប៉ុន្មានដែរព្រោះបែងចែកអស់ហើយ ។ ចំពោះឈ្មោះ [redacted] ហេងឡុង ខ្លួនពុំស្គាល់ទេ ហើយខ្លួនក៏ពុំដឹងថាគាត់ប្ដឹងខ្លួនដែរ ។

ខ្លួនសុំធ្វើការកែប្រែខ្លួនដោយសន្យាថា មិនអោយមានកំហុសទៀតឡើយ ខ្លួនកំពុងតែមានជម្ងឺ ម្ដាយបង្កើតក៏មាន ជម្ងឺ ចំណែកឯប្រពន្ធរបស់ខ្លួនទើបតែសម្រាល ដែលកូនកើតមកមានសុខភាពមិនល្អក៏ត្រូវចិញ្ចឹមក្នុងកែវទៀតផង ។

៥-សាក្សីឈ្មោះ [redacted] **សុធានី** (ប្រពន្ធរបស់ឈ្មោះ [redacted] **ប៊ុនរឿន**) បានឆ្លើយនៅដំណាក់កាលនៃការស៊ើបសួរថា៖ ខ្លួនរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ [redacted] **ប៊ុនរឿន** នៅឆ្នាំ ២០១១ ។ នៅពេលរៀបអាពាហ៍ពិពាហ៍ ប្ដីរបស់ខ្លួនមានទ្រព្យសម្បត្តិដីផ្ទះនៅខេត្តតាកែវចំនួនពីរល្វែងដែលម្ដាយគាត់ចែកឱ្យគាត់មួយល្វែង និងប្អូនគាត់មួយល្វែង និងមានដីមួយកន្លែងនៅភូមិកំពង់ជ្រៃ ។ បច្ចុប្បន្នផ្ទះមួយល្វែងខាងលើនេះនៅតែជាកម្មសិទ្ធិរបស់ខ្លួន និងប្ដីដដែល ។ ក្រោយរៀបការ ប្ដីខ្លួនមានដីនៅខេត្តឧត្ដរមានជ័យជាច្រើន ដោយប័ណ្ណកម្មសិទ្ធិមានតែឈ្មោះគាត់ទេ ហើយគាត់ជាអ្នករក្សាទុកនូវប័ណ្ណទាំងអស់នេះ ។ ខ្លួនមិនដឹងថា ដីនៅឧត្ដរមានជ័យមានប៉ុន្មានកន្លែងទេ ហើយខ្លួនមានប័ណ្ណកម្មសិទ្ធិរក្សាទុកតែ ៤ ទៅ ៥ ប៉ុណ្ណោះ ។ ប្ដីខ្លួនមានដីមួយចំនួនទៀតចូលហ៊ុនជាមួយបងគាត់ ហើយដីចូលហ៊ុនគឺបងរបស់គាត់ជាអ្នកទុកដាក់ ។ ប្រហែលជាចុងឆ្នាំ ២០១១ ខ្លួនបានបើកហាងលក់គ្រឿងសង្ហារឹមនៅខេត្តពោធិ៍សាត់ ហើយទីតាំងអាជីវកម្មជាផ្ទះរបស់ឪពុកម្ដាយខ្លួន ។ ប្រហែលជាឆ្នាំ ២០១៤ ប្ដីខ្លួនឡើងឋានៈជាប្រធានមុខងារសាធារណៈនៅខេត្តពោធិ៍សាត់ ហើយបន្ទាប់ពីធ្វើការបាន ២ឆ្នាំ គាត់ក៏ត្រូវបានតម្លើងជាប្រធានមន្ទីរសុរិយោដីខេត្តពោធិ៍សាត់ ។ ក្នុងអំឡុងខែឧសភា ឆ្នាំ២០១៦ ប្ដីខ្លួនបានឡើងឋានៈជាប្រធានមន្ទីរសុរិយោដីខេត្តពោធិ៍សាត់ ហើយគាត់ឱ្យប្រាក់ខ្លួនក្នុងមួយខែ ២.០០០ ដុល្លារអាមេរិក ទៅ ៣.០០០ ដុល្លារអាមេរិក ។ ចំពោះប្រាក់ទាំងនេះ ប្ដីខ្លួនប្រាប់ថា ជាប្រាក់ខែខ្លះ និងប្រាក់គាត់រកបានខ្លះ ហើយខ្លួនក៏ពុំសួរនាំដែរព្រោះរវល់រកស៊ី ។ ខ្លួនមិនចាំថា ក្នុងឆ្នាំ២០១៩ ប្ដីខ្លួនមានទិញដី ឬក៏អត់នោះទេ ។ នៅឆ្នាំ២០១៦ ខ្លួនបានទិញដីពីប្រជាពលរដ្ឋទំហំ ១០០ ហិកតា នៅស្រុកក្រវ៉ាញ ខេត្តពោធិ៍សាត់ តម្លៃ ៤៤.០០០ (បួនម៉ឺនបួនពាន់) ដុល្លារអាមេរិក ។ លុយដែលយកទៅទិញដីនេះ ខ្លួនពុំចាំថា លុយខ្លួនតែឯង ឬមានលុយប្ដីចូលរួមដែរ ឬអត់ទេ ដីនេះពុំមានប្លង់ទេ ហើយមានឈ្មោះខ្លួនតែម្នាក់ឯងប៉ុណ្ណោះ ចំពោះឯកសារខ្លួនបាត់រកពុំឃើញទេ ។ នៅពេលមានកម្មវិធីបុណ្យទាន ដូចជា ហែរកឋិនប្ដីរបស់ខ្លួនគាត់ច្រើនយកលុយអង្គភាព (មន្ទីរ) ខ្លះ និងលុយផ្ទះប៉ុន្តែតិចតួចដែរ ។ មួយរយៈមុនប្ដីខ្លួនប្រាប់ថា ចង់ហែរកឋិន ហើយគាត់ក៏តម្កល់នៅមន្ទីរ ១០.០០០.០០០ រៀល តែខ្លួនមិនបានសួរដេញដោលទេ ។ នៅឆ្នាំ២០១៦ ឈ្មោះ [redacted] កុសល ជាគយនៅខេត្តពោធិ៍សាត់ធ្លាប់យកលុយមកឱ្យខ្លួនចំនួន ២០.០០០ ដុល្លារអាមេរិក ថាទុកឱ្យប្ដីទៅគាត់ដឹងហើយ ។ ពេលខ្លួនសួរ ប្ដីខ្លួនប្រាប់ថាទុកសិនទៅ ហើយពេលគាត់ត្រូវការចាំគាត់យក ដោយខ្លួនមិនដឹងថា លុយ ២០.០០០ ដុល្លារអាមេរិក ជាលុយអ្វីនោះទេ ។ នៅឆ្នាំ ២០១៧ ខ្លួនបានទិញដីមួយកន្លែងមិនចាំទំហំតម្លៃ ៤២.០០០ ដុល្លារអាមេរិក នៅភូមិស្ពានថ្ម ។ នៅឆ្នាំ២០១៨ ពួកខ្លួនបានទិញដីមួយកន្លែងទៀត តម្លៃ ៧៤.០០០ ដុល្លារអាមេរិក នៅភូមិដូនជ្រុំ ។ ដីទាំងពីរកន្លែងនេះមានប័ណ្ណកម្មសិទ្ធិជាទ្រព្យសម្បត្តិរួម ហើយលុយទិញដីទាំងពីរកន្លែងនេះបានមកពីលុយខ្លួនខ្លះ និងលុយប្ដីខ្លួនសន្សំខ្លះ ។ ចំពោះផ្ទះត្រចៀកកាំដែលខ្លួនធ្វើនៅលើដីភូមិស្ពានថ្ម ចំណាយថ្លៃសាងសង់សរុបអស់ចំនួន ៤០.០០០ ដុល្លារអាមេរិក ។ សព្វថ្ងៃធ្វើបានពីរជាន់ហើយ និងបានឱ្យលុយសំណង់គេជាង ៣០.០០០ ដុល្លារអាមេរិក ហើយ ប៉ុន្តែឧបករណ៍បំពាក់ចិញ្ចឹមត្រចៀកកាំនៅពុំទាន់បានដាក់នៅឡើយ ។ លុយធ្វើផ្ទះត្រចៀកកាំនេះបានមកពីលុយដែលប្ដីខ្លួនលក់ដីចំនួនពីរកន្លែងនៅខេត្តឧត្ដរមានជ័យ ។ ចំពោះកូនចៅប្ដី ខ្លួនមិនដែលឃើញពួកគេយកលុយមកឱ្យនៅផ្ទះទេ ។ ផ្ទះដែលខ្លួនប្រកបអាជីវកម្មស្ថិតនៅភូមិមាន់ចៃ ខេត្តពោធិ៍សាត់ ជាកម្មសិទ្ធិរបស់ឪពុកម្ដាយខ្លួន ហើយឈ្មោះក្នុងប្លង់ ក៏ឪពុកម្ដាយខ្លួនដែរ ។ ឃ្លាំងដែលខ្លួនធ្វើលើដីផ្ទះនោះជារបស់ខ្លួន ហើយធ្វើអស់ប្រាក់ចំនួន ២.០០០ ដុល្លារអាមេរិក ។ ដោយឡែក ចំពោះតម្លៃគ្រឿងសង្ហារឹមខ្លួនពុំចាំទេ ។ ពេលបើកលក់ដំបូងក្នុងឆ្នាំ២០១១ ខ្លួនបានចំណាយប្រាក់ចំណេញដៃខ្លះ និងប្រាក់ឪពុកម្ដាយចែកឱ្យខ្លះ រួមទាំងប្រាក់ដែលឪពុក



Scanned with CamScanner

ម្តាយក្មេកឱ្យខ្លះសរុបប្រហែលជា ៦០.០០០ ដុល្លារអាមេរិក ទៅ ៧០.០០០ ដុល្លារអាមេរិក ។ ប្តីខ្លួនមិនបានឱ្យប្រាក់ខ្លួនបើកអាជីវកម្មនេះទេ គាត់គ្រាន់តែឱ្យប្រាក់ខែ ២.០០០ ទៅ ៣.០០០ ដុល្លារអាមេរិក ប៉ុណ្ណោះ ហើយប្រគល់ដោយផ្ទាល់ដៃតែម្តង។ នៅឆ្នាំ២០១៨ ខ្លួនបានទិញផ្ទះបុរីប៉េងហួត តម្លៃ ១៦៨.០០០ ដុល្លារអាមេរិក ដោយចំណាយប្រាក់ដែលបានមកពីការលក់ផ្ទះនៅត្រពាំងថ្លឹងចំនួន ៧០.០០០ ដុល្លារអាមេរិក ប្រាក់ខ្លួនខ្លះ និងប្រាក់ប្តីសន្សំខ្លះ ។ ចំណូល ពីអាជីវកម្មរបស់ខ្លួនក្នុងមួយខែបាន ៣.០០០ ដុល្លារអាមេរិក ទៅ ៤.០០០ ដុល្លារអាមេរិក ។ ខ្លួនពុំមានគណនីធនាគារទេ ចំណែកប្តីខ្លួនមានគណនីធនាគារកាណាឌីយ៉ាជាគណនីប្រាក់ខែរបស់គាត់ ។ ខ្លួនពុំដឹងថា ប្តីខ្លួនមានចំណូលប៉ុន្មានទេ គ្រាន់តែដឹងថាចំណូលរបស់ខ្លួនច្រើនជាងគាត់ ព្រោះខ្លួនលក់សាឡុងមួយឈុតចំណេញបាន ២.០០០ ដុល្លារអាមេរិក ហើយលក់ដាច់ជាប្រចាំ ។ ប្តីខ្លួនធ្លាប់ប្រាប់ថា ចង់ខ្ចីលុយប្អូនស្រីគាត់នៅខេត្តតាកែវ ឈ្មោះ សុជាតា ជាអ្នកលក់គ្រឿងសំណង់ចំនួនជាង ២០០.០០០ ដុល្លារអាមេរិក ដើម្បីបើកក្រុមហ៊ុន ប៉ុន្តែមិនទាន់បានខ្ចីទេ ។ បងប្អូនប្តីរបស់ខ្លួនមានចំនួន ៦នាក់ ។ ខ្លួនពុំដឹងថា គណនីធនាគារប្តីខ្លួនមានលុយ ឬអត់ទេ ហើយខ្លួនក៏មិនចេះប្រើប្រព័ន្ធធនាគារដែរ ។ ចំពោះកាតធនាគារ ខ្លួនចាំថាមានតែកាតធនាគារកាណាឌីយ៉ា ហើយកាតធនាគារផ្សេងទៀត ខ្លួនមិនចាំទេ ។ ចំពោះឡាន Morning សេរីឆ្នាំ២០១២ ស្លាកលេខ ពោធិ៍សាត់ 2D-3888 ខ្លួនបានទិញក្នុងឆ្នាំ២០១៩ តម្លៃ ១១.៥០០ ដុល្លារអាមេរិក ដោយយកប្រាក់បានពីអាជីវកម្មរបស់ខ្លួន ។ កាលប្តីខ្លួនធ្វើការនៅខេត្តឧត្តរមានជ័យ គាត់ជិះរថយន្ត Tundra សេរីឆ្នាំ២០០៧ តម្លៃជាង ២០.០០០ ដុល្លារអាមេរិក ទៅ ៣០.០០០ ដុល្លារអាមេរិក ជាឡានដែលម្តាយក្មេកខ្លួនទិញឱ្យគាត់មុនពេលរៀបការ ហើយលក់វិញបាន ២០.០០០ ដុល្លារអាមេរិក ។ ចំពោះឡាន Land Cruiser ខ្លួនមិនចាំថា គាត់ទិញពេលណាទេ ហើយក៏មិនដឹងតម្លៃប៉ុន្មានដែរ ប៉ុន្តែលក់វិញក្នុងឆ្នាំ២០១៩ បាន ៥៥.០០០ ដុល្លារអាមេរិក ។ ខ្លួនគ្រាន់តែចាំថា គាត់យកលុយផ្ទះទៅទិញខ្លះ តែមិនដឹងតម្លៃប៉ុន្មាន ។ ក្រោយមកគាត់លក់ឡាន Land Cruiser នេះ ហើយទិញឡាន Lexus 570 តម្លៃជាង ៨០.០០០ ដុល្លារអាមេរិក ដោយប្រើប្រាស់ប្រាក់បានមកពីការលក់ឡាន Land Cruiser និងប្រាក់ផ្ទះបន្ថែមចំនួន ១០.០០០ ក្រាស់ ទៅទិញ ។ កន្លងមក ធ្លាប់មានអ្នកមកទំនាក់ទំនងឱ្យប្តីជួយរត់ការដែរ តែខ្លួនមិនទទួលទេ ហើយរុញឱ្យទៅជួបប្តីខ្លួនតែម្តង ។ ចំពោះការចំណាយក្នុងផ្ទះមិនសូវចំណាយច្រើនទេ ព្រោះគ្រួសារមានគ្នាតិច ដោយមានតែខ្លួន ប្តីខ្លួន និងកូនស្រីបងកើតឆ្នាំ ២០១២ និងកូនស្រីទី២ កើតឆ្នាំ២០១៤ ។ ខ្លួនកំពុង ពពោះកូនមួយទៀតបាន ៦ខែហើយ បច្ចុប្បន្នខ្លួនផ្អាកការលក់គ្រឿងសង្ហារឹមបណ្តោះអាសន្នហើយ ។ នៅថ្ងៃកើតហេតុថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៩ នៅម៉ោងប្រហែលជា ៨ព្រឹក ខ្លួនឮមនុស្សស្រីទូរស័ព្ទមក ខ្លួនក៏សួរនាំ ហើយគាត់ប្រាប់ថា ក្រុមហ៊ុនគេទាក់ទងរឿងសូឡា ហើយគាត់ប្រាប់ទៀតថា ទៅជួបគេនៅហាងមហាលាភ ។ នៅថ្ងៃបន្ទាប់ប្រហែលជាថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩ ខាងអង្គភាពប្រឆាំងអំពើពុករលួយបានឱ្យប្តីខ្លួនទូរស័ព្ទមកខ្លួនឱ្យយកកាបូបម៉ាក Burberry ឱ្យគាត់នៅអង្គភាពប្រឆាំងអំពើពុករលួយ ខ្លួនឃើញលុយក្នុងនោះ ៥.០០០ ដុល្លារអាមេរិក ។ បន្ទាប់មក ខ្លួនក៏យកកាបូបនោះប្រគល់ ឱ្យគាត់នៅមុខអង្គភាពប្រឆាំងអំពើពុករលួយដែលមានមន្ត្រីអង្គភាពប្រឆាំងអំពើពុករលួយនៅទីនោះដែរ ។ ខ្លួនមិនដឹងថា លុយនេះគាត់បានមកពីណាទេ ហើយខ្លួនទើបដឹងនៅពេលអង្គភាពប្រឆាំងអំពើពុករលួយចាប់គាត់ ។ ចំពោះឡាន Lexus 570 បច្ចុប្បន្នខ្លួនរក្សាទុកនៅផ្ទះឯខេត្តពោធិ៍សាត់ (ផ្ទះលក់គ្រឿងសង្ហារឹម) មិនមានលក់ដូរទៅណាទេ ។

**៥-សាក្សីលោក [redacted] គីមហេង** (មន្ត្រីនគរបាលយុត្តិធម៌) បានបំភ្លឺថា៖ ខ្លួនមានមុខងារជាអនុប្រធាននាយកដ្ឋានកិច្ចការគតិយុត្តិ ។ ពាក់ព័ន្ធករណីនេះ ដំបូងឡើយតាំងពីឆ្នាំ២០១៨ អង្គភាពបានទទួលពាក្យបណ្តឹង និងព័ត៌មានមួយចំនួនដែលទាក់ទងនឹងលោក [redacted] ប៊ុនរឿន ។ កន្លងមក អង្គភាពប្រឆាំងអំពើពុករលួយបានឱ្យគាត់បំភ្លឺជាហូរហែរ ។ រហូតមកដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២១០៩ អង្គភាពប្រឆាំងអំពើពុករលួយក៏បានទទួលព័ត៌មានសំងាត់ ហើយបានប្រតិបត្តិការណ៍ប្រមូលព័ត៌មាននៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ ដល់ថ្ងទី២៧ ខែកក្កដា ឆ្នាំ២០១៩ ដោយបានតាមដានគោលដៅ



Scanned with CamScanner

ជាប់រហូត ។ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៩ នាពេលមានការប្រគល់ទទួលប្រាក់ជាក់ស្តែង អង្គភាពក៏ធ្វើការឃាត់ខ្លួនជនជាប់ចោទទាំងបីនាក់មកកាន់អង្គភាពប្រឆាំងអំពើពុករលួយដើម្បីសាកសួរ និងកសាងសំណុំរឿងតាមនីតិវិធីរហូតបញ្ជូនមកតុលាការ ។ នៅអង្គភាពប្រឆាំងអំពើពុករលួយ ជនជាប់ចោទទាំងបីនាក់បានសហការណ៍ផ្តល់ព័ត៌មាន ហើយអង្គភាពបានបំពេញនីតិវិធីត្រឹមត្រូវតាមច្បាប់ ។ នាពេលឃាត់ខ្លួន អង្គភាពបានឃាត់ខ្លួនអ្នកទាំងបី និងបានដកហូតទឹកប្រាក់ចំនួននៅជាប់ខ្លួន នៅការិយាល័យរបស់លោក [redacted] ប៊ុនរឿន ព្រមទាំងវត្ថុតាងមួយចំនួនទៀត ។

៦-តាមអំណាន ដីកាសម្រេចបង្កកទ្រព្យសម្បត្តិលេខ ៣៣០ “វ” ព្រ.ទ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៩ ឃើញថា ទ្រព្យសម្បត្តិរបស់ជនជាប់ចោទឈ្មោះ [redacted] ប៊ុនរឿន ដែលត្រូវបានចៅក្រមស៊ើបសួរសម្រេចបង្កកមានដូចជា ៖

-ដីផ្ទះលេខ៦១ ផ្លូវលេខ៤ បុរីប៉េងហួត (ប៉ុស្តិ៍វិទ្យុស្ទឹងមានជ័យ) រាជធានីភ្នំពេញ ទិញក្នុងឆ្នាំ២០១៨ ។

-ដីផ្ទះនៅភូមិអូរជ្រៃ សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ទិញក្នុងឆ្នាំ២០១៨ ។

-ដីស្ថិតនៅភូមិស្ពានថ្ម សង្កាត់រលាប ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ទិញក្នុងឆ្នាំ២០១៧ និងកំពុងសាងសង់ផ្ទះត្រចៀកកាំ ។

-រថយន្តម៉ាក Lexus 570 ពណ៌មាស សេរីឆ្នាំ២០១០ ស្លាកលេខ ពោធិ៍សាត់ ២C-៣៨៨៨ ។

-រថយន្តម៉ាក KIA Morning ពណ៌ ស សេរីឆ្នាំ២០១២ ស្លាកលេខ ពោធិ៍សាត់ ២D-៣៨៨៨ (ទិញក្នុងឆ្នាំ២០១៩)។

៧-តាមអំណានបណ្តឹងចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] ទី ដែលបានដាក់នៅអង្គភាពប្រឆាំងអំពើពុករលួយបានបង្ហាញថា៖ ខ្លួនឈ្មោះ [redacted] ទី ជាប្រជាពលរដ្ឋរស់នៅភូមិត្រពាំងជង ឃុំត្រពាំងជង ស្រុកបាកាន ខេត្តពោធិ៍សាត់ សូមប្តឹងលោក [redacted] ប៊ុនរឿន ជាប្រធានមន្ទីរសុរិយោដីខេត្តពោធិ៍សាត់ ដែលបានយកប្រាក់របស់ខ្លួនចំនួន ២០.០០០ ដុល្លារអាមេរិក ដើម្បីចុះបញ្ជីដីមួយកន្លែងស្ថិតនៅភូមិស្ពានថ្មី៦ សង្កាត់ស្វាយអាត់ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ។ នៅពេលខ្លួនទៅជួបគាត់សួរពីរឿងប្លង់ដី គាត់សន្យាថាបានថ្ងៃនេះថ្ងៃនោះ ហើយគិតមកដល់ពេលនេះមានរយៈពេលជាង ៥ខែ មកហើយ ខ្លួននៅតែមិនទាន់ទទួលបានប្លង់ដីនៅឡើយ ។ នៅថ្ងៃកើតហេតុគឺថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៨ ខ្លួនបានទៅយកប្លង់ដីពីគាត់ម្តងទៀត ហើយគាត់នៅតែឆ្លើយថា (ដីហ្នឹងមិនទាន់ហើយទេ គាត់កំពុងតែធ្វើហើយគាត់មិនធ្វើអោយក៏បានដែរ) ពេលខ្លួនឮសំដីនេះខ្លួនផ្តាក់ផ្អើលក្តុក និងអស់សង្ឃឹមយ៉ាងខ្លាំងពីព្រោះលុយនេះខ្លួនបានចងការគេក្នុងអត្រាការប្រាក់ខ្ពស់ដោយសង្ឃឹមថាបានប្លង់ដីយកទៅដាក់ធនាគារដើម្បីរកស៊ីចិញ្ចឹមជីវិត ការប្រាក់ទាប ដឹងអីប្រធានឆបោកលុយអស់ ប្លង់ក៏មិនបាន និងត្រូវបានប្រធានមន្ទីរគ្មានក្រមសីលធម៌ និងគ្មានវិជ្ជាជីវៈនៅក្នុងខ្លួន សូម្បីការនិយាយជាស្តី ជាពិសេសទៅទៀតគាត់ជាមន្ត្រីមិនបំរើជូនប្រជាពលរដ្ឋដូចសម្តេចតេជោ ហ៊ុន សែន មានប្រសាសន៍ថា មន្ត្រីគឺជាអ្នកបំរើរាស្ត្រចំណែករាស្ត្រគឺជាចៅហ្វាយ ។ នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩ បន្ទាប់ពីជនជាប់ចោទឈ្មោះ [redacted] ប៊ុនរឿន ត្រូវបានឃាត់ខ្លួន ឈ្មោះ [redacted] ទី ក៏បានដាក់ពាក្យបណ្តឹងម្តងទៀតដើម្បីទាមទារប្រាក់ចំនួន ២០.០០០ ដុល្លារអាមេរិក ។

៨-តាមអំណាចបណ្តឹង ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ហេងឡុង ដែលបានដាក់បណ្តឹងទាមទារនៅអង្គភាពប្រឆាំងអំពើពុករលួយថា៖ ខ្លួនឈ្មោះ [redacted] ហេងឡុង ភេទប្រុស អាយុ ៣៣ឆ្នាំ រស់នៅភូមិដើមជ្រេស ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់ ។ លោក [redacted] ប៊ុនរឿន អតីតជាប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តពោធិ៍សាត់ បានយកប្រាក់ខ្លួនចំនួន ១២.០០០ ដុល្លារអាមេរិក ដើម្បីធ្វើប្លង់រឹងដីមួយកន្លែង ដែលមានទំហំ ៧ហិចតា ស្ថិតនៅភូមិដើមជ្រេស ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់ ប្រហែលដើមខែកក្កដា ឆ្នាំ២០១៩ តែមកដល់ពេលនេះ ខ្លួនមិនទាន់បានទទួលប្លង់រឹងនៅឡើយទេ ។

## សេចក្តីសន្និដ្ឋានផ្តែងសុំរបស់តំណាងអយ្យការ



Scanned with CamScanner

ក្រោយពីបានពិនិត្យសំណុំរឿង និងក្រោយពីបានស្តាប់នូវចម្លើយរបស់ជនជាប់ចោទ អំណានចម្លើយរបស់សាក្សី សេចក្តីបំភ្លឺរបស់មន្ត្រីនគរបាលយុត្តិធម៌ ពាក្យបណ្តឹងនានា តំណាងអយ្យការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] ប៊ុនរឿន នៅក្នុងអង្គសវនាការបានឆ្លើយទទួលស្គាល់នូវបទចោទក៏ដូចជាអំពើដែលខ្លួនបានប្រព្រឹត្ត ដោយនៅក្នុងអង្គសវនាការក៏ដូចជានៅក្នុងសំណុំរឿងនេះជនជាប់ចោទឈ្មោះ [redacted] ប៊ុនរឿន បានទទួលស្គាល់នូវអំពើដែលខ្លួនបានប្រព្រឹត្តដូចការចោទប្រកាន់ ។ ជនជាប់ចោទបានឆ្លើយនៅអង្គភាពប្រឆាំងអំពើពុករលួយថា ជនជាប់ចោទពិតជាសុំតំណាងក្រុមហ៊ុនចំនួន ១០០.០០០ ដុល្លារអាមេរិក ហើយទទួលបានប្រាក់ចំនួន ៥០ ភាគរយ ស្មើនឹង ៥០.០០០ ដុល្លារអាមេរិក ដោយមាន ចេញវិក័យប័ត្រជូនតំណាងក្រុមហ៊ុនឡើយ ។ ជាងនេះទៀត ជនជាប់ចោទក៏បានបញ្ជាក់ថា ការទាមទារតម្លៃ ១០០.០០០ ដុល្លារអាមេរិក ជនជាប់ចោទបានចំណេញប្រហែលជា ២.០០០ ដុល្លារ អាមេរិក ទៅ ៣.០០០ ដុល្លារអាមេរិក ។ ហើយក្នុងមួយខែ ខ្លួនបានទទួលពី ២.០០០ ដុល្លារអាមេរិក ទៅ ៣.០០០ ដុល្លារអាមេរិក ពីសេវាដែលគេពឹងពាក់ ។ ប្រាក់ចំណេញដែលជនជាប់ចោទតែងតែទទួលបាននេះជាពន្ធជាអាករគឺលើសពីចំនួនដែល អ្នកដែលមកពឹងពាក់ជនជាប់ចោទបានបង់ ។ម្យ៉ាងទៀត តាមភស្តុតាងដែលប្រមូលបានដោយអង្គភាពប្រឆាំងអំពើពុករលួយមានដូចជា ពាក្យបណ្តឹងរបស់ជនរងគ្រោះ របាយការណ៍លេខ ៣០៨/១៩ នបហបព ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ ២០១៩ របស់នាយកដ្ឋានបច្ចេកទេសកោសលវិច័យ និងការត្រួតពិនិត្យម៉ាស៊ីនទិន្នន័យកាមេរ៉ាសុវត្ថិភាពម៉ាក DHI ទំហំ ៤TKB រូបថតចេញពីកាមេរ៉ាសុវត្ថិភាព និងសៀវភៅកំណត់ត្រា បានបង្ហាញសកម្មភាពដែលជនជាប់ចោទបានទារប្រាក់ និងទទួលប្រាក់ក្រៅសេវារដ្ឋដែលបានកំណត់ជាហូរហែរ ។ អំពើនេះគឺជាបទនីតិក្រមដូចមានចែងនៅក្នុងមាត្រា ៥៩២ និងមាត្រា ៥៩៣ នៃក្រមព្រហ្មទណ្ឌ ។ ជនជាប់ចោទក៏បានឆ្លើយសារភាពផងដែរថា ក្នុងនាមជាមន្ត្រីសាធារណៈបែរប្រើប្រាស់តួនាទីដើម្បីរត់ការច្បាប់សាងសង់ដែលជាអំពើមិនត្រឹមត្រូវ ប៉ុន្តែជនជាប់ចោទបែរជាយកលេសថា បទដ្ឋានគតិយុត្តមិនមានប្រការណាដែលកំណត់ ពីតួនាទីជាអ្នករត់ការឯកសារនេះទេ ហើយក៏មិនបានហាមមិនឱ្យមន្ត្រីរត់ការឯកសារក្រៅម៉ោងរដ្ឋបាលផងដែរ ។ ការដែលជនជាប់ចោទទទួលភារកិច្ចរត់ការដែលច្បាប់មិនហាមដើម្បីបានកម្រៃសេវាពីប្រជាពលរដ្ឋ ជនជាប់ចោទគិតថាមិនខុសនោះទេ ព្រោះជនជាប់ចោទគ្រាន់តែសម្រួលឱ្យការប្រើប្រាស់សេវាបានលឿនជាងច្បាប់កំណត់ប៉ុណ្ណោះ ហើយប្រាក់ដែលទទួលបានក៏ជាការសងគុណពីប្រជាពលរដ្ឋផងដែរ ។ ដោយសារតែនេះជាទំនៀមទំលាប់ខ្មែរ ហើយជនជាប់ចោទធ្វើការបម្រើសេវានេះបន្ថែមនៅក្រៅម៉ោងរដ្ឋបាល ការប្រើប្រាស់តួនាទី និងអង្គភាពដោយបានណែនាំមន្ត្រីក្នុងមន្ទីរក៏ដូចជាខ្លួនផ្ទាល់រត់ការសេវាផ្សេងៗ ដើម្បីទទួលបានកម្រៃក្រៅផ្លូវការជាប្រយោជន៍ផ្ទាល់ខ្លួន ដូចមានបង្ហាញក្នុងភស្តុតាងដែលប្រមូលបាននៅក្នុងសំណុំរឿងនេះគឺជាបទល្មើស រំលោភអំណាច ដូចមានចែងក្នុងមាត្រា ៣៥ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ។ ដោយឡែកជនជាប់ចោទ និងប្រពន្ធឈ្មោះ [redacted] សុធានី បានឆ្លើយប្រហាក់ប្រហែលគ្នាថា ទ្រព្យដែលខ្លួនបានទិញគឺបានមកពីការលក់ទ្រព្យចាស់ ដោយបន្ថែមប្រាក់ជនជាប់ចោទសន្សំខ្លះ និងប្រាក់ប្រពន្ធសន្សំខ្លះ ។ ជនជាប់ចោទ បានឆ្លើយនៅចំពោះមុខចៅក្រមស៊ើបសួរថា ចំណូលរដ្ឋរបស់ខ្លួនទទួលបានប្រហែលជា ៦ លានរៀលទៅ ៧ លានរៀល ហើយយ៉ាងច្រើនគឺ ៨ លានរៀលក្នុងមួយខែ ។ ក្នុងមួយខែៗ ជនជាប់ចោទទទួលបានពីសេវារត់ការចំនួន ២.០០០ ដុល្លារ អាមេរិក ទៅ ៣.០០០ ដុល្លារអាមេរិក ស្របតាមការអះអាងរបស់ប្រពន្ធជនជាប់ចោទដែលឆ្លើយថាជនជាប់ចោទបានឱ្យប្រាក់ប្រចាំខែពី ២.០០០ ដុល្លារអាមេរិក ទៅ ៣.០០០ ដុល្លារអាមេរិក ។ ប៉ុន្តែនាពេលសវនាការ ជនជាប់ចោទបែរជាឆ្លើយថា ប្រាក់ខែរបស់ជនជាប់ចោទពុំបានដល់កំរិត ២.០០០ ដុល្លារអាមេរិក ទៅ ៣.០០០ ដុល្លារអាមេរិកទេ ។ ចំណូលដែលជនជាប់ចោទរកបានពុំសមាមាត្រទៅនឹងទ្រព្យសម្បត្តិដែលជនជាប់ចោទកំពុងមាននាពេលបច្ចុប្បន្ន ។ ជនជាប់ចោទក៏បានបញ្ជាក់ផងដែរថា សេវាក្រៅផ្លូវច្បាប់ដែលទទួលបានសម្រាប់ផ្ទាល់ខ្លួនក្នុងអំឡុងពេលដែលជនជាប់

ចោទមានតួនាទីជាប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តពោធិ៍សាត់ រយៈពេល ៣ឆ្នាំមកនេះ មានចំនួន ៧៥.០០០ ដុល្លារអាមេរិក ។ អំពើនេះបានស្តែងឱ្យឃើញពីការប្រព្រឹត្តបទល្មើសសម្អាតប្រាក់ ដូចមានចែង និងឱ្យផ្តន្ទាទោស តាមមាត្រា ៣ថ្មី និងមាត្រា ២៩ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ៣ មាត្រា ២៩ និងមាត្រា ៣០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភាវរកម្ម ។ ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី បានឆ្លើយទទួលស្គាល់នូវបទចោទរបស់ខ្លួននាពេលសវនាការ ។ នៅក្នុងសកម្មភាពនៃអំពើដែលបានធ្វើការចោទប្រកាន់នេះ ជនជាប់ចោទក៏មានវត្តមានចូលរួមផងដែរ ។ នៅថ្ងៃកើតហេតុថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៩ ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី បានចូលរួមក្នុងសកម្មភាពជាមួយនឹងជនជាប់ចោទឈ្មោះ [redacted] ប៊ុនរឿន និងជនជប់ចោទឈ្មោះ [redacted] ប៊ុនថេង ដោយពេលនោះ ជនជាប់ចោទបានចេញទៅឃាមផ្លូវនាពេលតំណាងក្រុមហ៊ុនប្រគល់ប្រាក់ថ្លៃសេវាក្រៅច្បាប់ទៅឱ្យជនជាប់ចោទឈ្មោះ [redacted] ប៊ុនរឿន និង ឈ្មោះ [redacted] ប៊ុនថេង ។ ការប្រគល់ប្រាក់នេះធ្វើឡើងនៅថ្ងៃសៅរ៍ដែលជាថ្ងៃឈប់សម្រាកក្រៅម៉ោងការងារ ហើយការប្រគល់ប្រាក់ធ្វើឡើងនៅក្រៅស្ថាប័ន ពុំបានធ្វើឡើងនៅច្រកចេញចូលតែមួយដូចជនជាប់ចោទឈ្មោះ [redacted] ប៊ុនរឿន បានអះអាងនៅក្នុងសវនាការថា ប្រាក់សេវានានាត្រូវបង់នៅច្រកចេញចូលតែមួយ ។ ហេតុនេះ ទង្វើរបស់ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី ស្តែងឱ្យឃើញពីសកម្មភាពភាពចូលរួមក្នុងការប្រព្រឹត្ត បទវិតិក្រម និង បទរំលោភអំណាច ។ ចំពោះជនជាប់ចោទឈ្មោះ តែ ប៊ុនថេង បានចូលរួមយ៉ាងសកម្មភាពជាអ្នកទំនាក់ទំនងផង ជាអ្នករាប់លុយសេវាផង និងជាអ្នកចាត់ចែង ណាត់ជួបជាមួយនឹងតំណាងក្រុមហ៊ុនផង ។ នៅថ្ងៃឃាត់ខ្លួន ជនជាប់ចោទឈ្មោះ តែ ប៊ុនថេង ក៏មានវត្តមាននៅទីនោះ ហាងមហាលាភ ជាមួយឈ្មោះ [redacted] ប៊ុនរឿន ឈ្មោះ [redacted] វុទ្ធី និងតំណាងក្រុមហ៊ុន ដោយនៅពេលនោះជនជាប់ចោទឈ្មោះ [redacted] ប៊ុនថេង ជាអ្នករាប់លុយដែលបានទទួលពីតំណាងក្រុមហ៊ុនចំនួន ៤៥.០០០ ដុល្លារអាមេរិក បន្ថែមលើប្រាក់ដែលក្រុមហ៊ុនបានកក់នៅមន្ទីរចំនួន ៥.០០០ ដុល្លារអាមេរិក ដែលជនជាប់ចោទឈ្មោះ [redacted] ប៊ុនថេង ក៏ជាអ្នករាប់លុយនេះផងដែរ ។ ក្រៅពីអង្គហេតុនេះក៏បានស្តែងឱ្យឃើញពីសកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ប៊ុនថេង ថាបានប្រព្រឹត្ត យ៉ាងសកម្មភាពទាក់ទងនឹងការយកសេវាក្រៅផ្លូវច្បាប់ ដែលជនជាប់ចោទអះអាងថា បំពេញកិច្ចការគូសប្លង់ និងសេវាដែលបានចំណេញពី ៥០ ដុល្លារអាមេរិក ទៅ ១០០ ដុល្លារអាមេរិក ឬទៅ ១៥០ ដុល្លារអាមេរិក ដែលសកម្មភាពនេះជាសកម្មភាពល្មើសទៅនឹងច្បាប់ដែលបានកំណត់ថា ជាបទល្មើសវិតិក្រម និងបទ រំលោភអំណាច ។ ហេតុដូច្នេះដោយសារមានភស្តុតាង និងធាតុផ្សំគ្រប់គ្រាន់សម្រាប់ដាក់បន្ទុកទៅលើជនជាប់ចោទទាំងបីនាក់ ហើយជនជាប់ចោទទាំងបីនាក់ក៏ជានីតិជនមានស្មារតី មានសមត្ថភាព គ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ អំពើរបស់ជនជាប់ចោទក៏បានធ្វើអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់របៀបរៀបរយសង្គម និងសេចក្តីថ្លៃថ្នូររបស់មន្ត្រីរាជការសាធារណៈដែលច្បាប់បានកំណត់ថា ជាបទល្មើសព្រហ្មទណ្ឌ ។ ហេតុដូច្នេះ ដោយមានភស្តុតាងធាតុផ្សំគ្រប់គ្រាន់ក្នុងការដាក់បន្ទុកទៅលើជនជាប់ចោទ តំណាង អយ្យការស្នើសុំ៖ ១-រក្សារចោទប្រកាន់លើជនជាប់ចោទឈ្មោះ លៀម ប៊ុនរឿន ពីបទ វិតិក្រម រំលោភអំណាច និងសម្អាតប្រាក់ ប្រព្រឹត្តនៅខេត្តពោធិ៍សាត់ កាលពីអំឡុងឆ្នាំ២០១៦ រហូតដល់ថ្ងៃទី២៦-២៧ ខែកក្កដា ឆ្នាំ២០១៩ តាមបញ្ញត្តិមាត្រា ៥៩២ , មាត្រា ៥៩៣ នៃក្រមព្រហ្មទណ្ឌ , មាត្រា ៣៥ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និងតាមបញ្ញត្តិមាត្រា ៣ថ្មី , ២៩ថ្មី១ នៃច្បាប់ស្តីពីវិសោធនកម្ម មាត្រា ៣ , មាត្រា ២៩ និងមាត្រា ៣០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភាវរកម្ម ព្រមទាំងស្នើសុំធ្វើការរឹបអូសនូវទ្រព្យសម្បត្តិដែលមានដូចមានក្នុងសំណួមពរនៅក្នុងរបាយការណ៍សំយោគរបស់អង្គភាពប្រឆាំងអំពើពុករលួយលេខ ០១៤/១៩ របកអបភ ចុះថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០១៩ ។ ២-រក្សាបទចោទលើជនជាប់ចោទឈ្មោះ [redacted] វុទ្ធី និងឈ្មោះ [redacted] ប៊ុនថេង ពីបទ វិតិក្រម និង រំលោភអំណាច ប្រព្រឹត្តនៅខេត្តពោធិ៍សាត់ កាលពីថ្ងៃទី២៦-២៧ ខែកក្កដា ឆ្នាំ២០១៩ តាមបញ្ញត្តិមាត្រា ៥៩២ , មាត្រា

៥៩៣ នៃក្រមព្រហ្មទណ្ឌ , មាត្រា ៣៥ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ទុកនៅដដែល ។ ហេតុដូចនេះ តំណាងអយ្យការប្តឹងសុំ ក្រុមប្រឹក្សាជំនុំជម្រះធ្វើការវិនិច្ឆ័យ និងសម្រេចផ្តន្ទាទោសលើជនជាប់ចោទទាំងបីនាក់តាមច្បាប់។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **ប៊ុនរឿន** បានសន្និដ្ឋានការពារថា ៖ ផ្លូវតាមការពិនិត្យឯកសារ ការដេញដោលនាពេលសវនាការឃើញថា ពិតជាមានអង្គហេតុនៃបទល្មើសវិតិក្រម រំលោភអំណាច និងសម្អាតប្រាក់ ដែលប្រព្រឹត្តដោយឈ្មោះ [redacted] ប៊ុនរឿន ពិតប្រាកដកមែន ។ នៅគ្រប់ដំណាក់កាលនៃនីតិវិធីកូនក្តីខ្លួនបានសារភាពនូវកំហុសរបស់ខ្លួន ក៏ដូចជានៅក្នុងការដេញដោលនាពេលសវនាការនេះក៏បានសារភាពថា បានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការដែរ ។ ទន្ទឹមនឹងកំហុសទាំងនេះ ក្នុងនាមកូនក្តីខ្លួនជាប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តពោធិ៍សាត់ ក៏មានគុណសម្បត្តិ និងស្នាដៃមួយចំនួនក្នុងការដឹកនាំមន្ទីរដូចជា៖ ក្រៅពីសេវាដែលគាត់រត់ការ ១៤០ ករណី ក៏មានសេវាដែលគាត់បម្រើចុះបញ្ជីជាលក្ខណៈប្រព័ន្ធជូនប្រជាពលរដ្ឋដោយមិនយកកម្រៃជើងសារមានចំនួនទៅដល់ ៤៨.០០០ ករណី ដែលជាកិច្ចខិតខំប្រឹងប្រែងរបស់គាត់ក្នុងការជួយចុះបញ្ជីដីធ្លីជូនប្រជាពលរដ្ឋ ។ ជាងនេះទៀត កូនក្តីខ្លួនក៏បានជួយការងារសង្គមមួយចំនួន គាត់ជាក្រុមការងារចុះជួយសង្គមនៅសង្កាត់ព្រៃញី និងឃុំល ហើយបានកសាងនូវសមិទ្ធផលមួយចំនួនជូនប្រជាពលរដ្ឋក្រីក្រដូចជា ធ្វើផ្ទះជូនប្រជាពលរដ្ឋក្រីក្រ ផ្លូវថ្នល់ក្រាលគ្រួសក្រហម ដាក់លូ ស្ពានប្រឡាយ ជាដើម ។ ស្ថានភាពជម្ងឺលើសឈាម និងទឹកនោមផ្អែមរបស់កូនក្តីខ្លួនកាន់តែធ្ងន់ ហើយក្រុមគ្រួសាររបស់គាត់ក៏មានជម្ងឺប្រចាំកាយដែរព្រោះក្រោយគាត់ជាប់ឃុំឃាំងមួយរយៈប្រពន្ធគាត់បានឆ្លងទន្លេ ៧ខែ ហើយទាស់សសៃខ្ចី និងមានជម្ងឺទឹកនោមប្រៃ ដែលត្រូវការអ្នកថែទាំជាចាំបាច់ ។ ដោយឡែកកូនរបស់គាត់ដែលសម្រាលក្រោយនេះត្រូវចិញ្ចឹមក្នុងកែវតាំងពីឆ្លងទន្លេរួចមកដល់បច្ចុប្បន្ន ។ ម្យ៉ាងទៀត គាត់នៅមានកូនស្រីពីរនាក់ដែលជាអនីតិជនអាយុក្រោម ១០ឆ្នាំ ដោយកូនបងអាយុ ៨ឆ្នាំ កូនប្អូនអាយុ ៦ឆ្នាំ ។ ដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិ ស្នើសុំក្រុមប្រឹក្សាមេត្តាផ្តល់ស្ថានសម្រាលតាមមាត្រា ៧៣ និងមាត្រា ៧៤ នៃក្រមព្រហ្មទណ្ឌ ដល់កូនក្តីខ្លួនព្រោះគ្រួសារគាត់នេះត្រូវការគាត់ជាចាំបាច់ដើម្បីថែរក្សា ។ ម្យ៉ាងទៀតចំពោះទ្រព្យដែលជាកម្មវត្ថុនៅក្នុងដីកាសម្រេចបង្គរបស់ចៅក្រមស៊ើបសួរ ស្នើសុំឱ្យក្រុមប្រឹក្សាពិចារណានៅលើអង្គហេតុជាក់ស្តែងដូចការបញ្ជាក់របស់គាត់ដូចមានរថយន្ត ទ្រព្យទាំងអស់នោះថ្វីត្បិតតែមានប្រាក់សេវាខាងក្រៅផលនៃបទល្មើសចូលរួមក្នុងការទិញមែន ប៉ុន្តែក៏មានទ្រព្យដើមគាត់មួយចំនួនចូលរួមនៅក្នុងនោះដែរ ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **ប៊ុនរឿន** បានសន្និដ្ឋានថា ៖ ខ្លួនសុំឯកភាពទៅនឹងសេចក្តីសន្និដ្ឋានរបស់សហភាតាខ្លួនទាំងស្រុង ។ ខ្លួនស្នើសុំតុលាការមេត្តាផ្តល់ស្ថានសម្រាលដល់កូនក្តីខ្លួនឱ្យបានទាបបំផុតព្រោះថា បើពិនិត្យមើលទៅលើឥរិយាបទរបស់កូនក្តីខ្លួន គាត់មានការភ្ញាក់រលឹក ហើយឆ្លើយសារភាពគ្រប់ដំណាក់កាលទាំងអស់មិនបង្កការរាំងស្ទះដល់ការសាកសួរទេ ។ ទោះបីជាកូនក្តីខ្លួនបានប្រព្រឹត្តកំហុសមែន តែគាត់មានគុណសម្បត្តិជាច្រើនដូចដែលសហភាតាបានលើកឡើង ។ ក្រៅអំពីគុណសម្បត្តិដែលសហភាតាបានលើកឡើង កូនក្តីខ្លួនក៏មានគុណសម្បត្តិផ្សេងៗជាច្រើនទៀត ដូចជា ថវិកាមួយចំនួនដែលបានពីបទល្មើសគាត់បានយកទៅចំណាយលើការចាត់ចែងសេវាកម្មនៅក្នុងអង្គភាព ចំណាយលើការចុះសួរសុខទុក្ខប្រជាពលរដ្ឋ បរិចាគទៅមន្ត្រីខ្វះខាត និងស្ត្រីមេម៉ាយ ។ យោងតាមស្ថានភាពជម្ងឺរបស់កូនក្តីខ្លួន ស្នើសុំតុលាការផ្តល់ស្ថានសម្រាលទោសដល់កូនក្តីខ្លួនជាចាំបាច់ព្រោះថា តាមព័ត៌មានដែលទទួលបានពីក្មួយរបស់កូនក្តីខ្លួន នាពេលគាត់នៅក្នុងពន្ធនាគារសមាជិកគ្រួសារសុទ្ធតែមានជម្ងឺ ហើយថៃ្ងដន្យប្រពន្ធរបស់គាត់ឆ្លងទន្លេ ហើយប្រសិនបើមិនមានក្មួយរបស់គាត់ទៅទាន់ទេយឺតតែ ២ ទៅ ៣ម៉ោង គាត់អាចនឹងបាត់បង់ភរិយា និងកូន ព្រោះប្រពន្ធរបស់កាត់ឆ្លងទាសដែលភាសាខ្មែរហៅថា ជម្ងឺក្រឡាភ្លើង បើមិនទៅមន្ទីរពេទ្យបានទាន់ពេល

វេលានោះទេ ។ បច្ចុប្បន្នកូនរបស់គាត់កើតមិនគ្រប់ខែត្រូវចិញ្ចឹមក្នុងកែវ ដូចមានភស្តុតាងដែលបានដាក់ជូនតុលាការស្រាប់ ។ ជាចុងក្រោយចំពោះទ្រព្យសម្បត្តិ ខ្លួនទទួលស្គាល់ថា ទ្រព្យសម្បត្តិដែលធ្វើការរកឃើញនេះមួយចំនួនបានមកពីផលនៃបទល្មើស ប៉ុន្តែទ្រព្យសម្បត្តិមួយចំណែកទៀតក៏ទ្រព្យដោយសុចរិតរបស់គាត់ដែរ ដូច្នេះហើយខ្លួនស្នើសុំឱ្យលោកក្រុមប្រឹក្សាមេត្តាពិចារណា និងសម្រេចតាមច្បាប់ ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វុទ្ធី បានសន្និដ្ឋានថា ៖ តាមការពិភាក្សាដេញដោល តាមការស្តាប់ចម្លើយរបស់កូនក្តីខ្លួនឈ្មោះ [redacted] វុទ្ធី សុទ្ធតែបញ្ជាក់បានថា គាត់បានណែនាំមនុស្សម្នាក់ជាជាងថតរូប (ដោយគាត់ពុំដឹងថាជាក្រុមហ៊ុនទេ) ទៅឱ្យឈ្មោះ [redacted] ប៊ុនថេង ។ តាមចម្លើយរបស់ឈ្មោះ [redacted] ប៊ុនថេង និងចម្លើយរបស់ឈ្មោះ [redacted] ប៊ុនរឿន សុទ្ធតែបានបញ្ជាក់ថា ឈ្មោះ [redacted] វុទ្ធី ពិតជាមិនពាក់ព័ន្ធនឹងអង្គហេតុនៃអំពើទទួលប្រាក់ចំនួន ១០០.០០០ ដុល្លារអាមេរិកនៅក្នុងអង្គហេតុនេះទេ ។ ឆ្លងតាមចម្លើយសារភាពរបស់ឈ្មោះ [redacted] វុទ្ធី បានបញ្ជាក់ថា គាត់ពិតជាធ្វើសកម្មភាពនៅក្នុងថ្ងៃនោះមែន ប៉ុន្តែខ្លួនស្នើសុំឱ្យតុលាការពិចារណាមាត្រា ៥២៩ ស្តីអំពីបទ មិនប្តឹងបរិហារបទឧក្រិដ្ឋ និងការលើកលែងព្រោះ ឈ្មោះ [redacted] វុទ្ធី គ្មានបំណងចង់បានចំណែកជាប្រាក់នៅក្នុងអង្គហេតុនេះទេ ។ កំហុសរបស់គាត់គឺបានដឹងអង្គហេតុនេះតែមិនបានប្តឹងបរិហារទៅសមត្ថកិច្ច ។ នៅក្នុងសវនាការ និងក្នុងនីតិវិធីនៃការស៊ើបអង្កេតកន្លងមក ឈ្មោះ [redacted] វុទ្ធី តែងតែសហការណ៍ពុំមានការរំខាន ឬបង្កព្យសនកម្មណាមួយធ្វើឱ្យមានការលំបាកដល់ដំណើរការនីតិវិធីឡើយ ។ ហេតុនេះ ខ្លួនស្នើសុំក្រុមប្រឹក្សាមេត្តាពិចារណាសម្រេចដោយ
ពិនិត្យលើមាត្រា ៥២៩ នៃក្រមព្រហ្មទណ្ឌ និងស្នើសុំក្រុមប្រឹក្សាមេត្តាបន្ធូរបន្ថយដល់ឈ្មោះ ជាង វុទ្ធី ។

-លោក [redacted] **ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ** [redacted] **វុទ្ធី** បានសន្និដ្ឋានថា ៖ កូនក្តីខ្លួនបានទទួលស្គាល់នូវកំហុស តែកូនក្តីខ្លួនក៏បញ្ជាក់ផងដែរថា គាត់ពុំទទួលបានផលប្រយោជន៍ទេ ។ អ្វីដែលជាកំហុសរបស់កូនក្តីខ្លួនគឺគាត់បានដឹងតែពុំបានប្តឹងបរិហារនូវបទឧក្រិដ្ឋស្របទៅនឹងអ្វីដែលសហភាគាបានលើកឡើង ។ កូនក្តីខ្លួនមិនថា នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ដំណាក់កាលអយ្យការ ដំណាក់កាលស៊ើបសួរ ឬដំណាក់កាលសវនាការនោះទេ គាត់បានបង្ហាញឆន្ទៈទទួលស្គាល់កំហុសដែលគាត់បានធ្វើ ហើយមិនបង្កឱ្យមានវិបាកទៅដល់ដំណើរការជំនុំជម្រះក្តីឡើយ ។ កូនក្តីខ្លួនមានកូនតូចដែលត្រូវគ្រប់គ្រងថែរក្សា ហើយបន្ទុកគ្រួសារដ៏ធំនេះគឺត្រូវធ្លាក់មកលើកូនក្តីខ្លួន ។ ដូចនេះ សូមក្រុមប្រឹក្សាជំនុំជម្រះមេត្តាផ្តល់នូវស្ថានសម្រាលទោសដល់កូនក្តីខ្លួន ។

-លោក [redacted] **ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ** [redacted] **វុទ្ធី** បានសន្និដ្ឋានថា ៖ ក្រោយពីបានពិភាក្សាដេញដោលក្នុងអង្គសវនាការនេះ កូនក្តីខ្លួនត្រូវបានចោទប្រកាន់ពីបទ វិតិក្រម និងបទរំលោភអំណាច ។ ទាក់ទងនឹងការចោទប្រកាន់ពីបទ វិតិក្រម កូនក្តីខ្លួនពុំមានការគាបសង្កត់ភាគីណាមួយដើម្បីទទួលបានប្រាក់ចំនួន ១០.០០០ ដុល្លារអាមេរិក នេះទេ ។ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៩ ដោយសារតែកូនក្តីខ្លួនពុំមានឡានជិះ ទើបឈ្មោះ [redacted] ប៊ុនថេង ហៅកូនក្តីខ្លួនឈ្មោះ [redacted] វុទ្ធី ទៅហូបបាយជាមួយគ្នាតែថៃ្ងដដែលស្រាប់តែត្រូវលោក [redacted] ប៊ុនរឿន ទូរស័ព្ទហៅក៏ទៅជាមួយតែម្តង ទើបគាត់អត់បានដឹងពីការទទួលប្រាក់នៅថ្ងៃនោះទេ ។ ដូចនេះ ខ្លួនស្នើសុំក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិចារណាមាត្រា ៥២៩ នៃក្រមព្រហ្មទណ្ឌ ។

-លោក [redacted] **ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ** [redacted] **ប៊ុនថេង** បានសន្និដ្ឋានថា ៖ ឆ្លងកាត់ការពិភាក្សាដេញដោលនាពេលសវនាការ ចម្លើយរបស់កូនក្តីខ្លួននៅគ្រប់ដំណាក់កាលនីតិវិធី កូនក្តីខ្លួនមិនយល់ច្បាស់ថាអ្វីដែលកូនក្តីខ្លួនធ្វើជាអំពើខុសច្បាប់នោះទេ ។ ការណ៍ដែលគាត់យកសេវា ១០០ ឬ ១៥០ ដុល្លារអាមេរិក ដើម្បីគូសប្លង់នោះ គាត់មិនយល់ថា នេះជាអំពើខុសច្បាប់ទេ ។ អង្គហេតុដែលកើតឡើងនៅថ្ងៃទី២៦-២៧ ខែកក្កដា ឆ្នាំ២០១៩ គាត់ពិតជាបានទំនាក់ទំនងទៅក្រុមហ៊ុនជាដំបូងមែន តែគាត់គ្មានចេតនាណាមួយលាក់គំបាំងពីប្រធានរបស់គាត់ទេ ។ គាត់តែង

តែសួរលោក [redacted] ប៊ុនរឿន ជានិច្ច ហើយគាត់ក៏មិនបានទាមទារពីក្រុមហ៊ុន ឬតំណាងក្រុមហ៊ុនថា ត្រូវតែបង់សេវាក្រៅផ្លូវច្បាប់ឱ្យគាត់ដើម្បីឱ្យគាត់ណែនាំជូនទៅប្រធានមន្ទីរ ឬមួយនរណានោះដែរ ។ គាត់តែងប្រាប់ទៅតំណាងក្រុមហ៊ុនគ្រប់ដំណាក់កាលទាំងអស់ថា ចាំសួរមេសិន ហើយក៏ពុំបានទាមទារសេវាអ្វីពីតំណាងក្រុមហ៊ុនដែរ ។ នាពេលដែលកូនក្តីខ្លួនបំពេញភារកិច្ចជាមន្ត្រីនៅច្រកចេញចូលតែមួយសាលាខេត្តពោធិ៍សាត់ គាត់ក៏មិនបានយកតួនាទីរបស់គាត់ទៅគាបសង្កត់ប្រជាពលរដ្ឋថា ត្រូវតែអោយគាត់គូសប្លង់ ឬមួយឱ្យគាត់រត់ការណាមួយទេ ។ នេះជាភស្តុតាង បញ្ជាក់ថា កូនក្តីខ្លួនពុំបានប្រព្រឹត្តបទល្មើសរំលោភអំណាចឡើយ ។ នៅតំណាក់កាលស៊ើបសួរ និងតំណាក់កាលស៊ើបអង្កេត គាត់បានឆ្លើយថាគាត់បានយកតែតម្លៃពលកម្មគូសប្លង់ប៉ុណ្ណោះ ហើយគាត់មិនយល់ថា ការដែលគាត់ទារតម្លៃគូសប្លង់ជាអំពើខុសច្បាប់ឡើយ ។ ដូច្នេះ ខ្លួនស្នើសុំក្រុមប្រឹក្សាជំនុំជម្រះ ឱ្យកូនក្តីខ្លួនរួចផុតបទចោទពីបទ រំលោភអំណាច និងស្នើសុំបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនក្នុងបទ វិតិក្រម ដើម្បីឱ្យកូនក្តីខ្លួនបានយកចំណេះដឹងរបស់គាត់ទៅបម្រើសង្គម ព្រោះគាត់ជាសាស្ត្រាចារ្យម្នាក់ដែលបង្រៀននៅសាកលវិទ្យាល័យក្នុងខេត្តបាត់ដំបងដែរ ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនរឿន** បាននិយាយសំដីចុងក្រោយថា៖ ខ្លួនមានការសោកស្តាយជាពន់ពេកដោយបានប្រព្រឹត្តខុសឆ្គងដោយអចេតនា ។ ខ្លួនសុំការខន្តីអភ័យទោសចំពោះសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ដែលជាបិតាសន្តិភាព ។ ខ្លួនស្នើសុំក្រុមប្រឹក្សាជំនុំជម្រះមេត្តាសម្រាលទោសដល់ខ្លួនព្រោះខ្លួនមានម្តាយជាស្ត្រីមេម៉ាយចាស់ជរាអាយុជាង ៧០ឆ្នាំ មានជម្ងឺទឹកនោមផ្អែម បេះដូង និងជំងឺសតិអារម្មណ៍ បន្ទាប់ពីឪពុកខ្លួនស្លាប់ជាង ១០ឆ្នាំ ។ បន្ទាប់ពីខ្លួនមានបញ្ហាមក ប្រពន្ធខ្លួនមានជំងឺស្ត្រេសធ្ងន់ធ្ងរ ហើយសម្ពាធឈាមឡើងខ្ពស់មិនចុះទើបបណ្តាលឱ្យសម្រាលកូនមុនកំណត់ ។ បច្ចុប្បន្នកូនខ្លួនត្រូវចិញ្ចឹមក្នុងកែវ ហើយកូនស្រីទាំងពីររបស់ខ្លួនត្រូវការភាពកក់ក្តៅពីខ្លួន ។ សព្វថ្ងៃខ្លួនបានកុហកកូនថាខ្លួនទៅក្រៅប្រទេស ។ ចំពោះខ្លួនផ្ទាល់ក៏មានជម្ងឺទឹកនោមផ្អែម លើសជាតិអាស៊ីត ខ្លាញ់រុំបេះដូងជាងបីឆ្នាំមកហើយ ត្រូវការការព្យាបាលជាប្រចាំ ។

-ជនជាប់ចោទឈ្មោះ [redacted] **វុទ្ធី** បាននិយាយសំដីចុងក្រោយថា៖ ខ្លួនស្នើសុំតុលាការសម្រាលទោសដល់ខ្លួនផងព្រោះខ្លួនត្រូវមើលថែម្តាយចាស់អាយុ ៧៨ឆ្នាំ កូនតូច និងប្រពន្ធដែលមានជម្ងឺផ្លូវចិត្ត និងជំងឺលើសឈាម ។

-ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនថេង** បាននិយាយសំដីចុងក្រោយថា៖ ខ្លួនស្នើសុំឱ្យតុលាការបន្ធូរបន្ថយទោសផងព្រោះខ្លួនជាមន្ត្រីទើបមកបំពេញកិច្ចការងារទេ ។ ចំពោះក្រុមគ្រួសារក៏ខ្លួនត្រូវការខ្លួនជាចាំបាច់ព្រោះប្អូនរបស់ខ្លួនកំពុងសិក្សា ។ ម្យ៉ាងទៀត ខ្លួនក៏ជាសាស្ត្រាចារ្យម្នាក់ដែរ ដែលមានបទពិសោធន៍ផ្នែកវិស្វករ ៨ឆ្នាំហើយ ខ្លួនចង់ផ្ទេរបទពិសោធន៍ទៅអោយប្អូនៗជំនាន់ក្រោយ ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយជនរងគ្រោះ

-ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី

-ក្រោយពីបានស្តាប់អំណានឯកសារនានាដែលមាននៅក្នុងសំណុំរឿង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយ

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា

-ក្រោយពីបានពិចារណា និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ



Scanned with CamScanner

## សំអាងហេតុ

១-តាមដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ៥៨១០ "រ" ដ.ជ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩ ចៅក្រមស៊ើបសួរបានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] **ប៊ុនវឿន** ទៅជំនុំជម្រះ ពីបទ **វិតិក្រម រំលោភអំណាច** និង **សម្អាតប្រាក់** ប្រព្រឹត្តនៅខេត្តពោធិ៍សាត់ កាលពីអំឡុងឆ្នាំ២០១៦ រហូតដល់ថ្ងៃទី២៦-២៧ ខែកក្កដា ឆ្នាំ២០១៩ បទល្មើសមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥៩២ មាត្រា ៥៩៣ នៃក្រមព្រហ្មទណ្ឌ មាត្រា ៣៥ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និងតាមបញ្ញត្តិមាត្រា ៣ថ្មី ២៩ថ្មី១ នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ៣ មាត្រា ២៩ និងមាត្រា ៣០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងជនជាប់ចោទឈ្មោះ [redacted] **វុទ្ធី** និងឈ្មោះ [redacted] **ប៊ុនថេង** ពីបទ **វិតិក្រម** និង **រំលោភអំណាច** ប្រព្រឹត្តនៅខេត្តពោធិ៍សាត់ កាលពីថ្ងៃទី២៦-២៧ ខែកក្កដា ឆ្នាំ២០១៩ តាមបញ្ញត្តិមាត្រា ៥៩២ មាត្រា ៥៩៣ នៃក្រមព្រហ្មទណ្ឌ និង មាត្រា ៣៥ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ។

២-ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនវឿន** ពិតជាមន្ត្រីរាជការសាធារណៈ ដែលបានចូលបម្រើការងារតាំងពីឆ្នាំ ១៩៩៨ ហើយត្រូវបានតែងតាំងឱ្យបំពេញមុខងារជាប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និងសុរិយោដីខេត្តពោធិ៍សាត់ នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ រហូតដល់ថ្ងៃឃាត់ខ្លួន ។ ជនជាប់ចោទឈ្មោះ [redacted] **វុទ្ធី** ក៏ជាមន្ត្រីរាជការសាធារណៈដែលបានចូលបម្រើការងារតាំងពីឆ្នាំ ១៩៩៩ ហើយត្រូវបានតែងតាំងឱ្យបំពេញការងារជាអនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និងសុរិយោដីខេត្តពោធិ៍សាត់ តាំងពីឆ្នាំ២០០៩ រហូតដល់ថ្ងៃឃាត់ខ្លួន ។ ចំណែកជនជាប់ចោទឈ្មោះ [redacted] **ប៊ុនថេង** ជាមន្ត្រីរាជការសាធារណៈដែលបានចូលបម្រើការងារជាមន្ត្រីនៅមន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និងសុរិយោដីខេត្តពោធិ៍សាត់ តាំងពីឆ្នាំ២០១៨ រហូតមកដល់ថ្ងៃឃាត់ខ្លួន ។

៣-ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនវឿន** ពិតបានទាមទារសេវាក្រៅច្បាប់ចំនួន ១០០.០០០ (មួយរយពាន់) ដុល្លារអាមេរិក ពីតំណាងក្រុមហ៊ុនដើម្បីសម្រួល និងជម្រុញដល់ការផ្តល់ជូននូវលិខិតអនុញ្ញាតសាងសង់ (សំណង់ស្ទូឡា) កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩ នៅបន្ទប់ការិយាល័យរបស់ខ្លួនក្នុងមន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និងសុរិយោដីខេត្តពោធិ៍សាត់ ។ ជាលទ្ធផលនៃការទាមទារខាងលើនេះ ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនវឿន** ក៏បានទទួលប្រាក់ពីតំណាងក្រុមហ៊ុនចំនួន ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩ និងចំនួន ៤៥.០០០ (សែសិបប្រាំពាន់) ដុល្លារអាមេរិក នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៩ ។

៤-ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនថេង** បានចូលរួមយ៉ាងសកម្មភាពនៅក្នុងអង្គហេតុទាមទារ និងទទួលប្រាក់រវាងតំណាងក្រុមហ៊ុន និងជនជាប់ចោទឈ្មោះ [redacted] **ប៊ុនវឿន** ។ ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនថេង** ជាអ្នកនាំឱ្យមានការជួបគ្នា ជាអ្នករៀបចំលិខិតស្នាមតាមការស្នើសុំរបស់ក្រុមហ៊ុន ជាអ្នកជួយគណនានូវចំនួនទឹកប្រាក់ និងជាអ្នករាប់នូវចំនួនប្រាក់ដែលតំណាងក្រុមហ៊ុនប្រគល់ឱ្យជនជាប់ចោទឈ្មោះ [redacted] **ប៊ុនវឿន** ។

៥-ជនជាប់ចោទឈ្មោះ [redacted] **វុទ្ធី** បើទោះបីជាមិនបានចូលរួមសកម្មនៅក្នុងទំនាក់ទំនងរវាងតំណាងក្រុមហ៊ុន និងជនជាប់ចោទឈ្មោះ [redacted] **ប៊ុនវឿន** ក៏នៅតែអាចសន្និដ្ឋានបានថា ជនជាប់ចោទមានការចូលរួមនៅក្នុងអង្គហេតុនេះ។ ការចូលរួមរបស់ជនជាបចោទស្តែងឡើងតាមរយៈ ការណែនាំឱ្យមានការទំនាក់ទំនងជាមួយឈ្មោះ [redacted] **ប៊ុនថេង** ពាក់ព័ន្ធទៅនឹងការស្នើសុំលិខិតអនុញ្ញាតសាងសង់ (សំណង់ស្ទូឡា) បើទោះបីជាបានដឹងថា សេវាសាធារណៈរបស់មន្ទីរត្រូវផ្តល់ជូននៅច្រកចេញចូលតែមួយ។ ជនជាប់ចោទឈ្មោះ [redacted] **វុទ្ធី** បានទទួលព័ត៌មាន និងបានដឹងយ៉ាងច្បាស់អំពីការទាមទារ និងការទទួលប្រាក់ដោយជនជាប់ចោទឈ្មោះ [redacted] **ប៊ុនវឿន** ពីតំណាងក្រុមហ៊ុន តែជនជាប់ចោទនៅតែចូលរួម និងជួយដល់កិច្ចការមួយចំនួន ។ ជនជាប់ចោទឈ្មោះ [redacted] **វុទ្ធី** បានជួយឈ្មោះ [redacted] **ប៊ុនថេង** រៀបចំលិខិតស្នាមតាមការស្នើ



Scanned with CamScanner

ស៊ុំរបស់តំណាងក្រុមហ៊ុន ។ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៩ ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី ក៏បានចូលរួមនាពេលតំណាងក្រុមហ៊ុនប្រគល់ប្រាក់ចំនួន ៤៥.០០០ (សែសិបប្រាំពាន់) ដុល្លារអាមេរិក ឱ្យទៅឈ្មោះ [redacted] ប៊ុនរឿន ។ ចេតនាទុច្ចរិតរបស់ឈ្មោះ [redacted] វុទ្ធី បានស្តែងកាន់តែច្បាស់នាពេលប្រគល់ និងកំពុងរាប់ប្រាក់ ដោយជនជាប់ចោទឈ្មោះ [redacted] វុទ្ធី បានអះអាង និងចេញទៅក្រៅបន្ទប់ដើម្បីឃាមផ្លូវថែមទៀតផង ។

៦-ជនជាប់ចោទឈ្មោះ [redacted] ប៊ុនរឿន ក្នុងមុខងារជាប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និង សុរិយោដីខេត្តពោធិ៍សាត់ បានយល់ដឹងយ៉ាងជ្រួតជ្រាបអំពីការយកកម្រៃសេវាសាធារណៈរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និងសុរិយោដី ពីប្រជាពលរដ្ឋស្របតាមប្រកាសអន្តរក្រសួងរវាងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ចំណែកជនជាប់ចោទឈ្មោះ [redacted] វុទ្ធី និងជនជាប់ចោទឈ្មោះ [redacted] ប៊ុនថេង បើទោះបីជាមិនមានការស៊ីជម្រៅច្បាស់លាស់ ក៏ជនជាប់ចោទមានការយល់ដឹងជាទូទៅអំពីរបៀប និងការទទួលនូវកម្រៃសេវាសាធារណៈពីប្រជាពលរដ្ឋរបស់មន្ទីរដែលខ្លួនបំពេញការងារដែរ ។

៧-ជនជាប់ចោទឈ្មោះ [redacted] ប៊ុនរឿន ជនជាប់ចោទឈ្មោះ [redacted] វុទ្ធី និងជនជាប់ចោទឈ្មោះ [redacted] ប៊ុនថេង សុទ្ធតែបានដឹងរួចជាស្រេចថា ការផ្តល់សេវា និងការបង់កម្រៃសេវាសាធារណៈត្រូវធ្វើឡើងនៅច្រកចេញចូលតែមួយ ។ ជនជាប់ចោទស្ថិតក្នុងស្ថានភាពដែលមានការយល់ដឹងថា ការទទួល និងចូលរួមទទួលប្រាក់ពីប្រជាពលរដ្ឋពាក់ព័ន្ធទៅនឹងសេវាសាធារណៈរបស់មន្ទីរដែលខ្លួនបំពេញការងារក្រៅអំពីកន្លែងផ្តល់សេវានៅច្រកចេញចូលតែមួយ និងដោយពុំមានវិក័យប័ត្រជាអំពើមិនត្រឹមត្រូវ ។

៨-មន្ត្រីរាជការសាធារណៈត្រូវបំពេញមុខងាររបស់ខ្លួនជូនប្រជាពលរដ្ឋដោយតម្លាភាព សុច្ចរិតភាព និងភាពស្មោះត្រង់ ហើយត្រូវបានហាមឃាត់ក្នុងការទទួលបាននូវកម្រៃនានាចេញអំពីការបំពេញតួនាទីនេះ ។ បើទោះបីជាជនជាប់ចោទឈ្មោះ [redacted] ប៊ុនរឿន បានអះអាងថា ខ្លួនមានការភាន់ច្រលំថា ការទទួលយកកម្រៃពីប្រជាពលរដ្ឋដើម្បីជម្រុញការផ្តល់សេវាឱ្យបានកាន់តែ ឆាប់រហ័ស ពុំត្រូវបានហាមឃាត់ដោយប្រកាសលេខ ៧៦ ប្រក/ដ.ន.ស ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៩ គឺជាអំពើត្រឹមត្រូវ ក៏ការភាន់ច្រឡំនេះមិនមែនជាយុត្តិកម្មដែលនាំឱ្យជនជាប់ចោទអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌនោះដែរ ។

៩-ជនជាប់ចោទឈ្មោះ [redacted] ប៊ុនថេង បើទោះបីជាទើបនឹងចូលបម្រើការងារជាមន្ត្រីរាជការសាធារណៈ ជនជាប់ចោទត្រូវបានជ្រើសរើសដោយឆ្លងកាត់ការប្រលងប្រជែង និងទទួលបាននូវការបណ្តុះបណ្តាលទើបអាចក្លាយជាមន្ត្រីពេញសិទ្ធិដែលមានការយល់ដឹងគ្រប់គ្រាន់ក្នុងការបំពេញមុខងាររបស់ខ្លួន ។ ជនជាប់ចោទឈ្មោះ [redacted] ប៊ុនថេង ក៏បានយល់ជ្រួតជ្រាបអំពីសេវាសាធារណៈរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និងសុរិយោដីខេត្តពោធិ៍សាត់ ដែលផ្តល់ជូនប្រជាពលរដ្ឋនៅច្រកចេញចូលតែមួយ ។ បើទោះបីជាឈ្មោះ [redacted] ប៊ុនថេង បានអះអាងថា ជនជាប់ចោទមានការភាន់ច្រឡំថា ការទទួលកម្រៃដើម្បីជម្រុញ និងដើម្បីសម្រួលដល់ការងារផ្តល់សេវារបស់មន្ទីរគឺជាអំពើត្រឹមត្រូវមិនមែនជាយុត្តិកម្មដើម្បីរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ។

១០-ក្រៅអំពីការទាមទារ និងការទទួលប្រាក់ពីតំណាងក្រុមហ៊ុនដើម្បីសម្របសម្រួល និងជម្រុញដល់ការផ្តល់ជូននូវលិខិតអនុញ្ញាតសាងសង់ (សំណង់សួឡា) ជនជាប់ចោទឈ្មោះ [redacted] ប៊ុនរឿន ក៏បានទទួលនូវសេវាក្រៅច្បាប់ជាច្រើនទៀតដើម្បីសម្របសម្រួល និងជម្រុញចំពោះការផ្តល់សេវាសាធារណៈរបស់មន្ទីរដែលជនជាប់ចោទបំពេញការងារ ។ កម្រៃសេវាក្រៅច្បាប់ដែលជនជាប់ចោទឈ្មោះ [redacted] ប៊ុនរឿន បានទទួលតាំងពីឆ្នាំ២០១៦ មកដល់ពេលឃាត់ខ្លួនមានចំនួនមិនតិចជាង ១៤០ ករណី ហើយទទួលបាននូវប្រាក់ចំនួន ៣៧២.៧៤៧ (បីរយចិតសិបពីរពាន់ និងប្រាំពីររយសែប



Scanned with CamScanner

សិបប្រាំពីរ) ដុល្លារអាមេរិក និងចំនួន ៤៩.០០០.០០០ (សែសិបប្រាំបួនលាន) រៀល ដោយមិនទាន់រាប់បញ្ចូលនូវទឹកប្រាក់ចំនួន ២០.០០០ (ម្ភៃពាន់) ដុល្លារអាមេរិក របស់ឈ្មោះ [redacted]ទី នៅឡើយ ។

១១-ស្របតាមការយល់ឃើញចាប់ពីចំណុចទី២ ដល់ចំណុចទី១០ នៃសំអាងហេតុឃើញថា ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនវឿន** ក្នុងឋានៈជាមន្ត្រីរាជការសាធារណៈពិតជាបានទាមទារ និងទទួលនូវប្រាក់ដែលខ្លួនបានដឹងថា លើសពីចំនួនដែលត្រូវបង់ (សេវាក្រៅច្បាប់) ពីប្រជាពលរដ្ឋនាពេលប្រើប្រាស់សេវារបស់មន្ទីរដែលខ្លួនបំពេញការងារមែន ។ ចំពោះជនជាប់ចោទឈ្មោះ[redacted] **វុទ្ធី** និងជនជាប់ចោទឈ្មោះ[redacted] **ប៊ុនថេង** ដែលជាមន្ត្រីរាជការសាធារណៈនៃមន្ទីរឃើញថាពិតជាមានការព្រមព្រៀងដោយផ្ទាល់ជាមួយជនជាប់ចោទឈ្មោះ [redacted] **ប៊ុនវឿន** ក្នុងសកម្មភាពដែលឈ្មោះ [redacted] **ប៊ុនវឿន** បានទាមទារ និងទទួលនូវប្រាក់ពីតំណាងក្រុមហ៊ុនពាក់ព័ន្ធទៅនឹងការផ្តល់ជូននូវលិខិតអនុញ្ញាតសាងសង់ (សំណង់សូឡា) ដែលលើសពីចំនួនដែលក្រុមហ៊ុនត្រូវបង់ ។

១២-យោងតាមបញ្ញត្តិមាត្រា ៥៩២ នៃក្រមព្រហ្មទណ្ឌ បទល្មើសវិតិក្រម ជាអំពើរបស់អ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោតដែល: ១-ទាមទារ ឬទទួល ជាសិទ្ធិ ជាពន្ធ ជាអាករ នូវចំនួនប្រាក់ដែលខ្លួនបានដឹងថា មិនត្រូវបង់ ឬដែលលើសពីចំនួនដែលគេត្រូវបង់ ២-យល់ព្រមក្រោមរូបភាពណាមួយ និងដោយមូលហេតុណាមួយក៏ដោយ ធ្វើការលើកលែង ឬការលោះលាចំពោះការបង់ពន្ធ ឬអាករដែលខ្លួនដឹងថាខុសច្បាប់ ។

១៣-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនវឿន** ក្នុងមុខងារជាមន្ត្រីរាជការសាធារណៈបានទទួលនូវប្រាក់ជាកម្រៃសេវាក្រៅច្បាប់ដែលជនជាប់ចោទបានដឹងថា លើសពីចំនួនដែលត្រូវបង់ជូនរដ្ឋចំពោះការផ្តល់សេវាសាធារណៈរបស់អង្គភាពដែលខ្លួនបំពេញការងារ តាំងពីអំឡុងឆ្នាំ២០១៦ រហូតមកដល់ថ្ងៃទី២៦-២៧ ខែកក្កដា ឆ្នាំ២០១៩ ជាបទល្មើស **វិតិក្រម** តាមបញ្ញត្តិមាត្រា ៥៩២ នៃក្រមព្រហ្មទណ្ឌ ។

១៤-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនវឿន** ក្នុងមុខងារជាមន្ត្រីរាជការសាធារណៈធ្វើសកម្មភាពទាមទារ និងទទួលនូវប្រាក់ពីក្រុមហ៊ុនដើម្បីជម្រុញដល់ការផ្តល់ជូនលិខិតអនុញ្ញាតសាងសង់ (សំណង់សូឡា) ដែលជនជាប់ចោទបានដឹងថា លើសពីចំនួនដែលត្រូវបង់កាលពីថ្ងៃទី២៦-២៧ ខែកក្កដា ឆ្នាំ២០១៩ និងអំពើរបស់ជនជាប់ចោទក្នុងមុខងារជាមន្ត្រីរាជការសាធារណៈធ្វើសកម្មភាពទទួលនូវប្រាក់ពីប្រជាពលរដ្ឋដើម្បីជម្រុញដល់ផ្តល់ជូននូវសេវាសាធារណៈរបស់មន្ទីររបស់ខ្លួនដែលជនជាប់ចោទបានដឹងថា លើសពីចំនួនដែលត្រូវបង់កាលពីអំឡុងឆ្នាំ២០១៦ រហូតដល់ថ្ងៃទី២៦-២៧ ខែកក្កដា ឆ្នាំ២០១៩ គឺជាបទល្មើស **វិតិក្រម** តាមបញ្ញត្តិមាត្រា ៥៩២ នៃក្រមព្រហ្មទណ្ឌ ។

១៥-អំពើរបស់ជនជាប់ចោទឈ្មោះ[redacted] **វុទ្ធី** និងជនជាប់ចោទឈ្មោះ[redacted] **ប៊ុនថេង** ក្នុងមុខងារជាមន្ត្រីរាជការសាធារណៈ មានការព្រមព្រៀងដោយផ្ទាល់ក្នុងសកម្មភាពដែលជនជាប់ចោទឈ្មោះ [redacted] **ប៊ុនវឿន** ទាមទារ និងទទួលនូវប្រាក់ពីក្រុមហ៊ុនដើម្បីផ្តល់ជូនលិខិតអនុញ្ញាតសាងសង់ (សំណង់សូឡា) ដែលជនជាប់ចោទបានដឹងថា លើសពីចំនួនដែលត្រូវបង់កាលពីថ្ងៃទី២៦-២៧ ខែកក្កដា ឆ្នាំ២០១៩ គឺជាបទល្មើស **វិតិក្រម** តាមបញ្ញត្តិមាត្រា ៥៩២ នៃក្រមព្រហ្មទណ្ឌ ។

១៦-ជារួម តាមរបាយការណ៍របស់សមត្ថកិច្ចនគរបាលយុត្តិធម៌ ចម្លើយសារភាពរបស់ជនជាប់ចោទ ព្រមទាំងភស្តុតាងដែលប្រមូលបាននៅក្នុងសំណុំរឿង តុលាការយល់ឃើញថា មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ[redacted] **ប៊ុនវឿន** ពីបទ **វិតិក្រម** ប្រព្រឹត្តតាំងពីអំឡុងឆ្នាំ២០១៦ រហូតមកដល់ថ្ងៃទី២៦-២៧ ខែកក្កដា ឆ្នាំ២០១៩ នៅចំណុចខេត្តពោធិ៍សាត់ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥៩២ និងមាត្រា ៥៩៣ នៃក្រមព្រហ្មទណ្ឌ និងលើជនជាប់ចោទឈ្មោះ [redacted] **វុទ្ធី** និងជនជាប់ចោទឈ្មោះ[redacted] **ប៊ុនថេង** ពីបទ **វិតិក្រម** ប្រព្រឹត្តកាលពីថ្ងៃទី២៦-២៧ ខែកក្កដា



Scanned with CamScanner

ឆ្នាំ២០១៩ នៅចំណុចខេត្តពោធិ៍សាត់ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥៩២ និងមាត្រា ៥៩៣ នៃក្រមព្រហ្មទណ្ឌ ។

១៧-ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនរឿន** ក្នុងតួនាទីជាប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសូរិយោដីខេត្តពោធិ៍សាត់ជាអ្នកគ្រប់គ្រងរួមនៅក្នុងស្ថាប័នមានភារកិច្ចពិនិត្យ និងសម្រេចរាល់ឯកសារ និងកិច្ចការផ្សេងៗ ។ តាមឯកសារខ្សែវីដេអូដែលថតសកម្មភាពនៅក្នុងបន្ទប់ការិយាល័យរបស់ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនរឿន** ចាប់ពីថ្ងៃទី២២ ដល់ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៩ ឃើញថា ជនជាប់ចោទបានទទួលសេវាក្រៅច្បាប់ជាច្រើនពីប្រជាពលរដ្ឋ និងពីមន្ត្រីក្រោមឱវាទរបស់ខ្លួនដែលទទួលបានពីប្រជាពលរដ្ឋ ។ ជនជាប់ចោទថែមទាំងបានណែនាំមន្ត្រីក្រោមឱវាទឱ្យទទួលកម្រៃសេវាក្រៅច្បាប់ (រត់ការ) ពីប្រជាពលរដ្ឋដែលមានបំណងប្រើប្រាស់សេវា ។ តាមកំណត់ត្រានៅក្នុងសៀវភៅចំនួនប្រាំក្បាលរបស់ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនរឿន** បានបង្ហាញឱ្យឃើញថា ជនជាប់ចោទបានទទួលសេវាក្រៅច្បាប់ពីប្រជាពលរដ្ឋសរុបចំនួនមិនតិចជាង ១៤០ ករណី ។

១៨-យោងតាមបញ្ញត្តិមាត្រា ៣៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ បានបង្ហាញថា អំពើប្រព្រឹត្តដោយអ្នករាជការសាធារណៈ ឬដោយពលរដ្ឋដែលទទួលអាណត្តិសាធារណៈតាមការបោះឆ្នោតនៅក្នុងការបំពេញមុខងាររបស់ខ្លួន ឬក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ចាត់វិធានរារាំងការអនុវត្តច្បាប់ ដើម្បីទទួលបានដោយខុសច្បាប់នូវអត្ថប្រយោជន៍ណាមួយ ជាបទល្មើស ***រំលោភអំណាច*** ។ ជាងនេះទៀត កថាខណ្ឌទី២ នៃបញ្ញត្តិដដែលនេះក៏បានបញ្ញត្តិផងដែរថា បទល្មើសរំលោភអំណាចនេះនឹងត្រូវផ្តន្ទាទោសស្ថានទម្ងន់ ប្រសិនបើបទល្មើសនេះមានប្រសិទ្ធភាព។

១៩-ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនរឿន** ជាមន្ត្រីរាជការសាធារណៈ ក្នុងតួនាទីជាប្រធានស្ថាប័នដែលមានភារកិច្ចពិនិត្យ និងសម្រេចនូវកិច្ចការនានាបានប្រើប្រាស់តួនាទីរបស់ខ្លួន និងអង្គភាពរដ្ឋចាត់វិធានរារាំងការអនុវត្តច្បាប់ ដើម្បីស្វែងរកនូវផលប្រយោជន៍ផ្ទាល់ខ្លួនតាមរយៈការដាក់វិធានការណ៍ និងណែនាំមន្ត្រីក្រោមឱវាទរបស់ខ្លួនឱ្យទទួលរត់ការដើម្បីសម្រួល និងជម្រុញដល់ការផ្តល់សេវាសាធារណៈរបស់មន្ទីរដែលខ្លួនបំពេញការងារ ។ តាមរយៈការដាក់វិធានការណ៍ និងការណែនាំដល់មន្ត្រីក្រោមឱវាទ ជនជាប់ចោទបានបង្កឱ្យមានការភាន់ច្រឡំថា ការទទួលសេវាក្រៅច្បាប់ ជាអំពើត្រឹមត្រូវហើយប្រសិទ្ធភាពនៃវិធានការណ៍នេះបានស្តែងឡើងតាមរយៈការទទួលបាននូវសេវាក្រៅច្បាប់ជាច្រើនពីប្រជាពលរដ្ឋ និងពីមន្ត្រីក្រោមឱវាទដែលទទួលបានពីប្រជាពលរដ្ឋដែលមានចំនួនមិនតិចជាង ១៤០ ករណី តាំង ពីឆ្នាំ២០១៦ មក ។ អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនរឿន** ដែលបានរៀបរាប់ខាងលើនេះ បានបង្ហាញឱ្យឃើញថា មានពិរុទ្ធគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **ប៊ុនរឿន** ពីបទ ***រំលោភលើអំណាច (ស្ថានទម្ងន់ទោស)*** ប្រព្រឹត្តតាំងអំឡុងឆ្នាំ២០១៦ រហូតមកដល់ថ្ងៃទី២៦-ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៩ នៅចំណុចខេត្តពោធិ៍សាត់ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥ កថាខណ្ឌទី១ និងទី២ នៃច្បាប់ស្តីពី ការប្រឆាំងអំពើពុករលួយ ។

២០-ដោយឡែកចំពោះជនជាប់ចោទឈ្មោះ [redacted] **វុទ្ធី** និងជនជាប់ចោទឈ្មោះ [redacted] **ប៊ុនថេង** បើទោះបីជាមន្ត្រីរាជការសាធារណៈដែលមានមុខងារ និងតួនាទីនៅក្នុងមន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និងសូរិយោដីខេត្តពោធិ៍សាត់ ជនជាប់ចោទគ្រាន់តែជាមន្ត្រីក្រោមឱវាទរបស់ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនរឿន** មិនមែនជាអ្នកដាក់វិធានការណ៍រារាំងការអនុវត្តច្បាប់នោះទេ ។ ហេតុដូចនេះ តុលាការយល់ឃើញថា ពុំមានពិរុទ្ធគ្រប់គ្រាន់លើជនជាប់ចោទ ឈ្មោះ [redacted] **វុទ្ធី** និងជនជាប់ចោទឈ្មោះ [redacted] **ប៊ុនថេង** ពីបទ ***រំលោភអំណាច*** ប្រព្រឹត្តកាលពីថ្ងៃទី២៦-២៧ ខែកក្កដា ឆ្នាំ២០១៩ នៅចំណុចខេត្តពោធិ៍សាត់ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥ កថាខណ្ឌទី១ និងទី២ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយនោះទេ គប្បីឱ្យជនជាប់ចោទទាំងពីររួចផុតបទចោទពីបទ ***រំលោភអំណាច*** ។



Scanned with CamScanner

២១-ជនជាប់ចោទឈ្មោះ [redacted] ប៊ុនរឿន តាមរយៈការប្រព្រឹត្តបទល្មើសវិតិក្រម និងបទល្មើសរំលោភអំណាច ជាបន្តបន្ទាប់តាំងពីអំឡុងឆ្នាំ២០១៦ រហូតមកដល់ពេលឃាត់ខ្លួន ជនជាប់ចោទបានទទួលនូវប្រាក់ដែលជាកម្រៃសេវាក្រៅច្បាប់ជាច្រើនដូចដែលមានកត់ត្រានៅក្នុងសៀវភៅកំណត់ត្រាដកហូតបាននៅការិយាល័យរបស់ជនជាប់ចោទ ។ បន្ទាប់ពីបានបូកសរុបទឹកប្រាក់ក្នុងកំណត់ត្រាឃើញថា ជនជាប់ចោទបានទទួលនូវប្រាក់ចំនួន ៣៧២.៧៤៧ (បីរយចិបសិបពីរពាន់ និងប្រាំពីររយសែបសិបប្រាំពីរ) ដុល្លារអាមេរិក និងប្រាក់ចំនួន ៤៩.០០០.០០០ (សែសិបប្រាំ បួនលាន) រៀល ។ ក្រៅអំពីប្រាក់ដែលបានកត់ត្រានេះ ជនជាប់ចោទក៏បានទទួលនូវប្រាក់ចំនួន ២០.០០០ (ម្ភៃពាន់) ដុល្លារអាមេរិក ពីឈ្មោះ [redacted] ទី ថែមទៀតផង ។

២២-ជនជាប់ចោទឈ្មោះ [redacted] ប៊ុនរឿន បានបដិសេធថា ក្នុងចំណោមទឹកប្រាក់ដែលបានកត់ត្រានៅក្នុងសៀវភៅ ជនជាប់ចោទបានទទួលជាក់ស្តែងតែចំនួន ២៧៨.៦១៧ (ពីររយចិតសិបប្រាំបីពាន់ និងប្រាំមួយរយដប់ប្រាំពីរ) ដុល្លារអាមេរិក និងចំនួន ៤៩.០០០.០០០០ (សែសិបប្រាំបួនលាន) រៀល ប៉ុណ្ណោះ ព្រោះថា ជនជាប់ចោទបានបង្វិលសងទៅសាម៉ីជនដែលប្រើប្រាស់សេវាទាំងឡាយណាដែលមិនឯកភាពទៅនឹងតម្លៃដែលបានកំណត់ ។ ប៉ុន្តែជនជាប់ចោទឈ្មោះ [redacted] ប៊ុនរឿន ពុំមានភស្តុតាងដើម្បីបញ្ជាក់មកតុលាការអំពីករណីដែលខ្លួនបានបង្វិលសង និងប្រាក់ដែលបានបង្វិលសងទៅប្រជាពលរដ្ឋវិញនោះទេ ។

២៣-ជនជាប់ចោទឈ្មោះ [redacted] ប៊ុនរឿន បានបដិសេធថា ក្នុងចំណោមទឹកប្រាក់ដែលជនជាប់ចោទបានទទួលចំនួន ២៧៨.៦១៧ (ពីររយចិតសិបប្រាំបីពាន់ និងប្រាំមួយរយដប់ប្រាំពីរ) ដុល្លារអាមេរិក និងចំនួន ៤៩.០០០.០០០០ (សែសិបប្រាំបួនលាន) រៀល ជនជាប់ចោទបានទទួលជាក់ស្តែងមានចំនួនតែ ៧៥.០០០ (ចិតសិបប្រាំពាន់) ដុល្លារអាមេរិក ប៉ុណ្ណោះ ព្រោះជនជាប់ចោទត្រូវចូទាត់ចំណាយទៅលើកម្រៃដែលត្រូវបង់ជូនរដ្ឋជាអាទិ៍ ចំណាយលើសេវាសួរិយោដី និងចំណាយទៅលើការបង់ពន្ធ ។ ប៉ុន្តែការចំណាយដែលជនជាប់ចោទបានលើកឡើងទាំងអស់នេះឃើញថា ជនជាប់ចោទមិនមានលទ្ធភាព និងភស្តុតាងដើម្បីបញ្ជាក់មកតុលាការអំពីទំហំនៃការចំណាយនោះទេ ។ ហេតុដូចនេះ តុលាការមិនមានមូលដ្ឋានគ្រប់គ្រាន់ដើម្បីដកចេញនូវទំហំទឹកប្រាក់ដែលជនជាប់ចោទបានចំណាយ ចេញពីទំហំទឹកប្រាក់ដែលជនជាប់ចោទបានទទួលនោះទេ ។

២៤-ជារួម តុលាការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] ប៊ុនរឿន ពិតជាបានទទួលប្រាក់ចំនួន ៣៧២.៧៤៧ (បីរយចិបសិបពីរពាន់ និងប្រាំពីររយសែបសិបប្រាំពីរ) ដុល្លារអាមេរិក និងប្រាក់ចំនួន ៤៩.០០០.០០០ (សែសិបប្រាំបួនលាន) រៀល ដែលជាកម្រៃសេវាក្រៅច្បាប់ចំនួន ១៤០ ករណី ដូចដែលមានកត់ត្រានៅក្នុងសៀវភៅកំណត់ត្រារបស់ជនជាប់ចោទ មែន ។

២៥-ចាប់តាំងពីអំឡុងពេលជនជាប់ចោទឈ្មោះ [redacted] ប៊ុនរឿន បំពេញមុខងារជាប្រធានមន្ទីរ មានការកើនឡើងគួរឱ្យកត់សម្គាល់នូវទ្រព្យសម្បត្តិរបស់ជនជាប់ចោទ ។ ជនជាប់ចោទបានចំណាយទឹកប្រាក់ចំនួន ១៦៨.០០០ (មួយរយហុកសិបប្រាំបីពាន់) ដុល្លារអាមេរិក ដើម្បីទិញនូវអចលនវត្ថុដីផ្ទះដែលមានទីតាំងស្ថិតនៅក្នុងបូរីប៉េងហួត ប៊ុស្តិ៍រីឡស្ទឹងមានជ័យ ។ ជនជាប់ចោទបានចំណាយទឹកប្រាក់ចំនួន ៧២.០០០ (ចិតសិបពីរពាន់) ដុល្លារអាមេរិក ទិញអចលនវត្ថុដីផ្ទះស្ថិតនៅភូមិដូងជ្រុំ សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ កាលពីអំឡុងឆ្នាំ ២០១៨ ។ ជនជាប់ចោទបានចំណាយទឹកប្រាក់ចំនួន ៤៤.០០០ (សែសិបបួនពាន់) ដុល្លារអាមេរិក ទិញអចលនវត្ថុដីមានទីតាំងស្ថិតនៅភូមិស្ពានថ្មសង្កាត់រលាប ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ កាលពីអំឡុងឆ្នាំ២០១៧ ហើយបានចំណាយប្រាក់ចំនួន ៤០.០០០ (សែសិប



Scanned with CamScanner

ពាន់) ដុល្លារអាមេរិក ទៀត ដើម្បីសាងសង់សំណង់ផ្ទះគ្រចៀកកាំនៅអំឡុងឆ្នាំ ២០១៩ ។ ជនជាប់ចោទបានចំណាយប្រាក់ចំនួន ៨៦.០០០ (ប៉ែត្រសិបប្រាំមួយពាន់) ដុល្លារអាមេរិក ដើម្បីទិញរថយន្តមួយគ្រឿងម៉ាក LEXUS 570 ពណ៌មាស ស៊េរីឆ្នាំ២០១០ និងបានចំណាយប្រាក់ចំនួន ១១.៥០០ (ដប់មួយពាន់ និងប្រាំរយ) ដុល្លារអាមេរិក ទិញរថយន្តម៉ាក KIA Morning ស៊េរីឆ្នាំ២០១២ នៅអំឡុងឆ្នាំ ២០១៩ ។ សរុបទឹកប្រាក់ដែលជនជាប់ចោទបានចំណាយលើទ្រព្យសម្បត្តិទាំងអស់នេះឃើញថា មានចំនួន ៤១១.៥០០ (បួនរយដប់មួយពាន់ និងប្រាំរយ) ដុល្លារអាមេរិក ។

២៦-យោងតាមវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៦០១០៧-២៧៤៩ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០១៧ ឃើញថា អចលនវត្ថុដីផ្ទះមួយល្វែង មានទីតាំងស្ថិតនៅបូរីប៉េងហួត ភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ពិតជាទ្រព្យសម្បត្តិរបស់ឈ្មោះ [redacted] ប៊ុនរឿន ប្រាកដមែន ។ ពាក់ព័ន្ធទៅនឹងអចលនវត្ថុនេះដំបូងឡើយជនជាប់ចោទបានឆ្លើយនៅសមត្ថកិច្ចនគរបាលយុត្តិធម៌ថា ជនជាប់ចោទបានខ្ចីប្រាក់ប្អូនស្រីចំនួន ២០០.០០០ (ពីររយពាន់) ដុល្លារអាមេរិក ដើម្បីទិញ ប៉ុន្តែក្រោយមកជនជាប់ចោទបានកែប្រែចម្លើយថា ប្រាក់ចំណាយក្នុងការទិញដីផ្ទះនេះជាប្រាក់របស់ជនជាប់ចោទទាំងស្រុង ។ នាពេលសវនាការជនជាប់ចោទបែរជាឆ្លើយថា ប្រាក់ដែលបានចំណាយទិញផ្ទះនេះជាប្រាក់ដែលជនជាប់ចោទចូលហ៊ុនជាមួយប្អូនស្រី ។ ជនជាប់ចោទក៏បានបញ្ជាក់ផងដែរថា ប្រាក់ដែលបានចំណាយក្នុងការទិញផ្ទះចំនួន ៧០.០០០ (ចិតសិបពាន់) ដុល្លារអាមេរិក ជនជាប់ចោទទទួលបានមកពីការលក់ផ្ទះមួយកន្លែងនៅបូរីធូធូទី ទីតាំងនៅផ្សារត្រពាំងថ្លឹងទៅឱ្យបងស្រី និងចំនួនជាង ៩០.០០០ (កៅសិបពាន់) ដុល្លារអាមេរិក ទៀតបានមកពីប្រាក់ជនជាប់ចោទសន្សំខ្លះ និងប្រាក់ផ្ទះខ្លះ ។ ដោយពិនិត្យឃើញថា ជនជាប់ចោទបានលើក ឡើងនូវអង្គហេតុខុសៗគ្នាអំពីប្រភពនៃប្រាក់ដែលបានចំណាយក្នុងការទិញផ្ទះ ហើយក៏មិនមានភស្តុតាងដើម្បីបញ្ជាក់ទៅលើ អង្គហេតុដែលខ្លួនលើកឡើង តុលាការយល់ឃើញថា ការលើកឡើងរបស់ជនជាប់ចោទគ្រាន់តែជាការដោះសារដើម្បីលាក់បាំងនូវប្រភពនៃប្រាក់ដែលបានចំណាយទៅលើការទិញផ្ទះនេះប៉ុណ្ណោះ មិនអាចឱ្យតុលាការជឿជាក់បានឡើយ។

២៧-យោងតាមវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៥០៥០៦០៥-០៣២៨ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ ២០១៩ បានបង្ហាញថា អចលនវត្ថុទំហំ ១២៧២ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិស្ពានថ្ម សង្កាត់រលាប ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ពិតជាទ្រព្យសម្បត្តិរបស់ឈ្មោះ [redacted] ប៊ុនរឿន និងប្រពន្ធឈ្មោះ [redacted] សុធានី ។ ពាក់ព័ន្ធទៅនឹងប្រភពនៃប្រាក់ដែលចំណាយលើការទិញដី និងសាងសង់ផ្ទះគ្រចៀកកាំ នាពេលសវនាការជនជាប់ចោទអះអាងថា មួយផ្នែកបានមកពីប្រាក់ថ្លៃលក់ដីរបស់ជនជាប់ចោទនៅឧត្តរមានជ័យ និងមួយផ្នែកទៀតជាប្រាក់សន្សំ ។ ប៉ុន្តែឈ្មោះ [redacted] សុធានី ដែលជាប្រពន្ធរបស់ជនជាប់ចោទបានលើកឡើងថា ប្រាក់ចំណាយលើការទិញដីនេះបានមកពីប្រាក់សន្សំរបស់ជនជាប់ចោទឈ្មោះ [redacted] ប៊ុនរឿន និងប្រាក់សន្សំរបស់ខ្លួន ចំណែកប្រាក់ដែលបានចំណាយលើការសាងសង់ផ្ទះគ្រចៀកកាំបានមកពីប្រាក់លក់ដីនៅឧត្តរមានជ័យ ។ ដោយពិនិត្យឃើញថា ជនជាប់ចោទពុំមានសំអាងដើម្បីបញ្ជាក់អំពីអង្គហេតុដែលខ្លួនលើកឡើង ហើយមានការលើកឡើងផ្សេងគ្នារវាងជនជាប់ចោទនិងប្រពន្ធ តុលាការយល់ឃើញថា ចម្លើយរបស់អ្នកទាំងពីរនេះមិនអាចឱ្យតុលាការជឿជាក់បានឡើយ ។

២៨-យោងតាមវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៥០៥០៥០២-០១៥៣ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ ២០១៩ បានបង្ហាញថា អចលនវត្ថុទំហំ ៦៣៦ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិអូងជ្រៃ សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ពិតជាទ្រព្យសម្បត្តិរបស់ឈ្មោះ [redacted] ប៊ុនរឿន និងប្រពន្ធឈ្មោះ [redacted] សុធានី ។ ពាក់ព័ន្ធទៅនឹងប្រភពនៃប្រាក់ដែលចំណាយលើការទិញទ្រព្យសម្បត្តិនេះ ជនជាប់ចោទបានលើកឡើងថា មួយផ្នែកបានមកពីប្រាក់សន្សំ (សេវាក្រៅច្បាប់) និងមួយផ្នែកទៀតជាប្រាក់យកពីផ្ទះ ។ ស្របតាមការលើកឡើងរបស់ជនជាប់ចោទ ឈ្មោះ [redacted] សុធានី ក៏បាន



Scanned with CamScanner

បញ្ជាក់ផងដែរថា ប្រាក់ដែលបានចំណាយដើម្បីទិញដីនេះមានមួយផ្នែកជាប្រាក់សន្សំរបស់ជនជាប់ចោទ និងមួយផ្នែកទៀតជាប្រាក់សន្សំរបស់ខ្លួន ។ បើទោះបីជនជាប់ចោទ និងប្រពន្ធបានបដិសេធថា ចំណាយដើម្បីទិញដីនេះមានមួយផ្នែកជាប្រាក់សន្សំស្របច្បាប់ ជនជាប់ចោទក៏ពុំមានសំអាងដើម្បីបញ្ជាក់មកតុលាការនោះដែរ ។ ហេតុដូចនេះ តុលាការមិនអាចជឿជាក់លើការអះអាងនេះឡើយ ។

២៩-យោងតាមរបាយការណ៍ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ របស់អង្គភាពប្រឆាំងអំពើពុករលួយ លើវត្ថុចាប់យករថយន្តម៉ាក LEXUS LX570 បានបង្ហាញថា រថយន្តម៉ាក LEXUS LX570 ពណ៌ទឹកមាស ផលិតឆ្នាំ២០១០ បំពាក់ ផ្លាកលេខពោធិ៍សាត់ 2C-3888 ជាទ្រព្យសម្បត្តិរបស់ជនជាប់ចោទឈ្មោះ [redacted] ប៊ុនរឿន ។ ពាក់ព័ន្ធទៅនឹងប្រភពនៃប្រាក់ដែលចំណាយលើការទិញរថយន្តនេះ ជនជាប់ចោទបានលើកឡើងថា ជនជាប់ចោទបានលក់រថយន្តចាស់របស់ខ្លួនម៉ាក LAND CRUISER បានប្រាក់ចំនួន ៥៥.០០០ (ហាសិបប្រាំពាន់) ដុល្លារអាមេរិក ហើយថែមប្រាក់ប្រពន្ធចំនួន ១០.០០០ (ដប់ពាន់) ដុល្លារអាមេរិក ហើយប្រាក់នៅសល់ជាប្រាក់សន្សំរបស់ជនជាប់ចោទ ។ យោងតាមកិច្ចសន្យាលក់និងទិញរថយន្តចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៩ ឃើញថា ជនជាប់ចោទពិតបានលក់រថយន្តម៉ាក LAND CRUISER ផលិតឆ្នាំ២០០៨ ក្នុងតម្លៃ ៥៥.០០០ (ហាសិបប្រាំពាន់) ដុល្លារអាមេរិក ។ បើទោះបីជាជនជាប់ ចោទបានលក់រថយន្តចាស់របស់ខ្លួនបានប្រាក់ចំនួន ៥៥.០០០ (ហាសិបប្រាំពាន់) ដុល្លារអាមេរិក តុលាការយល់ឃើញថា ក៏នៅតែមិនអាចបញ្ជាក់បានថាប្រាក់ដែលបានពីការលក់ឡាននេះត្រូវបានចំណាយដើម្បីទិញរថយន្តថ្មីនេះ នោះទេ ។

៣០-យោងតាមរបាយការណ៍ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ របស់អង្គភាពប្រឆាំងអំពើពុករលួយ លើវត្ថុចាប់យករថយន្តម៉ាក KIA MORNING ពណ៌ស ផលិតឆ្នាំ២០១២ បំពាក់ផ្លាកលេខពោធិ៍សាត់ 2D-3888 ជាទ្រព្យសម្បត្តិរបស់ជនជាប់ចោទឈ្មោះ [redacted] សុធានី ។ ពាក់ព័ន្ធទៅនឹងប្រភពនៃប្រាក់ដែលចំណាយលើការទិញរថយន្តនេះ ជនជាប់ចោទនិងប្រពន្ធរបស់ជនជាប់ចោទបានលើកឡើងប្រហែលគ្នាថា ជាប្រាក់របស់ប្រពន្ធជនជាប់ចោទ ។ ស្របតាមការលើកឡើងរបស់ជនជាប់ចោទ និងប្រពន្ធរបស់ជនជាប់ចោទឃើញថា ជនជាប់ចោទតែងតែផ្តល់ប្រាក់ជាប្រចាំទៅប្រពន្ធរបស់ខ្លួន ។ ហេតុដូចនេះ តុលាការយល់ឃើញថា ប្រាក់របស់ជនជាប់ចោទនេះក៏ជាផ្នែកដែលទទួលបានមកពីផលនៃបទល្មើសដែរ ។

៣១-ជនជាប់ចោទឈ្មោះ [redacted] ប៊ុនរឿន ជាមន្ត្រីរាជការទទួលបានបៀវត្សគោលប្រហែលជា ២.០០០.០០០ រៀល ក្នុងមួយខែប៉ុណ្ណោះ ។ ដោយឡែកឈ្មោះ [redacted] សុធានី ប្រពន្ធរបស់ជនជាប់ចោទមានអាជីវកម្មលក់គ្រឿងសង្ហារឹមដែលបើកដំណើរការតាំងពីអំឡុងឆ្នាំ២០១១ ហើយដែលឈ្មោះ [redacted] សុធានី បានអះអាងអាជីវកម្មនេះមានចំណូលពី ៣.០០០ (បីពាន់) ដុល្លារអាមេរិក ទៅ ៤.០០០ (បួនពាន់) ដុល្លារអាមេរិក ក្នុងមួយខែ ប៉ុន្តែឈ្មោះនេះពុំបានផ្តល់ជូនមកតុលាការនូវបញ្ជីចំណូលចំណាយដើម្បីបញ្ជាក់ទៅលើការអះអាងរបស់ខ្លួននោះទេ ។ ដោយហេតុថា កម្រិតនៃចំណូលស្របច្បាប់របស់ជនជាប់ចោទមានកម្រិតទាប ហើយអាជីវកម្មប្រពន្ធរបស់ជនជាប់ចោទក៏ពុំមានបញ្ជីរចំណូលច្បាស់លាស់ តុលាការយល់ឃើញថា ជនជាប់ចោទ និងប្រពន្ធពុំមានលទ្ធភាពគ្រប់គ្រាន់ដើម្បីបញ្ជាក់អំពីចំណូលស្របច្បាប់របស់ខ្លួនស្របទៅនឹងការចំណាយដ៏ច្រើនសន្ធឹកសន្ធាប់លើទ្រព្យសម្បត្តិនោះទេ ។ បន្ថែមពីលើនេះផងដែរ ឈ្មោះ [redacted] សុធានី ក៏បានទទួលស្គាល់ផងដែរថា ឈ្មោះ [redacted] ប៊ុនរឿន តែងតែប្រគល់ប្រាក់ឱ្យខ្លួនប្រចាំខែពី ២.០០០ (ពីរពាន់) ដុល្លារអាមេរិក ទៅ ៣.០០០ (បីពាន់) ដុល្លារអាមេរិក ដែលចំណុចអាចបង្ហាញបានថា ប្រាក់ដែលជាផលនៃបទល្មើស និងប្រាក់សន្សំរបស់ឈ្មោះ [redacted] សុធានី មិនអាចញែកដាច់ពីគ្នានោះទេ ។ ហេតុដូចនេះ តុលាការយល់ឃើញថា ទ្រព្យសម្បត្តិរបស់ជនជាប់ចោទ និងប្រពន្ធដែលបានលើកឡើងចាប់ពីចំណុចទី២៩ ដល់ចំណុចទី៣០ នៃសំអាងហេតុគឺបានមកពីផលនៃបទ



Scanned with CamScanner

ល្មើសវិតិក្រម និងបទល្មើសរំលោភអំណាច ដែលជនជាប់ចោទឈ្មោះ [redacted] ប៊ុនឿន បានប្រព្រឹត្តដូចបានរៀបរាប់ពីខាងដើម ។

**៣២**-សកម្មភាពនៃការបំប្លែងនូវផលនៃបទល្មើសដែលជនជាប់ចោទឈ្មោះ [redacted] **ប៊ុនឿន** ទទួលបានចាប់តាំងពីអំឡុងឆ្នាំ២០១៦ រហូតដល់ថ្ងៃទី២៦-២៧ ខែកក្កដា ឆ្នាំ២០១៩ ធ្វើឡើងក្នុងស្ថានភាពដែលជនជាប់ចោទដឹងថា ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការបំប្លែងគឺទទួលបានមកពីផលនៃបទល្មើស ។

**៣៣**-យោងតាមបញ្ញត្តិមាត្រា ៣ថ្មី ចំណុចក-១ នៃច្បាប់ស្តីពី វិសោធនកម្មមាត្រា ៣ មាត្រា ២៩ និងមាត្រា ៣០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មបានបញ្ញត្តិថា ការសម្អាតប្រាក់គឺជាការបំប្លែង ឬការផ្ទេរទ្រព្យសម្បត្តិ ដោយដឹងថាទ្រព្យសម្បត្តិនេះជាផលនៃបទល្មើសក្នុងគោលបំណងបិទបាំង ឬក្លែងប្រភពដើមមិនស្របច្បាប់នៃទ្រព្យសម្បត្តិនោះ ឬជួយបុគ្គលណាដែលបានពាក់ព័ន្ធក្នុងបទល្មើស ដើម្បីឱ្យបុគ្គលនោះគេចផុតពីផលវិបាកតាមផ្លូវច្បាប់នូវសកម្មភាពរបស់ខ្លួន ។ ជាងនេះទៀត យោងតាមបញ្ញត្តិមាត្រា ២៩ថ្មី១ នៃច្បាប់ដដែល និងមាត្រា ៤០៦ នៃក្រមព្រហ្មទណ្ឌ ឃើញថា បទល្មើសសម្អាតប្រាក់មានស្ថានទម្ងន់ទោសកាលបើប្រព្រឹត្តជាទម្លាប់ ។

**៣៤**-ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនឿន** បានធ្វើសកម្មភាពបំប្លែងនូវទ្រព្យសម្បត្តិដែលជនជាប់ចោទបានដឹងថាទទួលពីបទល្មើសវិតិក្រម និងបទល្មើសរំលោភអំណាច មានគោលបំណងបិទបាំង និងក្លែងប្រភពដើមមិនស្របច្បាប់នៃទ្រព្យសម្បត្តិនោះ តាមរយៈការបំប្លែងនូវផលនៃបទល្មើសទៅជាចលនវត្ថុទ្រព្យ និងអចលនទ្រព្យនានា ។ ជនជាប់ចោទបានធ្វើសកម្មភាពបំប្លែងនូវផលនៃបទល្មើសនេះជាបន្តបន្ទាប់ដែលកើតឡើងជាទម្លាប់ចាប់តាំងពីឆ្នាំ២០១៦ រហូតមកដល់ពេលឃាត់ខ្លួន ។ ហេតុដូចនេះ តាមរយៈអំពើទាំងអស់នេះ តុលាការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនឿន** បានប្រព្រឹត្តបទល្មើស សម្អាតប្រាក់ (ស្ថានទម្ងន់ទោស) បទល្មើសព្រហ្មទណ្ឌមានថែង និងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ២៩ថ្មី១ កថាខណ្ឌទី២ នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ៣ មាត្រា ២៩ និងមាត្រា ៣០ នៃច្បាប់ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

**៣៥**-ជារួម តាមរបាយការណ៍របស់សមត្ថកិច្ចនគរបាលយុត្តិធម៌ ចម្លើយរបស់ជនជាប់ចោទ ព្រមទាំងភស្តុតាងដែលមានក្នុងសំណុំរឿង តុលាការយល់ឃើញថា មានពិរុទ្ធគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **ប៊ុនឿន** ពីបទ សម្អាតប្រាក់ (ស្ថានទម្ងន់ទោស) ប្រព្រឹត្តចាប់តាំងពីអំឡុងឆ្នាំ២០១៦ រហូតមកដល់ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៩ នៅខេត្តពោធិ៍សាត់ បទល្មើសព្រហ្មទណ្ឌមានថែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ថ្មី១ កថាខណ្ឌទី២ នៃច្បាប់ស្តីពី វិសោធនកម្មមាត្រា ៣ មាត្រា ២៩ និងមាត្រា ៣០ នៃច្បាប់ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

**៣៦**-យោងតាមបញ្ញត្តិមាត្រា ៣០ថ្មី២ នៃច្បាប់ស្តីពី វិសោធនកម្មមាត្រា ៣ មាត្រា ២៩ និងមាត្រា ៣០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ក្នុងស្ថានភាពដែលមានទោសសម្អាតប្រាក់ ឬសម្អាងនៃបទល្មើសហិរញ្ញប្បទានភេរវកម្ម តុលាការអាចចេញបញ្ជាឱ្យរឹបអូសនូវទ្រព្យសម្បត្តិដែលជាផលនៃបទល្មើស រួមទាំងទ្រព្យសម្បត្តិរួមបញ្ចូលគ្នា ឬត្រូវបានផ្លាស់ប្តូរជាមួយផលនោះ ។

**៣៧**-យោងតាមចំណុចលេខ ៣១ នៃសំអាងហេតុ តុលាការយល់ឃើញថា ទ្រព្យសម្បត្តិរបស់ជនជាប់ចោទដែលមានរៀបរាប់ចាប់ពីចំណុចលេខ ២៦ ដល់លេខ ៣០ នៃសំអាងហេតុ ជាទ្រព្យសម្បត្តិដែលកើតចេញពីផលនៃបទល្មើស ។ ហេតុដូចនេះ ទ្រព្យសម្បត្តិទាំងអស់នេះជាផលនៃបទល្មើសសម្អាតប្រាក់ គប្បីតុលាការសម្រេចរឹបអូសតាមបញ្ញត្តិមាត្រា ៣០ថ្មី២ នៃច្បាប់ស្តីពី វិសោធនកម្មមាត្រា ៣ មាត្រា ២៩ និងមាត្រា ៣០ នៃច្បាប់ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។



Scanned with CamScanner

៣៨-បន្ទាប់ពីបានឃាត់ខ្លួន សមត្ថកិច្ចនគរបាលយុត្តិធម៌បានដកហូតនូវប្រាក់មួយចំនួនពីជនជាប់ចោទឈ្មោះ [redacted] ប៊ុនវឿន និងប្រាក់មួយចំនួននៅការិយាល័យរបស់ជនជាប់ចោទ ។ ទីមួយ ប្រាក់ដុល្លារអាមេរិកប្រភេទក្រដាស ប្រាក់ ១០០ ដុល្លារអាមេរិក ចំនួន ៥០ សន្លឹក សរុបទឹកប្រាក់មានចំនួន ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក ។ ទីពីរ ប្រាក់ដុល្លារអាមេរិកប្រភេទក្រដាស់ប្រាក់ ១០០ ដុល្លារអាមេរិក ចំនួន ០១ សន្លឹក ។ ទីបី ប្រាក់ដុល្លារអាមេរិក ប្រភេទក្រដាស ប្រាក់ ២០ ដុល្លារអាមេរិក ចំនួន ៣០ សន្លឹក និងប្រភេទក្រដាស ១០ ដុល្លារអាមេរិក ចំនួន ៤០ សន្លឹក សរុបទឹកប្រាក់មានចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិក ។ ទីបួន ប្រាក់រៀលប្រភេទក្រដាសប្រាក់ ៥០.០០០ (ហាសិបពាន់) រៀល ចំនួន ១១៥ សន្លឹក សរុបជាទឹកប្រាក់ ៥.៧៥៧.០០០ (ប្រាំលាន ប្រាំពីររយហាសិបប្រាំពីរពាន់) រៀល ។ ទីប្រាំ ប្រាក់រៀលប្រភេទក្រដាសប្រាក់ ១០.០០០ (ដប់ពាន់) រៀល សរុបចំនួន ១០ សន្លឹក និងប្រភេទក្រដាសប្រាក់ ៥.០០០ រៀល សរុបចំនួន ៧៧ សន្លឹក និងប្រភេទក្រដាសប្រាក់ ២.០០០ (ពីរពាន់) រៀល ចំនួន ០២ សន្លឹក និងប្រភេទក្រដាសប្រាក់ ១.០០០ (មួយពាន់) រៀល ចំនួន ០១ សន្លឹក សរុបជាទឹកប្រាក់មានចំនួន ៥០០.០០០ (ប្រាំរយពាន់) រៀល ។ ទីប្រាំមួយ ប្រាក់ដុល្លារអាមេរិកប្រភេទក្រដាសប្រាក់ ១០០ ដុល្លារអាមេរិក ចំនួន ២៥ សន្លឹក សរុបជាទឹកប្រាក់ចំនួន ២.៥០០ (ពីរពាន់ប្រាំរយ) ដុល្លារអាមេរិក រក្សាទុកនៅក្នុងស្រោមសំបុត្រពណ៌សមានសរសេរថា៖ “ម្លូង ស៊ីថា ២.៥០០$” ។ ទីប្រាំពីរ ប្រាក់ដុល្លារអាមេរិក ប្រភេទក្រដាស ១០០ ដុល្លារអាមេរិក ចំនួន ២៨ សន្លឹក សរុបជាទឹកប្រាក់ចំនួន ២.៨០០ (ពីរពាន់ប្រាំបីរយ) ដុល្លារអាមេរិក រក្សាទុកនៅក្នុងស្រោមសំបុត្រពណ៌សមានឈ្នូតផ្នែកខៀនពណ៌ក្រហមនៅលើសំបុត្រមានសរសេរថា៖ “ហាប់ភ្លី លក់ផ្កាច់ ៧ប្លង់” ។ ទីប្រាំបី ប្រាក់ដុល្លារអាមេរិកប្រភេទក្រដាសប្រាក់ ១០០ ដុល្លារអាមេរិក ចំនួន ២៥ សន្លឹក សរុបជាទឹកប្រាក់ចំនួន ២.៥០០ (ពីរពាន់ប្រាំរយ) ដុល្លារអាមេរិក រក្សាទុកក្នុងស្រោមសំបុត្រពណ៌បៃតងមានរូបផ្កាកុលាបពណ៌ក្រហមនៅលើសំបុត្រមានសរសេរថា៖ “ចេង ប៊ុនលេខ” ។ ទីប្រាំបួន ប្រាក់ដុល្លារអាមេរិកប្រភេទក្រដាស ១០០ ដុល្លារអាមេរិក ចំនួន ៣០ សន្លឹក សរុបជាទឹកប្រាក់ចំនួន ៣.០០០ (បីពាន់) ដុល្លារអាមេរិក រក្សាទុកនៅក្នុងស្រោមសំបុត្រពណ៌ផ្ទៃមេឃខ្ចីនៅលើសំបុត្រមានសរសេរថា៖ “សេវា វណ្ណសាក់ ៣០០០$ ប្លង់រៀបរយ” ។ ទីដប់ ប្រាក់រៀលប្រភេទក្រដាសប្រាក់ ៥.០០០ (ប្រាំពាន់) រៀល ចំនួន ២.០០០ (មួយពាន់) សន្លឹក សរុបជាទឹកប្រាក់ចំនួន ១០.០០០.០០០ (ដប់លាន) រៀល ។ ទីដប់មួយ ប្រាក់ដុល្លារអាមេរិកប្រភេទក្រដាសប្រាក់ ១០០ ដុល្លារអាមេរិក ចំនួន ០៤ សន្លឹក ប្រភេទក្រដាសប្រាក់ ៥០ ដុល្លារអាមេរិក ចំនួន ០១ សន្លឹក ប្រភេទក្រដាសប្រាក់ ២០ ដុល្លារអាមេរិក ចំនួន ០៣ សន្លឹក ប្រភេទក្រដាសប្រាក់ ៥ ដុល្លារអាមេរិក ចំនួន ១៤ សន្លឹក និងប្រភេទក្រដាសប្រាក់ ១ ដុល្លារអាមេរិក ចំនួន ១៤ សន្លឹក សរុបជាទឹកប្រាក់ចំនួន ៦២៩ (ប្រាំមួយរយម្ភៃប្រាំបួន) ដុល្លារអាមេរិក រក្សាទុកនៅក្នុងស្រោមសំបុត្រពណ៌សមានឡូហ្គូមន្ទីរ ដ.ន.ស.ស ខេត្តពោធិ៍សាត់ ។ ទីដប់ពីរ ប្រាក់ដុល្លារអាមេរិកប្រភេទក្រដាសប្រាក់ ១០០ ដុល្លារអាមេរិក ចំនួន ៥០ សន្លឹក សរុបជាទឹកប្រាក់ចំនួន ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក ជាប្រាក់ដែលតំណាងក្រុមហ៊ុនបានប្រគល់ទៅជនជាប់ចោទក្នុងបន្ទប់ការិយាល័យ ។ ទីដប់បី ប្រាក់ដុល្លារអាមេរិកប្រភេទក្រដាសប្រាក់ ១០០ ដុល្លារអាមេរិក ចំនួន ៤៥០ សន្លឹក សរុបជាទឹកប្រាក់ចំនួន ៤៥.០០០ (សែសិបប្រាំពាន់) ដុល្លារអាមេរិក ជាប្រាក់ដែលតំណាងក្រុមហ៊ុនប្រគល់ឱ្យជនជាប់ចោទនៅភោជនីយដ្ឋានមហាលាភ ។

៣៩-ប្រាក់ចំនួន ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក ដែលជាវត្ថុចាប់យកទីមួយ ក្នុងចំណុចទី៣៤ នៃសំអាងហេតុ ជនជាប់ចោទឈ្មោះ [redacted] ប៊ុនវឿន បានឆ្លើយថា ជាប្រាក់ដែលជនជាប់ចោទបានមកពីការលក់ដីនៅខេត្តឧត្តរមានជ័យចំនួនមួយឡូតិ៍បានប្រាក់ចំនួន ១៥.០០០ (ដប់ប្រាំពាន់) ដុល្លារអាមេរិក ដោយលក់តាមរយៈឈ្មោះ [redacted] ផៃលឿត



Scanned with CamScanner

ជាមន្ត្រីនៅមន្ទីរ ដ.ន.ស.ស ខេត្តឧត្តរមានជ័យ ។ ឈ្មោះ [redacted] ឆែងលៀត បានផ្ទេរប្រាក់មកជនជាប់ចោទតាមសេវាផ្ទេរប្រាក់ លីហួរ ក្នុងអំឡុងខែកក្កដា ឆ្នាំ២០១៩ ចំនួនពីរលើក ដោយលើកទីមួយទឹកប្រាក់ចំនួន ៥.០០០ (បួនពាន់) ដុល្លារអាមេរិក និងលើកទីពីរទឹកប្រាក់ចំនួន ១០.២៥០ (ដប់ពាន់ និងពីររយហាសិប) ដុល្លារអាមេរិក ។ ពាក់ព័ន្ធទៅនឹងការលើកឡើងអំពីប្រភពនៃប្រាក់នេះ ជនជាប់ចោទមិនមានភស្តុតាងដើម្បីបញ្ជាក់ទៅលើអង្គហេតុដែលខ្លួនលើកឡើងនោះដែរ ។ ហេតុដូចនេះ តុលាការយល់ឃើញថា ទ្រព្យសម្បត្តិនេះជាផលនៃបទល្មើសដែលប្រព្រឹត្តដោយជនជាប់ចោទ គប្បីតុលាការសម្រេចរឹបអូស ។

៤០-ប្រាក់ចំនួន ១០០ (មួយរយ) ដុល្លារអាមេរិក ដែលជាវត្ថុចាប់យកទីពីរ ប្រាក់ចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិក ដែលជាវត្ថុចាប់ទីបី ប្រាក់ចំនួន ៥.៧៥០.០០០ (ប្រាំលាន ប្រាំពីររយហាសិបពាន់) រៀល ដែលជាវត្ថុចាប់យកទីបួន ប្រាក់ចំនួន ៥០០.០០០ (ហាសិបពាន់) រៀល ដែលជាវត្ថុចាប់យកទីប្រាំ ប្រាក់ចំនួន ២.៥០០ (ពីរពាន់ប្រាំរយ) ដុល្លារអាមេរិក ដែលជាវត្ថុចាប់ទីប្រាំមួយ ប្រាក់ចំនួន ២.៨០០ (ពីរពាន់ប្រាំបីរយ) ដុល្លារអាមេរិក ដែលជាវត្ថុចាប់យកទីប្រាំពីរ ប្រាក់ចំនួន ២.៥០០ (ពីរពាន់ប្រាំរយ) ដុល្លារអាមេរិក ដែលជាវត្ថុចាប់យកទីប្រាំបី និងប្រាក់ចំនួន ៣.០០០ (បីពាន់) ដុល្លារអាមេរិក ដែលជាវត្ថុចាប់យកទីប្រាំបួន ក្នុងចំណុចលេខ ៣៨ នៃសំអាងហេតុ ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនរឿន** បានទទួលស្គាល់ថា ជាប្រាក់ដែលជនជាប់ចោទបានទទួលមកពីសេវាក្រៅច្បាប់នានា ។ ហេតុដូចនេះ ទ្រព្យសម្បត្តិទាំងនេះជាផលនៃបទល្មើសដែលប្រព្រឹត្តដោយជនជាប់ចោទ គប្បីតុលាការសម្រេចរឹបអូស ។

៤១-ប្រាក់ចំនួន ១០.០០០.០០០ (ដប់លាន) រៀល ដែលជាវត្ថុចាប់យកទីដប់ ក្នុងចំណុចលេខ ៣៨ នៃសំអាងហេតុ ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនរឿន** បានអះអាងថា ជាប្រាក់បៀវត្សរបស់ខ្លួនដែលជនជាប់ចោទគ្រោងទុកសម្រាប់បង់កថិនទាន ប៉ុន្តែជនជាប់ចោទមិនមានភស្តុតាងដើម្បីបញ្ជាក់ទៅលើអង្គហេតុនេះទេ ។ ចំណែកប្រាក់ចំនួន ៦២៩ (ប្រាំមួយម្ភៃប្រាំបួន) ដុល្លារអាមេរិក ដែលជាវត្ថុចាប់យកទីដប់មួយ ក្នុងចំណុចលេខ ៣៦ នៃសំអាងហេតុ ជនជាប់ចោទ ឈ្មោះ [redacted] **ប៊ុនរឿន** ក៏មិនមានលទ្ធភាពបញ្ជាក់អំពីប្រភពនៃប្រាក់នេះដែរ ។ ហេតុដូចនេះ តុលាការយល់ឃើញថា ទ្រព្យសម្បត្តិទាំងនេះគឺជាផលនៃបទល្មើសដែលប្រព្រឹត្តដោយជនជាប់ចោទ គប្បីតុលាការសម្រេចរឹបអូស ។

៤២-ប្រាក់ចំនួន ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក ដែលជាវត្ថុចាប់យកទីដប់ពីរ និងប្រាក់ចំនួន ៤៥.០០០ (សែសិបប្រាំពាន់) ដុល្លារអាមេរិក ដែលជាវត្ថុចាប់យកទីដប់បី ក្នុងចំណុចលេខ៣៨ នៃសំអាងហេតុ ជាប្រាក់របស់ក្រុមហ៊ុនដែលស្នើសុំលិខិតអនុញ្ញាតសាងសង់ (សំណង់សូឡា) ហើយត្រូវបានប្រគល់ជូនវិញ ។ ហេតុដូចនេះ វត្ថុចាប់យកនេះមិនមែនជាកម្មវត្ថុនៃការរឹបអូសនោះទេ ។

៤៣-នាពេលឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] **ប៊ុនរឿន** ក្រៅអំពីប្រាក់ដែលបានចាប់យកដូចមានរៀបរាប់ក្នុងចំណុចលេខ ៣៨ នៃសំអាងហេតុ សមត្ថកិច្ចនគរបាលយុត្តិធម៌ក៏បានដកហូតនូវទ្រព្យសម្បត្តិ និងសម្ភារៈមួយចំនួនទៀតដូចជា៖ សៀវភៅកត់ត្រាចំនួន ០៨ (ប្រាំបី) ក្បាល បង្កាន់ដៃបង់ប្រាក់អង្គភាពមន្ទីរដ.ន.ស.សខេត្តពោធិ៍សាត់ចំនួន ៥១ (ហាសិបមួយ) សន្លឹក ក្រដាសកត់ត្រាទូរទាត់ថ្លៃសេវាដោយដៃចំនួន ៣ (បី) សន្លឹក ។ សមត្ថកិច្ចក៏បានដកហូតផងដែរនូវទូរស័ព្ទរបស់ជនជាប់ចោទសរុបចំនួន ៦ (ប្រាំមួយ) គ្រឿងដែលមានដូចជា៖ ទូរស័ព្ទដៃម៉ាក OPPO A7 ពណ៌មាស ចំនួន ០១ (មួយ) គ្រឿង ទូរស័ព្ទដៃម៉ាក One pluse ពណ៌ស ចំនួន ០១ (មួយ) គ្រឿង ទូរស័ព្ទដៃម៉ាក Iphone5 ពណ៌ទឹកមាស ចំនួន ០១ (មួយ) គ្រឿង ទូរស័ព្ទដៃម៉ាក SAMSUNG GALAXY Note9 ពណ៌ខ្មៅ ចំនួន ០១ (មួយ) គ្រឿង ទូរស័ព្ទដៃម៉ាក Iphone 7Plus ពណ៌ RoseGold ចំនួន ០១ (មួយ) គ្រឿង និងទូរស័ព្ទដៃម៉ាក HUAWEI OVA3 ពណ៌ខ្មៅ ចំនួន ០១ (មួយ) គ្រឿង ។ វត្ថុចាប់យកទាំងអស់នេះជាមធ្យោបាយ និងសម្ភារៈនៃអំពើល្មើស គប្បីតុលាការ



Scanned with CamScanner

សម្រេចរឹបអូស ។

៤៤-យោងតាមបញ្ញត្តិមាត្រា ១៣៧ នៃក្រមព្រហ្មទណ្ឌ កាលបើនៅក្នុងពេលចោទប្រកាន់តែមួយ ជនជាប់ចោទត្រូវបានគេរកឃើញថាមានពិរុទ្ធពីបទល្មើសច្រើន ទោសនីមួយៗអាចត្រូវបានប្រកាសឡើង ។ ប៉ុន្តែកាលបើទោសត្រូវទទួលមានច្រើន ហើយមានប្រភេទដូចគ្នា តុលាការត្រូវប្រកាសទោសតែមួយនៃប្រភេទនេះ នៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ ។

៤៥-ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនវឿន** ត្រូវបានរកឃើញថា មានពិរុទ្ធលើបទល្មើសច្រើនដែលត្រូវបានចាត់ថ្នាក់ថា ជាបទល្មើសត្រួតគ្នា ។ ហេតុដូចនេះ យោងតាមបញ្ញត្តិមាត្រា ១៣៧ នៃក្រមព្រហ្មទណ្ឌខាងលើ តុលាការត្រូវធ្វើការប្រកាសនូវទោសតែមួយនៃប្រភេទដែលដូចគ្នា នៅក្នុងព្រំដែនអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ លើជនជាប់ចោទឈ្មោះ [redacted] **ប៊ុនវឿន** ។

៤៦-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ទី** បានដាក់បណ្តឹងទាមទារនូវប្រាក់ដែលដើមបណ្តឹងរដ្ឋប្បវេណីបានប្រគល់ឱ្យជនជាប់ចោទឈ្មោះ [redacted] **ប៊ុនវឿន** ចំនួន ២០.០០០ (ម្ភៃពាន់) ដុល្លារអាមេរិក ដើម្បីផ្តល់ជូននូវវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ។ ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនវឿន** បានទទួលស្គាល់ថា ជនជាប់ចោទពិតជាបានទទួលប្រាក់ក្នុងចំនួនខាងលើពិតប្រាកដមែន ប៉ុន្តែជនជាប់ចោទបានបំពេញកិច្ចការផ្តល់ជូននូវវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុទៅឱ្យឈ្មោះ [redacted] **ទី** រួចហើយ ។ ដោយពិនិត្យឃើញថា ជនជាប់ចោទបានទទួលស្គាល់នូវទំហំទឹកប្រាក់ ដែលជនជាប់ចោទបានទទួលស្របតាមការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយជនជាប់ចោទក៏មិនមានសំអាង ដើម្បីបញ្ជាក់ទំហំនៃការចំណាយចាំបាច់ដើម្បីផ្តល់ជូននូវវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ គប្បីតុលាការសម្រេចតាមការទាមទាររបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ។

៤៧-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ហេងឡុង** បានដាក់បណ្តឹងទាមទារនូវប្រាក់ដែលដើមបណ្តឹងរដ្ឋប្បវេណីបានប្រគល់ឱ្យជនជាប់ចោទឈ្មោះ [redacted] **ប៊ុនវឿន** ចំនួន ១២.០០០ (ដប់ពីរពាន់) ដុល្លារអាមេរិក នៅក្នុងបន្ទប់របស់ជនជាប់ចោទកាលពីអំឡុងខែមិថុនា ឆ្នាំ២០១៩ ដើម្បីផ្តល់ជូននូវវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុឱ្យដើមបណ្តឹងរដ្ឋប្បវេណី គប្បីតុលាការសម្រេចតាមការទាមទារនេះ ។

៤៨-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការដែលប្តឹងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទ ឈ្មោះ [redacted] **ប៊ុនវឿន** ពីបទ វិតិក្រម រំលោភអំណាច និងសម្អាត ប្រព្រឹត្តនៅខេត្តពោធិ៍សាត់ កាលពីអំឡុងឆ្នាំ២០១៦ រហូតដល់ថ្ងៃទី២៦-២៧ ខែកក្កដា ឆ្នាំ២០១៩ តាមបញ្ញត្តិមាត្រា ៥៩២ , មាត្រា ៥៩៣ នៃក្រមព្រហ្មទណ្ឌ , មាត្រា ៣៥ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និងតាមបញ្ញត្តិមាត្រា ៣ថ្មី , ២៩ថ្មី១ នៃច្បាប់ស្តីពីវិសោធនកម្ម មាត្រា ៣ , មាត្រា ២៩ និងមាត្រា ៣០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភាវរកម្ម ព្រមទាំងសេចក្តីសន្និដ្ឋានប្តឹងសុំឱ្យតុលាការសម្រេចរឹបអូសលើវត្ថុតាងយកនានាមានសំអាងគ្រប់គ្រាន់គប្បីតុលាការយកមកពិចារណា ។ ប៉ុន្តែសេចក្តីសន្និដ្ឋានប្តឹងសុំឱ្យតុលាការសម្រេចរឹបអូសនូវប្រាក់ចំនួន ៣៧២.៧៤៧ (បីរយចិតសិបពីរពាន់ និងប្រាំពីររយសែសិបប្រាំពីរ) ដុល្លារអាមេរិក និងប្រាក់ចំនួន ៤៩.០០០.០០០ (សែសិបប្រាំបួនលាន) រៀល ពុំមានសំអាងដើម្បីឱ្យតុលាការសម្រេចតាមការទាមទារនោះទេ ។ តុលាការយល់ឃើញថា ទឹកប្រាក់ខាងលើនេះត្រូវបានបំប្លែងទៅជាចលនទ្រព្យ និងអចលនទ្រព្យនានារួចហើយ ហេតុនេះ ពុំមានប្រាក់ខាងលើនៅសេសសល់ដើម្បីរឹបអូសនោះទេ ។

៤៩-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការដែលប្តឹងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទ ឈ្មោះ **ជាង វុទ្ធី** និងជនជាប់ចោទឈ្មោះ [redacted] **ប៊ុនថេង** ពីបទ វិតិក្រម មានសំអាងគ្រប់គ្រាន់ គប្បីតុលាការពិចារណា ។ ប៉ុន្តែសេចក្តី

សន្និដ្ឋានប្ដឹងសុំឱ្យតុលាការផ្ដន្ទាទោសជនជាប់ចោទទាំងពីរពីបទ រំលោភអំណាច ពុំមានសំអាងគ្រប់គ្រាន់អាចឱ្យតុលាការពិចារណាបានឡើយ ។

**៥០**-សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **ប៊ុនរឿន** ដែលស្នើសុំឱ្យតុលាការពិចារណាអំពីស្ថានសម្រាលដល់ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនរឿន** ដោយមូលហេតុថា ជនជាប់ចោទទទួលស្គាល់នូវទោសកំហុស ហើយកន្លងមកជនជាប់ចោទក៏បានកសាងស្នាដៃជាច្រើនជូនដល់ស្ថាប័ន ។ ជនជាប់ចោទកំពុងជួបប្រទះបញ្ហាសុខភាពដែលត្រូវទទួលការព្យាបាល និងជាជនបង្គោលក្នុងគ្រួសារដែលកំពុងតែជួបប្រទះនូវវិបត្តិធ្ងន់ធ្ងរដោយសារអវត្តមានរបស់ជនជាប់ចោទ ។ សេចក្ដីសន្និដ្ឋានទាំងអស់នេះ តុលាការនឹងយកជាមូលដ្ឋានពិចារណាដើម្បីសម្រេចអំពីទោស ។ ដោយឡែកពាក់ព័ន្ធទៅនឹងទ្រព្យសម្បត្តិ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទមិនមានសំអាងដើម្បីបញ្ជាក់អំពីភាគនៃទ្រព្យសម្បត្តិដែលត្រឹមត្រូវនោះទេ ។ ហេតុនេះ តុលាការមិនមានមូលដ្ឋានដកចេញ នូវភាគដែលត្រឹមត្រូវតាមការទាមទារឡើយ ។

**៥១**-នាពេលសវនាការ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **វុទ្ធី** បានស្នើសុំតុលាការឱ្យកែប្រែបញ្ញត្តិចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] **វុទ្ធី** ទៅបទ **មិនប្ដឹងបរិហារបទឧក្រិដ្ឋ** បទល្មើសមានទោសជាប់ចោទ ... ទោសតាមបញ្ញត្តិមាត្រា ៥២៩ នៃក្រមព្រហ្មទណ្ឌ ដោយសំអាងថា ជនជាប់ចោទគ្រាន់តែបានដឹងអំពីអំពើល្មើស ហើយមិនប្ដឹងបរិហារ ជនជាប់ចោទមិនបានចូលរួមប្រព្រឹត្តបទល្មើសនោះទេ ។ ជនជាប់ចោទពុំបានទទួលផលប្រយោជន៍ក្នុងអំពើទាំងអស់នេះទេ ហើយវត្តមានរបស់ជនជាប់ចោទឈ្មោះ [redacted] **វុទ្ធី** គ្រាន់តែជាការថៃដន្យដោយសារតែជនជាប់ចោទឈ្មោះ [redacted] **វុទ្ធី** ពឹងពាក់ឈ្មោះ [redacted] **ប៊ុនថេង** ជាមធ្យោបាយធ្វើដំណើរ ។ ចំពោះសេចក្ដីសន្និដ្ឋានខាងលើនេះ តុលាការយល់ឃើញថា ពុំបានរំលេចអង្គហេតុឱ្យបានពេញលេញនោះទេ ។ ជាក់ស្ដែង ចេតនារបស់ជនជាប់ចោទឈ្មោះ [redacted] **វុទ្ធី** ក្នុងការចូលរួមប្រព្រឹត្តអំពើល្មើសខាងលើនេះ ត្រូវបានស្ដែងឡើងយ៉ាងច្បាស់នាពេលដែលមានការប្រគល់ទទួលប្រាក់រវាងជនជាប់ចោទឈ្មោះ [redacted] **ប៊ុនរឿន** និងតំណាងក្រុមហ៊ុន ដោយជនជាប់ចោទឈ្មោះ [redacted] **វុទ្ធី** បានអះអាង និងចេញទៅខាងក្រៅដើម្បីយាមទ្វារ ។ ហេតុនេះ សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិខាងលើមិនមានភាពត្រឹមត្រូវទេ ។

**៥២**-នាពេលសវនាការ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **ប៊ុនថេង** បានស្នើសុំឱ្យតុលាការសម្រេច ឱ្យជនជាប់ចោទបានរួចផុតបទចោទពីបទ **រំលោភអំណាច** និងស្នើសុំបន្ធូរបន្ថយទោសពីបទ **វិតិក្រម** ដោយសំអាងថា ជនជាប់ចោទបានធ្វើសកម្មភាពក្នុងស្ថានភាពដែលជនជាប់ចោទ មិនបានយល់ច្បាស់ចំពោះអំពើរបស់ខ្លួនជាបទល្មើសព្រហ្មទណ្ឌ ហើយជនជាប់ចោទក៏មិនដែលបានទាមទារប្រាក់ពីក្រុមហ៊ុន ឬប្រើប្រាស់នូវតួនាទីរបស់ខ្លួនទៅធ្វើការគាបសង្កត់ឱ្យប្រើប្រាស់សេវារត់ការនោះដែរ ។ ចំពោះសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទខាងលើនេះ តុលាការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនថេង** ពិតជាពុំមានសិទ្ធិអំណាចក្នុងការចាត់វិធានការណ៍រារាំងការអនុវត្តច្បាប់នោះដែរ ។ ប៉ុន្តែបើទោះបីជានៅក្នុងអង្គហេតុជនជាប់ចោទពុំដែលបានទាមទារប្រាក់ពីតំណាងក្រុមហ៊ុនក៏ដោយ តុលាការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនថេង** មានការព្រមព្រៀងដោយផ្ទាល់ក្នុងអំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **ប៊ុនរឿន** តាមរយៈការចូលរួមជាបន្តបន្ទាប់នៅក្នុងសកម្មភាពរបស់ឈ្មោះ [redacted] **ប៊ុនរឿន** ដូចជា ការគណនា និងទាមទារប្រាក់ ព្រមទាំងការទទួលប្រាក់ដែលជាសេវាក្រៅច្បាប់ ។

## ហេតុដូច្នេះសម្រេច

I-ឱ្យឈ្មោះ [redacted] **វុទ្ធី** និងឈ្មោះ [redacted] **ប៊ុនថេង** រួចខ្លួនពីបទចោទពីបទ រំលោភអំណាច ប្រព្រឹត្តនៅខេត្តពោធិ៍សាត់ កាលពីថ្ងៃទី២៦-២៧ ខែកក្កដា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងតាមបញ្ញត្តិមាត្រា ៣៥ នៃច្បាប់ស្ដីពីការ

ប្រឆាំងអំពើពុករលួយ ។

II-ផ្តន្ទាទោស៖

១-ឈ្មោះ [redacted] ប៊ុនថេង ភេទប្រុស ដែលមានសាវតាជាតិខាងលើ ដាក់ពន្ធនាគារកំណត់ **២ឆ្នាំ និង ៦ខែ (ពីរឆ្នាំ និងប្រាំមួយខែ)** និងពិន័យជាប្រាក់ចំនួន **៥.០០០.០០០ (ប្រាំលាន) រៀល**

២-ឈ្មោះ [redacted] វុទ្ធី ភេទប្រុស ដែលមានសាវតាជាតិខាងលើ ដាក់ពន្ធនាគារកំណត់ **៣ (បី) ឆ្នាំ** និងពិន័យជាប្រាក់ចំនួន **៥.០០០.០០០ (ប្រាំលាន) រៀល**

ពីបទ **ឧក្រិដ្ឋ** ប្រព្រឹត្តនៅខេត្តពោធិ៍សាត់ កាលពីថ្ងៃទី២៦-២៧ ខែកក្កដា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌ មានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥៩២ និងមាត្រា ៥៩៣ នៃក្រមព្រហ្មទណ្ឌ ។

III-ផ្តន្ទាទោសឈ្មោះ [redacted] **ប៊ុនរឿន** ភេទប្រុស ដែលមានសាវតាជាតិខាងលើ ដាក់ពន្ធនាគារកំណត់រយៈពេល **៨ (ប្រាំបី) ឆ្នាំ** និងពិន័យជាប្រាក់ចំនួន **៨.០០០.០០០ (ប្រាំបីលាន) រៀល** ពីបទ **ឧក្រិដ្ឋ** , បទ **រំលោភអំណាច** និងបទ **សម្អាតប្រាក់** ប្រព្រឹត្តនៅខេត្តពោធិ៍សាត់ កាលពីអំឡុងឆ្នាំ២០១៦ រហូតដល់ថ្ងៃទី២៦-២៧ ខែកក្កដា ឆ្នាំ២០១៩ តាមបញ្ញត្តិមាត្រា ៥៩២ មាត្រា ៥៩៣ នៃក្រមព្រហ្មទណ្ឌ មាត្រា ៣៥ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និងតាមបញ្ញត្តិមាត្រា ៣ថ្មី និងមាត្រា ២៩ថ្មី១ កថាខណ្ឌទី២ នៃច្បាប់ វិសោធនកម្មមាត្រា ៣ មាត្រា ២៩ និងមាត្រា ៣០ នៃច្បាប់ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

IV-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] **ប៊ុនរឿន** សងសំណងជាប្រាក់៖

១-ចំនួន ២០.០០០ (ម្ភៃពាន់) ដុល្លារអាមេរិក ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ទី** ។

២-ចំនួន ១២.០០០ (ដប់ពីរពាន់) ដុល្លារអាមេរិក ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ហេងឡុង** ។

V-រឹបអូសវត្ថុចាប់យករួមមាន៖

១-អចលនវត្ថុ(ដីផ្ទះ) លេខ ៦១ ផ្លូវលេខ៤ បុរីប៉េងហួត (ប៉ុស្តិ៍វិទ្យុស្ទឹងមានជ័យ) ភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលមានដោយវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៦០១០៧-២៧៥៩ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៧ ចេញដោយមន្ទីរដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ។

២-អចលនវត្ថុ(ដីផ្ទះ) ទីតាំងនៅភូមិដូងជ្រុំ សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៥០៥០៥០២-០១៥៣ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៩ ចេញដោយមន្ទីរដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តពោធិ៍សាត់ ។

៣-អចលនវត្ថុ(ដីផ្ទះ) ទីតាំងស្ថិតនៅភូមិស្ពានថ្ម សង្កាត់រលាប ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៥០៥០៦០៥-០៣២៨ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ ចេញដោយមន្ទីរដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តពោធិ៍សាត់។

៤-ចលនវត្ថុ (រថយន្ត) ម៉ាក Lexus 570 ពណ៌ទឹកមាស សេរីឆ្នាំ២០១០ ផ្លាកលេខ ពោធិ៍សាត់ ២C-៣៨៨៨ មានលេខតួ JTJHY00W6A4039974 និងលេខម៉ាស៊ីន 3UR3053578 ។

៥-ចលនវត្ថុ (រថយន្ត) ម៉ាក KIA Morning ពណ៌ស សេរីឆ្នាំ២០១២ ផ្លាកលេខពោធិ៍សាត់ ២D-៣៨៨៨ មានលេខតួ KNABZ511BC150460 និងលេខម៉ាស៊ីន G3LABP117438 ។

៦-ប្រាក់ដុល្លារអាមេរិកចំនួន ១៧.៥២៩ (ដប់ប្រាំពីរពាន់ និងប្រាំរយម្ភៃប្រាំបួន) ដុល្លារអាមេរិក និងប្រាក់រៀលចំនួន ១៦.២៥០.០០០ (ដប់ប្រាំមួយលាន ពីររយហាសិបពាន់) រៀល ។



Scanned with CamScanner

៧-សៀវភៅកត់ត្រាចំនួន ៨ (ប្រាំបី) ក្បាល ។

៨-បង្កាន់ដៃបង់ប្រាក់អង្គភាពមន្ទីរ ដ.ន.ស.ស ពស ចំនួន ៥១ (ហាសិបមួយ) សន្លឹក និងក្រដាសកត់ត្រាទូរទាត់ថ្លៃសេវាដោយដៃចំនួន ៣ (បី) សន្លឹក ។

៩-ទូរស័ព្ទដៃម៉ាក OPPO A7 ពណ៌មាស IMIE:844124040250816 IMIE:864124040250808 ចំនួន ០១ (មួយ) គ្រឿង ,ទូរស័ព្ទដៃម៉ាក One pluse ពណ៌ស IMIE:86750049085417 IMIE:867520049085409 ចំនួន ០១ (មួយ) គ្រឿង, ទូរស័ព្ទដៃម៉ាក Iphone5 ពណ៌ទឹកមាស IMIE:358828054103090 ចំនួន ០១ (មួយ) គ្រឿង, ទូរស័ព្ទដៃម៉ាក SAMSUNG GALAXY Note9 ពណ៌ត្នោត IMIE:352141100681606 IMIE:352142100681604 ចំនួន ០១ (មួយ) គ្រឿង, ទូរស័ព្ទដៃម៉ាក Iphone 7Plus ពណ៌ Rose gold IMIE:35917 207119147 ចំនួន ០១ (មួយ) គ្រឿង, និងទូរស័ព្ទដៃម៉ាក HUAWEI OVA3 ពណ៌ខ្មៅ IMIE:869592 032124675 IMIE:869592032130656 ចំនួន ០១ (មួយ) គ្រឿង ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២០ និងថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ប៊ុនរឿន ឈ្មោ[redacted] ប៊ុនថេង និងឈ្មោះ[redacted] វុទ្ធី និងប្រកាសជាសាធារណៈនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ ។

ជនជាប់ចោទមានសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់ ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ៥កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០

| បានឃើញ | |
|---|---|
| ប្រធានក្រុមប្រឹក្សាជំនុំជម្រះ | ក្រឡាបញ្ជីសវនាការ |
| [redacted] | [redacted] |



Scanned with CamScanner